ឆ្នាំទី ៥

លេខ ៩

# ទស្សនាវដ្ដី សាស្ត្រាចារ្យ

ផ្សាយចេញរាល់ត្រីមាស



ផ្សាយចេញ
ពីសមាគម សាស្ត្រាចារ្យ

ទីចាត់ការបណ្ដោះអាសន្ន
៦០,ផ្លូវអូរឫស្សី

ភ្នំពេញ

# [illegible]

# [illegible]

[illegible]



[illegible]

[illegible]

លេខ ៧ ខែកក្កដា សីហា កញ្ញា ១៩៦២

# មាតិការឿងៈ


| | ទំព័រ |
|---|---|
| កថាមុខ | ក |
| **បិតុ-គរុកោសល្យ** | |
| — ផលល្អកើតពីទំលាប់ឲ្យសិស្សប្រុស . . . | ១ |
| — ការចាប់អារម្មណ៍ ចំពោះវិញ្ញាសាខ្លះៗ . . . | ៤ |
| — ប្រវត្តិសាស្ត្រនៃកាលប្រវត្តិវិជ្ជា . . . . | ១០ |
| — ការពិសោធន៍ ខាងមុខវិជ្ជាខ្លះ . . . . | ១៥ |
| — ប្រធានដែលបានឲ្យក្នុងការប្រឡងចូលរ-ជ-គ . . | ១៩ |
| **វិទ្យាសាស្ត្រនិងសិល្ប** | |
| — បណ្ដាំទំនើប . . . . . . | ២៥ |
| — លូ ស៊ិន កត្រ្កមួយដ៏ឆើតឆាយ . . . | ២៨ |
| **ស្ទូរដ្ឋងសាលា** | |
| — La situation de notre Faculté des Siences . . . | ៣៥ |
| — អាកប្បកិរិយាដ៏រឹងរុះ . . . . . | ៣៩ |
| **ដំណើរទស្សនកិច្ច** | |
| — សន្និសីទ ស្ដីអំពីវប្បធម៌ និងអក្សរសាស្ត្រ នៅសហភាពសូវៀត . | ៤២ |
| **សកម្មភាពសមាគម** | |
| — ញត្តិសំដែងអំណរគុណថ្វាយសម្ដេចឪ . . . | ៥៤ |
| **ប្រអប់សំបុត្រ** | |
| — ការឆ្លើយតបមិត្ត អ៊ុក សាម៉ន . . . | ៥៦ |
| — សំបុត្រពីខេត្តស្វាយរៀង . . . . | ៦០ |
| **កំប្លែង** . . . . . | ៦១ |

សេចក្តីថ្លែងការណ៍
នៃសមាគមសាស្ត្រាចារ្យខ្មែរ

## កថាមុខ

ព្រឹត្តិការណ៍ដែលនាំឲ្យចាប់អារម្មណ៍ខ្លាំងក្នុងមជ្ឈដ្ឋានសាស្ត្រាចារ្យ ព្រះប្រមុខរដ្ឋទ្រង់បានដោះស្រាយរឿងផ្ទាល់សាស្ត្រាចារ្យ ដោយព្រះទ័យសន្តោសប្រណី និងសំរុះសំរួលជាទីបំផុត នៅខែត្រគតពង្សហើយ ស្រាប់តែកាសែតឈ្មោះ "អ្នកនាំសារ" ធៀតរកឧប្បត្តិហេតុមកចិះដៀលជាថ្មី ដើម្បីឲ្យមានការសង្ស័យលែងទុកចិត្តក្រសួងសិក្សាធិការ ។ អ្នកសរសេរអត្ថបទនោះ ដែលជាជនបរទេសចោលថា ចាំអំពីមហាជនមិនលើកគ្នាធ្វើញត្តិតវ៉ាក្នុងកាំងកំទេចពួកគ្រូទៅ ម្តេចក៏នៅស្ងៀមដូចនេះ ? រួចគេឆ្លើយខ្លួនគេថា "ឬមួយក៏មកពីមហាជនខ្មែរសំពឹងតែចាំទទួលកុម្មុយនីសតាមយថាកម្ម ឬមួយរឹតតែលង់មិនឃើញអាសន្នកុម្មុយនីស" ។ គេហៅពួកគ្រូថាជា "បញ្ញវ័ន្តពុំទាន់ស្ទើរ" (semi-intellectuel) ដែលដើរតែបង្ខូចខួរក្បាលកូនខ្មែរ (tripoter l'intelligence et le coeur de nos enfants) ។ គោលបំណងធំរបស់គេមានខ្សែស្រឡាយវែងឆ្ងាយណាស់ គឺគេចង់ញុះញង់ឲ្យមានវិបត្តិមួយយ៉ាងធ្ងន់ក្នុងសិក្សាធិការជាតិយើង និងបំបាក់បំបែកសាមគ្គីភាពដែលកំពុងតែរឹងប៉ឹងនៅជុំវិញសម្តេចឪដូចសព្វថ្ងៃនេះ ។ ក្រសួងអប់រំជាតិបានឆ្លើយដោយឡែករួចទៅហើយ រីឯសមាគមយើងក៏ពុំអាចទុកឲ្យមានបរិយាកាសកករល្អក់ ដល់កិត្តិយសនិងចិត្តស្មោះត្រង់បរិសុទ្ធនៃសាស្ត្រាចារ្យយើងដែរ ។ ដូចនេះហើយ ទើបគណៈកម្មាធិការនាយកបានធ្វើសេចក្តីកែតំរូវ ផ្សាយតាមសារពត៌មាននិងវិទ្យុជាតិ ដែលមានខ្លឹមសារដូចតទៅ :

ការសែតកាតូលិកប្រចាំសប្តាហ៍ឈ្មោះ "អ្នកនាំសារ" បានផ្សាយក្នុងលេខចុះថ្ងៃទី ៤ សីហា ១៩៦៤ នូវអត្ថបទមួយមានលក្ខណៈចាក់ដោត ក្រោមចំណងជើងថា "តើយើងអាចទុកចិត្តលើគ្រូបង្រៀនបានឬទេ?" ដែលបានប៉ះពាល់ខ្លាំងដល់កិត្តិយសនៃបុគ្គលិកផ្នែកសិក្សា ។ នៅក្នុងអត្ថបទនោះមានចោទអំពី "វិទ្ធង្សនាកុម្មុយនីសបំទមុខ" ដែលពួកគ្រូបានធ្វើ អំពីគ្រោះអាសន្នចំពោះយុវជន អំពី "លក្ខណៈមិនហ៊ឺនទំនៃអព្យាក្រឹតយើង" ហើយអ្នកនិពន្ធក៏តាំងតែអួសទាញឪពុកម្តាយសិស្សឲ្យលើកគ្នាធ្វើញត្តិថ្កោលទោសបណ្តាអ្នកអប់រំ ។

ដោយឈឺចាប់ជាខ្លាំងចំពោះពាក្យចោទករៀងដ៏ទម្ងន់នេះ សមាគមយើងត្រូវតែតប់ទល់តាមសេចក្តីបញ្ជាក់ដូចតទៅនេះ ដើម្បីកុំឲ្យមានការមន្ទិលសង្ស័យតទៅមុខទៀត ចំពោះចិត្តថ្លើមនៃសមាជិកទាំងឡាយរបស់យើង :

១– យើងសូមសំដែងជាថ្មីយ៉ាងឱឡារិក នូវសេចក្តីទុកចិត្តនិងចំណងស្មោះភក្តិដែលគ្មានអ្វីផ្តាច់បាន ចំពោះព្រះអង្គសម្តេចនិងចំពោះការដឹកនាំដ៏ក្លាហានរបស់ព្រះអង្គ ដូចដែលយើងធ្លាប់តែប្រកាន់ខ្ជាប់តាំងតែពីដើមរៀងមកហើយ ។

២– យើងស្រឡាញ់ខ្ជាប់ខ្ជួនក្នុងចិត្តជានិច្ចនូវលទ្ធិប្រជាធិបតេយ្យ នូវនយោបាយអព្យាក្រឹត ហើយយើងមិនព្រមដើរឲ្យវៀចពីផ្លូវជាតិជាដាច់ខាត ។

៣– យើងយល់ច្បាស់នូវការទទួលខុសត្រូវរបស់យើង ក្នុងឋានៈជាអ្នកអប់រំ ហើយយល់ភារៈកិច្ចរបស់យើងក្នុងការកសាងប្រទេសជាតិ ។ យើងពុំដែលពន់បំពេញករណីយកិច្ចដ៏លំបាករបស់យើងពាល់តែសោះ ដើម្បីបណ្តុះបណ្តាលយុវជនយើងខាងផ្លូវកាយនិងផ្លូវចិត្ត ព្រមទាំងអប់រំយុវជននេះក្នុងមាគ៌ាស្នេហាជាតិដ៏បរិសុទ្ធ និងក្នុងការគោរពដ៏លើសលប់ចំពោះព្រះពុទ្ធសាសនានិងព្រះរាជបល្ល័ង្ក ។

សូមប្រកាសនូវចំណុចទាំងនេះឲ្យច្បាស់លាស់អស់ពីពោះ ដើម្បីកុំឲ្យអ្នកកាសែតក្លែងក្លាយជាតិបរទេស (យើងដូចជាច្បាស់ល្អមដែរ) សរសេរកេលេស មកមួលបង្កាច់បុគ្គលិកផ្នែក

សិក្សាទៀត ៗ មិនមែនជាលើកដំបូងទេ ដែលយើងឃើញផងអកុសលនេះ ធ្លៀតឱកាស ពេលដែលមានការរអាក់រអួលបន្តិចបន្តួចក្នុងកិច្ចការជាតិយើង ដើម្បីប្រព្រឹត្តអំពើថោកទាប ចាក់រុកបំបាក់បំបែកផ្ទៃក្នុងនៃសង្គមជាតិយើង ៗ ម្យ៉ាងទៀត យើងពុំបើកសិទ្ធិឲ្យជនបរទេស នេះនិយាយពេញមាត់ពុំបេះខ្មាសអៀន អំពីការការពារបីតិកភណ្ឌជាតិ "យើង" និងការពារ ព្រះពុទ្ធសាសនា "យើង" ឡើយ ៗ ថា "យើង" ពុំកើតទេ បើខ្លួនជាបរទេស សរសេរក្នុងសន្ទឹកកាសែត ដែលជាអ្នកនាំសាររបស់វិមានកាតូលិក វ៉ាទីកង់ តែប៉ុណ្ណោះ ៗ

យើងធ្លៀតឱកាសនេះ អញ្ជើញឪពុកម្ដាយសិស្សពិនិត្យមើល តើមកទល់សព្វថ្ងៃនេះ កូនចៅលោកអ្នកបានទទួលការអប់រំត្រឹមត្រូវតាមឧត្តមគតិជាតិឬទេ ? ហើយតើសាស្ត្រាចារ្យ ចាងហ្វាងសាលានិងគ្រូបង្រៀនទាំងឡាយ តាមដែលលោកធ្លាប់ស្គាល់ បានរួបរួមមុនគេ ឬក្រោយគេក្នុងសកម្មភាពជាតិ ដូចជាចលនាយុវជនរាជសង្គមនិយមខ្មែរ ការហាត់កម្មនឹងកីឡា ជាដើម ៗ

ភ្នំពេញ នៅថ្ងៃទី ១៣ សីហា ១៩៦២

គណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យ

X

X X

## ញត្តិ

សូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះរាជទានក្រាបបង្គំទូលសម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ ៗ

ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ជាសមាជិកគណៈកម្មាធិការនាយកសមាគមសាស្ត្រាចារ្យខ្មែរ,

– ក្រោយពីបានស្តាប់តាមវិទ្យុជាតិនូវព្រះរាជសន្និសិទរបស់សម្តេចព្រះមុខរដ្ឋ នៅពេជ្រនិល ពីថ្ងៃទី ១៤ សីហា នៅខេត្តតាកែវ ពីថ្ងៃទី ១៧ សីហា និងនៅព្រះទីនាំងភោជនីយនាព្រះបរមរាជវាំង ពីថ្ងៃទី ២០ សីហា ១៩៦២ នេះ,

មានសេចក្តីឈឺចាប់យ៉ាងខ្លាំងចំពោះអំពើឈ្លានពានរបស់ថៃ យកទឹកដីខ្មែរ នៅព្រះវិហារជាក្បាន្តនិងនៅហាត់ឡែក "កោះកុង" ដែលមានទាំងនាយទាហានអាមេរិកាំង ១០ នាក់ រួមមកជាមួយផង ។

នៅចំពោះមុខអំពើគម្រាមកំហែងរបស់ថៃសេ-អា-តូ ដែលមានមហាអំណាច "លោកសេរី" ជួយឧបត្ថម្ភដោយចំហយ៉ាងនេះ ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ជាសាស្ត្រាចារ្យ សូមប្តេជ្ញាចិត្តគាំទ្រពេញទំហឹងនូវព្រះរាជសន្និសិទទាំងបីនេះ និងទ្រទ្រង់នូវព្រះរាជនយោបាយនិងព្រះរាជយោបល់ស្តីពីការអំពាវនាវឲ្យមហាអំណាចទាំង ១៤ ទៅហ្សឺណែវមករួមប្រជុំឡើងវិញ ដើម្បីធានាអះអាងដល់អព្យាក្រឹតភាពខ្មែរ ។

ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ប្តេជ្ញាថានឹងរួបរួមជុំវិញសម្តេចឪក្នុងការការពារនយោបាយអព្យាក្រឹត ការពារបូរណភាពនៃដែនដីកម្ពុជា លុះត្រាជីវិតបង់ ប្រឆាំងនឹងគ្រប់អំពើឈ្លានពានរបស់ថៃ ដែលជាបាវបំរើគេ ធ្វើឫកចក្រពត្រ ។

សេចក្តីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស

សូមព្រះរាជទានក្រាបបង្គំទូលនៅភ្នំពេញ ថ្ងៃទី២០ សីហា ១៩៦២

សមាជិកគណៈកម្មាធិការនាយក




## ផលល្អកើតពីទំលាប់ •
## ឲ្យសិស្សប្រុសនិងសិស្សស្រី រៀនជាមួយគ្នា

ក្នុងសាលាដែលសិស្សប្រុស និង សិស្សស្រី រៀនចូលគ្នា គេសំគាល់ឃើញថាស្រួលរក្សាវិន័យជាងក្នុងសាលាដែលយុវជនទាំងពីរប្រភេទនេះនៅដាច់ពីគ្នា ។ តើហេតុអ្វី ? - ឆ្លើយថា ហេតុមកពីមានតុល្យភាព រវាងការលូតលាស់ភេទស្រីនិងការលូតលាស់ភេទប្រុស ។

គួរសំគាល់តែប៉ុណ្ណោះ ! ក្នុងថ្នាក់ដែលមានតែសិស្សប្រុស ៗ ការលេងសើចច្រើនពោរពេញទៅដោយពាក្យទិលខូច ទៅដោយកាយវិការលោតផ្ដោក្រមាល់ ទៅដោយអាកប្បកិរិយារឹងរូស គ្មានអធ្យាស្រ័យ ។ ចំណែកឯក្នុងថ្នាក់ដែលមានតែសិស្សស្រី ៗ វិញ គេច្រើនប្រទះជាញឹកញាប់នូវការខ្សិបខ្សៀវលាក់ពុតលាក់គំនិត នូវប្រុកពាម៉ិកម៉ក់ នូវទឹកមុខកញ្ចួបកញ្ចូវ នូវការសំរក់ទឹកភ្នែកនៅចំពោះមុខគ្រូ ។ ក្នុងករណីទាំងពីរនេះ ច្បាស់ជាមានវិបត្តិមួយហើយ ដ្បិតយុវជនប្រុសឬស្រីលូតលាស់នៅក្នុងមជ្ឈដ្ឋានមួយ ដែលមិនសមនឹងលក្ខណៈធម្មជាតិ ។

តាមទំនៀមទំលាប់ខ្មែរយើង តែចេញក្រៅគ្រួសារកាលណា គេចូលចិត្តបំបែកប្រុសដោយឡែក ស្រីដោយឡែក តាំងពីអង្គុយស្ដាប់ធម៌ទេសនា ចូលរង់ទទួលទានបាយឡើងទៅ ។

គរុកោសល្យទំនើប មិននិយមបំបែកភេទយ៉ាងនេះទេ ក្នុងការអប់រំយុវជន ។ ពេលដែលរៀនក្នុងវិទ្យាល័យ-អនុវិទ្យាល័យ ការលូតលាស់សព៌ាង្គកាយកំពុងតែពេញសន្ទុះក្នុងយុវជន ដែលយើងហៅថា “ឡើងខ្លួន„ ។ កាលណាបើឃើញគ្នាព្រឹកល្ងាច ការទាក់ទងរវាងសិស្សប្រុស នឹង សិស្សស្រីមានលក្ខណៈធម្មតា ស្មោះត្រង់គួរសម ។ ផ្ទុយទៅវិញ បើគេចេះតែឃាត់មិនឲ្យទាក់ទងគ្នា បើគេចេះតែបិទបាំងច្រើនពេក យុវជនរឹតតែចង់ដឹងសង្ស័យ ហើយមាននិន្នាការចង់ជំនះការខាខាំងនេះ ។ បាតុភាពលេចចេញមក ជួនកាលទៅជាខ្មាសអៀនច្រើនពេក គេចមុខពីគ្នា ជួនកាលទៅជាជ្រើមពេក ឬ ស្រើបស្រាលរកជួបគ្នាដោយលួចលាក់ទៅវិញ ។ មិត្តយើងជាសាស្ត្រាចារ្យប្រហែលជាធ្លាប់ប្រទះនៅក្នុងថ្នាក់ដែលមានតែសិស្សប្រុស ៗ ថាគ្រាន់តែនិយាយអ្វីមួយប៉ះពាល់ទៅលើរូបកាយស្ត្រី ក៏ស្រាប់តែឮហ៊ោកញ្ជ្រៀវឥតសមហេតុផល ហើយខ្លះសូមឲ្យលោកគ្រូបន្ថែមទៀតផង ។ ពេលទៅមើលសិស្សនារីប្រកួតកីឡា គេសំគាល់ឃើញថាសិស្សប្រុស ៗ ដែលធ្លាប់រៀនជាមួយស្រី ៗ មានប្រតិកម្មធម្មតា ជួយទះដៃលើកទឹកចិត្ត ប៉ុន្តែសិស្សប្រុស ៗ ខ្លះ ដែលមកពីសាលាគ្មានស្រី ៗ រៀនជាមួយ គិតតែគយគន់រាងកាយគេ ហើយមានពាក្យសំដីពុំសមរម្យសោះ ។ ដូច្នេះ ក្នុងសាលាណាដែលសិស្សប្រុស នឹងសិស្សស្រីធ្លាប់អង្គុយរៀនជាមួយគ្នាតាំងពីថ្នាក់ក្រោម ៗ ទៅ ការលូតលាស់ខាងផ្លូវកាយនឹងផ្លូវចិត្តពុំចោទឲ្យមានវិបត្តិទេ ឯការស្និទ្ធស្នាលក៏ពុំហួសព្រំដែននៃមិត្តភាពដែរ ។

ចាប់ពីអាយុ ១៧ ទៅ ២០ ឆ្នាំ ពិសេសក្នុងចំពួកសិស្សដែលរៀនពីថ្នាក់ទី ២ ទំនើបឡើងទៅលើ ចិត្តថ្មើមក្នុងការស្និទ្ធស្នាលអាចវិវត្តទៅរកមនោសញ្ចេតនាជ្រៅ ៗ ទៀត ។ ចំនួនតិចទេដែលមិត្តភាពក្លាយទៅជាការប្រតិព័ទ្ធ ប៉ុន្តែការប្រតិព័ទ្ធនេះរវាងយុវជនពីររូប ដែលស្គាល់គ្នាតាំងពីដើមមក មានគ្រោះថ្នាក់តិចជាង ការប្រតិព័ទ្ធរវាងយុវជនដែលមិនដែលស្គាល់គ្នាសោះ ។ ក្នុងពេលនោះហើយដែលអ្នកអប់រំត្រូវប្រយ័ត្ន ហើយចេះរកវិធីអប់រំនឹងព្រមាន ដោយយល់ចិត្តថ្មើមសិស្សឲ្យច្បាស់ ដើម្បីដាក់កំរិតព្រំដែនក្នុងការស្និទ្ធស្នាលរវាងគ្នានឹងគ្នា ។ កុំឲ្យគ្រាន់តែចាប់សំបុត្របានមួយ បង្អើលគ្រូនឹងសិស្សមួយសាលា

ព្រមទាំងត្រូវសារសាមីខ្លួនទាំងពីរ ជួបជល់គ្នា មានការម៉ាស់មុខ ៗ ចុះបើយុវជនឃើញមនោ-សញ្ចេតនា ដែលខ្លួននឹកថាល្អបរិសុទ្ធក្លាយទៅជាទោស យ៉ាងការម៉ាស់មុខទៅវិញ តើគ្នាឈឺចាប់ឬទេ ? សិស្សខ្លះមានប្រតិកម្មមកវិញ គឺស្អប់ទាំងអស់ នឹងប្រមាថច្បាប់ដែលសង្គមមនុស្សធ្វើពីព្រោះតែគេមិនយល់ចិត្តខ្លួន ៗ

និយាយយ៉ាងនេះ មិនមែនថាឲ្យសាស្ត្រាចារ្យ បណ្តែតបណ្តោយឲ្យសិស្សប្រុស នឹងសិស្សស្រី ប្រឡូកប្រឡាក់ជាមួយគ្នាតាមចិត្ត រហូតដល់បណ្តើរគ្នាយប់ ៗ ចូលពេងកុន ឬ ទៅរាំ "ធូស្ត" នោះទេ ៗ ដ្បិតម្យ៉ាង ទំនៀមទំលាប់ខ្មែរយើង ពុំទាន់វិវត្តទៅដល់កំរិតនេះ ហើយឪពុកម្តាយសិស្សលោកពុំអនុញ្ញាតឲ្យ ម្យ៉ាងទៀតការអប់រំសព្វថ្ងៃមិនទាន់ជំរះស្មារតីយុវជន ឲ្យអស់កំអែលខ្លះនៅឡើយទេ ៗ ប៉ុន្តែក្នុងបរិវេណសាលា ការបញ្ចូលសិស្សប្រុសនឹងសិស្សស្រីឲ្យរៀនជាមួយគ្នា ជាការចាំបាច់ ចំពោះសង្គមជាតិយើងទៅអនាគត ដើម្បីឲ្យស្ត្រីបានស្មើនឹងប្រុសខាងផ្លូវច្បាប់ ក៏ដូចខាងផ្លូវប្រពៃណី ៗ ការដែលស្រី ៗ ខ្មែរនៅខ្មាសអៀនច្រើននៅឡើយ ពុំហ៊ានចេញមុខធ្វើការស្មើនឹងប្រុស ក្នុងសកម្មភាពដូចជាកីឡាកំច្រៀង ការពារមតិខ្លួនជាវាគ្មិន ឈរឈ្មោះឲ្យគេបោះឆ្នោត ។ល។ មកពីមានគំនិតមួយជាប់នឹងខ្លួនថា ខ្លួនជា "ភេទខ្សោយ" ជាងប្រុស ៗ គំនិតញ៉ម នេះត្រូវផ្លាញ់បាន តាំងតែពីនៅរៀនក្នុងសាលា មកដោយភ្ជាប់បានរាប់អានសិស្សប្រុស ៗ ដែលរៀនជាមួយគ្នា ៗ

ក្នុងប្រទេសយើងសព្វថ្ងៃ សាលាស្ទើរតែទាំងអស់បើកទ្វារឲ្យសិស្សប្រុសនឹងសិស្សស្រីចូលរៀនលាយឡំគ្នាហើយ ៗ នៅសល់តែសាលាមួនដប់ទេ ដែលពុំទាន់កែប្រែរបបដូចជាអនុវិទ្យាល័យព្រះនរោត្តមនៅភ្នំពេញ ដែលជាអនុវិទ្យាល័យនារី នឹងវិទ្យាល័យព្រះស៊ីសុវត្ថិ ដែលមិនទាន់ទទួលសិស្សស្រីក្នុងបឋមភូមិ ហើយទទួលតែពីមធ្យមភូមិទៅលើ ៗ គួរពិនិត្យកែប្រែរបបបំបែកភេទប្រុសពីភេទស្រីនៅក្នុងសាលា ដែលនៅសល់យ៉ាងនេះ ៗ បើឪពុកម្តាយសិស្សណាចង់អប់រំបុត្រីលោកឲ្យផុតពីភេទប្រុស នោះទុកឲ្យលោកយកបុត្រីលោកទៅផ្ទះសាលាយាយជីតែម្តងទៅ !



# ការចាប់អារម្មណ៍
## ចំពោះវិញ្ញាសាខ្មែរខ្លះ ក្នុងការប្រឡងមធ្យមសិក្សាបត្រ

លាង ហាប់-អាន

ជារាល់ដង នៃការប្រឡងមធ្យមសិក្សាប័ត្រ, តាំងពីបុគ្គល តាំងពីសាស្ត្រាចារ្យខាងភាសាខ្មែរ តែងមានការជជែក ឬយោបល់ វិនិច្ឆ័យ ដោយមតិទស្សនៈយោបល់ផ្សេង ៗ គ្នា រកឯកភាពគ្មាន ក្នុងការដោះស្រាយពិភាក្សាវែកញែកចំពោះប្រធាន តែងសេចក្តីខ្មែរ ៗ សោតវិញ្ញាសាសរសេរ តាមសូត្រក៏ដូច្នេះដែរ អ្នកខ្លះពេញចិត្តនឹងអត្ថបទ ខ្លះពុំពេញចិត្ត ខ្លះរិះគន់បន្ទូសទៀតខ្លះថែមទៀត ៗ

ឧបសគ្គ វិបត្តិខាងទឹកចិត្ត នឹងគំនិតនេះមិនមែនកើតមកពីក្រសួងមានសមត្ថកិច្ចតម្រូវ ឬ ដាក់ឲ្យបេក្ខជនធ្វើឲ្យរួចតែពីដៃនោះទេ គឺគេស្រាវជ្រាវជ្រើសរើសយកប្រធានតែពីក្នុងចំណោមវិញ្ញាសាដ៏ច្រើនលើសលប់ ដែលសាស្ត្រាចារ្យខាងភាសាខ្មែរ បង្រៀនថ្នាក់ប្រឡងប្រដែងនោះផ្ញើមកឲ្យ ពីគ្រប់ទិសទី នៃវិទ្យាល័យ អនុវិទ្យាល័យរបស់រាជការ ពោលគឺម្នាក់ៗផ្ញើមកក្រសួងសិក្សាធិការជាតិ តាមរយៈនាយចៅហ្វាយផ្ទាល់របស់ខ្លួន ដល់ទៅ ៣ វិញ្ញាសាខុស ៗ គ្នា ៗ ដូច្នេះ ការខុសឬត្រូវ ល្អឬអាក្រក់ សម ឬ ពុំសម ងាយ ឬ ពិបាក នោះគឺជាភារៈកិច្ចផ្ទាល់ របស់អស់លោក-អ្នកជាសាស្ត្រាចារ្យ គ្រូបាអាចារ្យ របស់សិស្សដែលជ្រើសរើសតម្រូវមកឲ្យក្រសួងសិក្សាធិការ ពិនិត្យយកសម្រេចតែមួយប៉ុណ្ណោះ ៗ ឃើញពុំមានគំនិតឬចិត្តចង់រិះគន់ ប្រៀនប្រដៅ ឬរំឭកដល់សម្បជញ្ញៈ នឹងសមត្ថកិច្ចរបស់អស់លោក-អ្នកជាគ្រូបាអាចារ្យនោះឡើយ ព្រោះថាម្នាក់ ៗ សុទ្ធតែមានសមត្ថភាពចំណេះវិជ្ជា ការពិសោធន៍ចំណេះខ្លួន នឹងការអនុវត្តប្រៀនប្រដៅ បង្រៀនសិស្ស

ឲ្យចេះដឹងសព្វគ្រប់ទៅហើយ ។ គឺប៉ុន្តែយើងក៏នៅមានការស្តាយណាស់ដែរ ក្នុងការដែលអស់លោក-អ្នកជាគ្រូបា យកតែសមត្ថភាព បំណេះចេះដឹងរបស់ផងខ្លួន និងការបង្រៀនរបស់ខ្លួនមកប្រើជាមធ្យោបាយសម្រាប់តែបង្ហាញនូវកម្រិត នឹងកំពស់នៃបំណេះផ្ទាល់នោះ ឬយកការបង្រៀនចំពោះតែសិស្សមួយសាលាទៅអនុវត្តលើអ្នកឯទៀតដែលចេះពុំដល់ ឬអ្នកដែលពុំបានបង្រៀនបែបនោះសោះ ដើម្បីដោះស្រាយឲ្យដូចសមត្ថភាពនិងការអនុវត្តរបស់ខ្លួន ។ ពោលដោយខ្លីទៅគឺថាការដាក់វិញ្ញាសាឲ្យបេក្ខជនធ្វើ គឺឲ្យសមទៅនឹងតម្រិះបញ្ញា ការចេះដឹងតាមកម្មវិធីរបស់ថ្នាក់គ្នានោះ នឹងមិនមែនដាក់ដើម្បីឲ្យគិតពុំចេញ ហួសបំណេះ ឬធ្វើពុំកើតជាក់ទទេៗនោះឡើយ ។

ជាច្រើនលើក នៃការប្រឡងមកហើយ យើងអាចចែកប្រធានតែងសេចក្តីនោមធ្យមសិក្សាតាមការខុសទំនងដូចតទៅ :

ឧទាហរណ៍ :

១– ប្រធានចោទសួរខ្វះទៅខ្លាំងពេក មិនប្រាកដជាចង់សួរពីអ្វីឲ្យច្បាស់ និយាយឲ្យត្រូវ មានឯកភាពពុំបាចហាច ហើយពិបាកដោះស្រាយឲ្យចុះសម្រុងគ្នា ។

២– ប្រធានងាយពេក ឬជួនកាលពិបាកពេក (ឧ. ប្រធានសំរាប់ប្រឡងថ្នាក់ទី ៣ ទំនើបទៅជាសួរហួសដល់ទៅសំរាប់ថ្នាក់ទីមួយទំនើបវិញ ឬ ប្រធានសំរាប់មធ្យមសិក្សាបត្រថ្នាក់ទី ១ សួរធូរងាយ មកត្រឹមតែកម្រិតបំណេះសិស្សទី ៣ ទំនើបវិញ) ។

៣– ប្រធានដែលផ្តេកទៅលើតែអក្សរសាស្ត្រ ឬរៀងខ្លាំងពេក ពោលគឺសួរដើម្បីឲ្យសូត្ររៀង ឬធ្វើសេចក្តីសង្ខេបរឿងឡើងវិញ ហើយដែលពុំមែនប្រាជ្ញាចង់ដឹងនូវការយល់ឃើញគំនិតបញ្ញា ឬការវ័យឆ្លាតរបស់បេក្ខជនសោះ ។

៤– ប្រធានដែលមានសភាព អរូបីយ ពោលគឺចោទតែបញ្ហាហួសហេតុផល ហើយដែលពុំមានទាក់ទងមកផលប្រយោជន៍ ឬបច្ចុប្បន្នព្រឹត្តិការណ៍ និងការប្រាកដប្រជានៃហេតុកេទ ឬបំណេះវិជ្ជាណាមួយ ក្នុងកម្មវិធីថ្នាក់ជាមួយគ្នានោះឡើយ (ឧ. ប្រធានឲ្យមានបែបជាប្រាកដនិយមវិទ្យាសាស្ត្រនិយម នឹងមានប្រយោជន៍) ។ ចំពោះសរសេរតាមសូត្រក៏ដូច្នោះដែរ ។ ប្រធានទាំងឡាយដែលបានឲ្យក្នុងការប្រឡងមធ្យមសិក្សា

ប័ត្រមកហើយ ច្រើនមានទង្គង់អន់ខ្លះៗ ដូចជា:

១– អត្ថបទវែងពេក ឬខ្លីពេក, ពិបាកពេក (មានពាក្យថ្មីៗ ក្នុងគណៈកម្មការវប្បធម៌បានប្រែ ពាក្យបាលី ឬ សំស្ក្រឹតច្រើន), ឬ ងាយពេក (ព្រោះមានតែពាក្យងាយៗ សរសេរពុំខុសសោះ) ។

២– អត្ថបទដកស្រង់ពីសៀវភៅអនុពាក្យខ្លះ ដែលជួនកាលគ្មានខ្លឹមសារគ្មានប្រយោជន៍អ្វីសោះ ចំពោះសតិបញ្ញា នឹងការអប់រំសតិស្មារតីសិស្ស (គឺដែលពោរពេញតែទៅដោយពាក្យពិបាកៗ សរសេរពុំកើត ស្តាប់ពុំបាន មើលពុំយល់) ។

៣– ពាក្យសួរដែលគ្មានទាក់ទងនឹងអត្ថបទនោះ (ពោលគឺពុំសួរគោលគំនិត គោលមតិក្នុងរឿងនោះ ទៅជាសួរឯណាក្រៅវិញ) ឬមួយបើសួរវេយ្យាករណ៍ក៏ចូលចិត្តឲ្យតែសូត្រមេរៀន;ដាក់មិនឲ្យរកឧទាហរណ៍ ក្នុងអត្ថបទមកពន្យល់បញ្ចាំងការយល់នឹងការចេះដឹងនោះ ឬសួរកន្លែងណាដែលខ្លួនឯងមិនទាំងចេះធ្វើ គិតមិនចេញផង ដូចជាធ្វើសម្ពន្ធពាក្យ ឬឃ្លាប្រយោគក្នុងវគ្គទាំងមូលណាមួយ ។

បើមានវិបត្តិ នឹងការមិនចុះសម្រុងយ៉ាងនេះហើយ តើគេទៅទៀត គប្បីយើងជ្រើសរើសតម្រូវប្រធានតែងសេចក្តី ឬវិញ្ញាសារសរសេរតាមសូត្រ បែបណាទៅវិញ ?

## ១– ចំពោះប្រធានតែងសេចក្តី :

ក) មុននឹងរើសប្រធាន គប្បីគិតថា:

–ប្រធានសម្រាប់ថ្នាក់ណា (ទី ៣ ឬ ទី១ ?)

– ប្រធានសម្រាប់តែសិស្សរបស់ខ្លួនទេ ឬ សម្រាប់សិស្សទូទៅធ្វើ ?

– ប្រធានបែបអក្សរសាស្ត្រ (ដោយចោទសួរទៅលើរឿងក្នុងកម្មវិធីណាមួយ) ឬ ប្រធានទូទៅ (ជាសុភាសិត ឬ ពាក្យទំនៀម ឬ អំពីបញ្ហាណាមួយដែលមានប្រយោជន៍) ?

– ប្រធានគិតដោយបញ្ញារបស់ខ្លួនឯង ឬ យកពីក្នុងសៀវភៅរបស់នរណាមួយ ដែលទុកជាជាប្រសើរ ជាគ្រូប្រដៅយើងបាន ?

– ប្រធានថ្មី ឬដែលធ្លាប់ឲ្យសិស្សរបស់ខ្លួនធ្វើហើយ ឬដែលបម្រុងនឹងដាក់ឲ្យសិស្សខ្លួនធ្វើដើម្បីយកត្រូវតែឯង ?

ខ) រួចពីត្រិះរិះគោលគំនិតទាំងប៉ុន្មានខាងលើនេះហើយ ត្រូវរើសនឹងរៀបរៀងប្រធានឲ្យបានសមល្មមដូចតទៅ :

– បើប្រធានសម្រាប់ថ្នាក់ទី ៣ គប្បីបិតក្នុង

វង្វ័ន់សមត្ថភាពថ្នាក់ទី ៣, បើសម្រាប់ថ្នាក់ទី ១ គឺឲ្យសមនឹងកម្លាំងគម្រិះសិស្សថ្នាក់ទី ១ ;

– ប្រធានសម្រាប់សិស្សទូទៅនៃថ្នាក់ដូចគ្នា ពោលគឺកុំតម្រូវតែសិស្សរបស់ខ្លួន ហើយសំពប់ជាឧបសគ្គទម្លាក់សិស្សឯទៀត យកល្បីឈ្មោះតែឯងនោះ (សូមកុំភ្លេចថា ការប្រឡងមិនមែនជាការទម្លាក់បេក្ខជននោះឡើយ );

– បើប្រធានបែបអក្សរសាស្ត្រ :

ចំពោះថ្នាក់ទី ៣ គឺយករឿងដែលបានរៀនហើយពីថ្នាក់ទី ៦ មកទល់នឹងទី ៣ ។ ប្រធានដែលដោះស្រាយបញ្ហាទាក់ទងមកនឹងសង្គមមនុស្ស មិនមែនរៀបរាប់សង្ខេបនិយាយតែពីសេចក្ដី ឬដំណើររឿងប៉ុណ្ណោះឡើយ ។

ចំពោះថ្នាក់ទី ១ គឺយករឿងទាំងឡាយដែលបានរៀនតាំងពីថ្នាក់ក្រោម ៗ មក គឺប្រធានបែបបញ្ហាដោះស្រាយភ្ជាប់មកនឹងជីវភាព បញ្ហានៃសង្គមជាតិតាមសម័យនិយម ប្រធានដោះស្រាយបែបទាក់ទងទៅនឹងធាតុទាំងបី នៃការពន្យល់រឿង គឺបញ្ហាអត្ថន័យ (ជំរៅឧត្តមគតិរឿង) បញ្ហាអត្ថរូប (របៀបតែងកាព្យឃ្លោង ពាក្យពេចន៍ ឃ្លោងឃ្លាប្រយោគ, វិធីតែងនិពន្ធវិធីបង្កើតរូបារម្មណ៍ផ្សេងៗ ឬរូបារម្មណ៍វិធីនេះឯង) ហើយនឹងបញ្ហាអត្ថរស (គឺលំអសោភ័ណភាពរបស់រឿង: ល្អដោយបង្ហាញការកំសត់ ទារុណភាព, នាដ្យភាព កំប្លែង អស្ចារ្យ ធម្មតា ឬអ្វីអាចហៅវិភយត្តភាព) ឬប្រធានដែលមានបញ្ហាប្រៀបធៀបគ្នា បែបរឿងប្រៀបធៀប ឬប្រធានចោទសួរអំពីគំនិតអរូបខ្លះ ទាក់ទងនឹងទស្សនវិជ្ជា សាសនា វប្បធម៌នឹងអារ្យធម៌ខ្មែរ ដូចជាបញ្ហាកម្មផល ពៀរពៅ បាប បុណ្យ កើតស្លាប់ ។ល។ . . .

– បើប្រធានទូទៅ គប្បីជ្រើសរើសឲ្យស្របទៅនឹងបញ្ហារបស់ប្រទេសជាតិ ដែលជាការអប់រំណែនាំសិស្ស ឲ្យស្គាល់នូវតម្លៃនៃអព្យាក្រឹតភាព សេដ្ឋកិច្ចជាតិ សិល្បៈ កីឡា ឧស្សាហកម្ម ការហត្ថកម្ម កសិកម្ម ជាដើម ។ល។ ឬបើជាសុភាសិតក៏ឲ្យមានការលើកជាឧទាហរណ៍ពីក្នុងរឿងផ្សេងៗ ក្នុងកម្មវិធីមកបញ្ជាក់ផង ។

– ប្រធានគប្បីគិតរិះរក រៀបរឿងដោយបញ្ហា ការពិសោធន៍របស់ខ្លួនល្អជាជាងដកស្រង់ចម្លងពីក្នុងក្បួនខ្នាតកាយរង ព្រោះជាប្រធានមានមកហើយ រមែងនាំឲ្យមានការខ្វះយោបល់រាំងមេប្រយោគដែលខុសជាអ្នកពុំប្រើ ពុំឲ្យតម្លៃទៅលើ

សៀវភៅនោះៗទេ ឬមួយនាំឲ្យសិស្សគាបដក ស្រង់យកឯកសារទៅលួចចម្លង តាមមធ្យោបាយ មិនប្រសព្វរបស់ខ្លួន;

– ប្រធានដែលជ្រើសរើសហើយ ត្រូវទុកដាក់ឲ្យជិត កុំយកទៅលាតត្រដាងឲ្យសិស្សធ្វើ ឬដឹងមុន ព្រោះសុទ្ធតែជាឧបសគ្គ ហើយពុំគប្បីផង;

– ជ្រើសរើសហើយ ត្រូវថ្លឹងមើលដោយបញ្ញា គំនិតរបស់ខ្លួនថា តើសមត្ថភាព សិស្សថ្នាក់នោះៗ អាចធ្វើបានឬទេ ? តើខ្លួនឯងយល់ប្រធានរបស់ខ្លួនប្រាកដឬនៅ ? តើអាចពន្យល់នឹងដោះស្រាយបញ្ហាគោលបំណង របៀបផែនអត្ថាធិប្បាយប្រធាននោះ ដល់ក្រុមប្រយោគក្នុងការពិភាក្សាប្រធាននោះ ឲ្យមានឯកភាពច្បាស់លាស់ឬទេ ? (ពេលគឺកុំឲ្យរួចតែពីដៃហើយខ្លួនមិនដឹងជាចង់ថា ឬ ពន្យល់ដូចម្ដេចផង រួចដល់គេត្រូវការសួរឲ្យជួយដោះស្រាយលាក់មុខគេចខ្លួនចេញនោះ ជាកំហុស ទីធំគុណវិបត្តិធ្ងន់ណាស់, ។

សារុបសេចក្ដីទៅ :

ទោះជាប្រធានបែបអក្សរសាស្ត្រក្ដី ឬប្រធានទូទៅក្ដី ត្រូវតែងឲ្យខ្លីល្មម កុំវែងមិនប្រាកដសេចក្ដី កុំយកពាក្យពិបាកខ្លាំងៗ មកប្រើជាកិច្ច បំភាន់សតិ គំនិតចំណេះចេះដឹងរបស់សិស្ស ហើយជាប្រធានស្របនឹងលក្ខណៈប្រយោជន៍របស់ជាតិ តាមបែបប្រាកដនិយម វិទ្យាសាស្ត្រនិយមផង ។

## ២– បំពោះវិញ្ញាសាសរសេរតាមសូត្រ

ក)– មុននឹងរើស គប្បីគិតថា :

– រើសយកអត្ថបទ សម្រាប់ឲ្យសរសេរសុទ្ធតែត្រូវ ឬ ឲ្យសរសេរសុទ្ធតែខុស ឬ មួយឲ្យសិស្សចេះគិត យល់នឹងក្រេបជញ្ជក់នូវអត្ថន័យតម្លៃអត្ថបទនោះផង ?

– រើសយកអត្ថបទពីក្នុងសៀវភៅណាមួយ ឬ អត្ថបទរៀបរៀងដោយខ្លួនឯង ?

– រើសអត្ថបទឲ្យល្មមសរសេរតាមរយៈពេលដែលបក្ខជនត្រូវធ្វើ ឬ វែងអន្លាយ ?

– រើសអត្ថបទថ្មី ឬ អត្ថបទដែលធ្លាប់ឲ្យសិស្សធ្វើរួចទៅហើយ ?

– បំពោះសំនួរ ក៏ដូចគ្នាដែរ តើសួរពីអ្វី ? (បញ្ហាក្នុងអត្ថបទដែលទាក់ទងទៅនឹងចំណេះទូទៅរបស់សិស្សសម្រាប់ពិសោធមើលបញ្ញា ការចេះដឹង ឬ សួរកុំឲ្យឆ្លើយកើត ? សួរពីវេយ្យាករណ៍បែបណា ? បែបចេះតែម្នាក់គ្រូ ឬ តាមបែបក្បួន

ខ្នាត ដែលមានមកខ្លះហើយជាគោល) ?

១) ក្រោយការត្រិះរិះពិចារណា បែបនេះហើយ ទើបគ្រូសម្រេចដូចតទៅ :

— រើសអត្ថបទដែលមានពាក្យពិបាក ល្មមកុំឲ្យច្រើនពេក ដែលអាចឲ្យសិស្សគិតឃើញយល់បាន ចាប់សេចក្តីកើត ហើយទាក់ទងត្រឹមត្រូវទៅនឹងរបៀបប្រើផង ;

— បើអត្ថបទចាស់ តើយកអត្ថបទបែបអ្នកនិពន្ធណា ? (ពោលគួរយកអត្ថបទតែពាក្យរាយ) អត្ថបទរបស់អ្នកនិពន្ធដ៏ល្បី ៗ ឈ្មោះ ឬ អត្ថបទរាយរងដែលអ្នកនិពន្ធសម័យថ្មីគេចង់ក្រងបោះប្រញាប់លក់យកប្រាក់ចាយ ?

បើគួរ គប្បីសាស្ត្រាចារ្យទំសម្រាំងអត្ថបទពីប្រធានណាមួយឲ្យល្អដោយខ្លួនឯងវិញ (ព្រោះថាយើងខ្វះអត្ថបទសំរាប់ការអាន នឹងសិក្សាតម្រូវតាមសតិបញ្ញាការអប់រំសិស្សច្រើនណាស់) ។

— រើសអត្ថបទឲ្យល្មមពេលវេលា ដែលអាចសរសេរចប់ក្នុង ៤៥ នាទី កុំលោភវែងពេក ។

— រើសអត្ថបទថ្មី ដែលពុំទាន់ឲ្យសិស្សធ្វើនៅឡើយ ហើយជាអត្ថបទក្រៅពីក្បួនខ្នាតលក់រាយរង (ជាការចៀសវាងដល់សិស្សដែលយកក្បួនខ្នាត ឬ ប្រធាននោះទៅទុកលួចចម្លង) ។

— ឃ្លាប្រយោគ ត្រូវគោរពវេយ្យាករណ៍ កុំចេះតែប្រើពាក្យតាមតែដក់មាត់ . . . ។

— ចំពោះសំនួរ គួរសួរដូចតទៅ :

សំនួរទី ១ អំពីប្រធានទាក់ទងទៅនឹងគំនិតឧត្តមគតិនៃអត្ថបទ ;

សំនួរទី ២ អំពីប្រធានទាក់ទងទៅនឹងអត្ថបទដោយប្រៀបធៀបទៅនឹងបញ្ហាផ្សេងៗក្នុងបច្ចុប្បន្នតាមការចេះដឹងទូទៅរបស់សិស្ស ;

សំនួរទី ៣ អំពីវេយ្យាករណ៍ មានការធ្វើសម្ពន្ធពាក្យ ក្នុងឃ្លា ឬ ពន្យល់រកឧទាហរណ៍តាមបញ្ញាក្នុងវិធានណាមួយ ។

រួមសេចក្តីទាំងអស់មក គឺថា ប្រសិនបើយើងចេះឲ្យប្រធានសមប្រកបដល់សតិបញ្ញា ស្មារតី នឹងការចេះដឹង សមត្ថភាពរបស់សិស្ស នោះពិតជាប្រធានយើងនឹងមានតម្លៃ ហើយលទ្ធផលរបស់បេក្ខជន ក៏នឹងសមប្រកបដោយចំណេះចេះដឹងសព្វគ្រប់មែន ៗ ពិសេសក្នុងការតែងក្តី ឬ ក្នុងការពិភាក្សាក្តី យើងនឹងរកបាននូវបរិយាកាសរីករាយនឹងគ្មានឧបសគ្គអ្វី ឬ ការរំខានដោយប្រការណាមួយឡើយ ។

# ប្រវត្តិសាស្ត្រនឹងកាលប្រវត្តិវិជ្ជា

ចន្ទ-ឌិត្យ
សាស្ត្រាចារ្យប្រវត្តិសាស្ត្រ, ភូមិសាស្ត្រ
នៅវិទ្យាល័យសង្គមរាស្ត្រនិយម

## សញ្ញាណទូទៅនៃកាលប្រវត្តិវិជ្ជា

### ក.– អត្ថន័យនឹងការទាក់ទងរវាងប្រវត្តិសាស្ត្រនឹងកាលប្រវត្តិវិជ្ជា

ប្រវត្តិសាស្ត្រគឺជារឿងរ៉ាវ ហេតុភេទ ព្រឹត្តិការណ៍ផ្សេងៗ ឬរបៀបរៀបរបស់នៅក្នុងអតីតកាលនៃមនុស្សជាតិ ។ សរសេរប្រវត្តិសាស្ត្រប្រទេសកម្ពុជា ឧទាហរណ៍ អំពីរជ្ជកាលព្រះបាទយសោវរ្ម័នជាដើម បានន័យថា គេត្រូវរៀបរាប់ថាតើក្នុងរជ្ជកាលនោះ ខ្មែររស់នៅរបៀបណា ចិញ្ចឹមជីវិតរបៀបណា ស្លៀកពាក់របៀបណា មានទីលំនៅរបៀបណា ធ្វើស្រែចំការរបៀបណា ។ គេត្រូវៈរៀបរាប់ថែមទៀត នូវគំនិត ឧត្តមគតិ ដូចជាសាសនា និងលក្ខណៈនៃពុទ្ធិ ។ គេត្រូវកត់ត្រាទុកដែរ នូវស្នាដៃសំខាន់ ៗ នៃអ្នកនិពន្ធ ឬសិល្បករ ដែលបានធ្វើឲ្យរជ្ជកាលនោះបានប្រសើររុងរឿង ហើយគេត្រូវពណ៌នា អំពីការដឹកនាំនិងរៀបចំប្រទេស ។ ទាំងអស់នេះជាផ្នែកមួយនៃប្រវត្តិសាស្ត្រ ដែលមានឈ្មោះហៅថា ប្រវត្តិសាស្ត្រអារ្យធម៌ ។

ក្នុងផ្នែកមួយទៀតនៃរជ្ជកាលនោះ គេឃើញព្រឹត្តិការណ៍ខ្លះ ដែលញុំាងការទាក់ទងរវាងមនុស្សនឹងមនុស្ស ឲ្យប្លែកពីធម្មតា ។ ឧទាហរណ៍ ដូចជា មានចំបាំងរវាងប្រទេសខ្មែរ នឹងប្រទេសឯទៀតៗ ដែលធ្វើឲ្យព្រះបាទយសោវរ្ម័ន លាតសន្ធឹងអធិរាជាណាចក្ររបស់ព្រះអង្គ យ៉ាងធំទូលាយក្នុងអាស៊ីភាគអគ្នេយ៍ ។ នេះគឺជា ប្រវត្តិសាស្ត្រព្រឹត្តិការណ៍ ។

ដូច្នេះ ប្រវត្តិសាស្ត្រគឺជាការរៀបរាប់ព្រឹត្តិការណ៍ ឬ តាកង់ទំនៀមទម្លាប់នៃអតីតកាល ។ ប៉ុន្តែប្រសិនជាគេឡើងទៅឆ្ងាយក្នុងអតីតកាល គេឃើញតែសំណេះសំណាល់បន្តិចបន្តួច នៃអារ្យធម៌ ដូចជាក្នុងអារ្យធម៌មេមត់ ប្រហែល ១៥០០ មុន គ.ស. គេឃើញតែអំបែងចាន-ឆ្នាំង ឬពាង និងពូថៅតូច ៗ ដែលធ្វើអំពីថ្ម ។ ដូច្នេះ ប្រវត្តិសាស្ត្រព្រឹត្តិការណ៍ ក៏ពុំអាចកើតឡើងបានដែរ ។ អតីតកាលដ៏វែងឆ្ងាយនេះ គឺជាកម្មសិទ្ធរបស់បុព្វប្រវត្តិសាស្ត្រ ។

ប៉ុន្តែដើម្បីយល់នូវប្រវត្តិសាស្ត្រ ឬ ដើម្បីប្រៀបធៀបព្រឹត្តិការណ៍មួយទៅនឹងព្រឹត្តិការណ៍មួយទៀត គេត្រូវដឹងពេលវេលា ឬកាលបរិច្ឆេទនៃព្រឹត្តិការណ៍នោះជាដាច់ខាត ។ ដូច្នេះប្រវត្តិសាស្ត្រ ក៏ត្រូវការកាលប្រវត្តិវិជ្ជាជាដាច់ខាតដែរ ពីព្រោះកាលប្រវត្តិវិជ្ជា ជាវិជ្ជាដែលបង្រៀនយើងអំពីការបែកពេលវេលា ឬការដាក់កាលបរិច្ឆេទ ។

## ១.– សករាជ

ដើម្បីធ្វើកាលប្រវត្តិវិជ្ជា ឬ ដើម្បីរាប់កាលបរិច្ឆេទ គេត្រូវជ្រើសរើសចំណុចដើមមួយ ។ ឧទាហរណ៍: អ្នកមានអាយុ ១១ ឆ្នាំ បានសេចក្តីថា តាំងពីអ្នកកើតមកអ្នករស់បាន ១១ ឆ្នាំ ឬគេរាប់បាន ១១ ឆ្នាំហើយ ។ ថ្ងៃកំណើតរបស់អ្នក ជាចំណុចដើម ដើម្បីរាប់អាយុរបស់អ្នក ជាចំណុចដើមនៃព្រឹត្តិការណ៍ទាំងឡាយ ដែលមានចំពោះអ្នក ពោលគឺជាប្រភពនៃប្រវត្តិសាស្ត្ររបស់អ្នក ។ ឯចំណុចដើមនេះ គេច្រើនតែជ្រើសរើសព្រឹត្តិការណ៍ណាដែលពិសេស ហើយសំខាន់ជាងគេក្នុងប្រវត្តិសាស្ត្រ ។

នៅបស្ចិមប្រទេស គេយកកំណើតយេស៊ូគ្រីស្ត ដែលជាដើមកំណើតនៃគ្រិស្តសករាជ (គ.ស.) ។ កាលណាអ្នកថា ឆ្នាំ "១៩៦២" ត្រង់នេះបានន័យថា តាំងពីយេស៊ូគ្រីស្តកើតមក គេរាប់បាន ១៩៦២ ឆ្នាំហើយ ។

នៅមានសករាជច្រើនទៀត ដូចជា ពុទ្ធសករាជ (ព.ស.) ដែលរាប់តាំងពីព្រះពុទ្ធចូលនិព្វាន គឺប្រហែលក្នុងឆ្នាំ ៥៤៣ មុន គ.ស. ។

អុិស្លាមសករាជ (អ.ស ) រាប់ពីថ្ងៃ ១៦ កក្កដា ៦២២ ក្រោយគ្រិស្តសករាជ ថ្ងៃដែលសាវ័ក ម៉ាហូម៉ាត រត់ពីក្រុងឡាមុក្កទៅម៉េឌីន ។

ជនជាតិក្រិក ដែលលង់ក្នុងកីឡា អូឡាំពិក ដល់ធ្វើរាល់ ៤ ឆ្នាំ ក៏រាប់ជាចតុវត្ស (៤ ឆ្នាំរាប់មួយ)

ដោយយកជាចំណុចដើម នូវឆ្នាំបើកកីឡាអូឡាំពិក ដំបូងបំផុត គឺគង់ឆ្នាំ៧៧៦ មុន គ.ស. ។

សកកាជ ចិន ឥណ្ឌា អេស៊ីប ឬមេសូប៉ូតាមី ផ្លាស់ប្ដូរតាមរាជាភិសេក ។ រជ្ជកាលថ្មីមួយ ជាដើមនៃសកកាជថ្មីមួយ ។

ដូច្នេះ សកកាជ គឺជាចំនួនឆ្នាំដែលគេរាប់បន្តបន្ទាប់គ្នារដឹកមិនដាច់ ចាប់តាំងពីចំណុចដើមមួយ ដែលគេជ្រើសរើសជាមុន ។

## គ.– មាត្រដ្ឋានៃពេលវេលា

កាលបរិច្ឆេទពេញលេញ ហើយច្បាស់លាស់ ត្រូវប្រាប់យើង ពីថ្ងៃ ខែ និងឆ្នាំ ។

១. បវេសនកាល ឆ្នាំសិក្សា១៩៦២-៦៣ ត្រូវធ្វើនៅថ្ងៃ២ កក្កដា ១៩៦២ ។

– តាមភូមិសាស្ត្រ ១ ឆ្នាំមាន ៣៦៥ ថ្ងៃ ៥ ម៉ោង ៤៩ នាទី ។

– ១ សតវត្ស មាន ១០០ ឆ្នាំ ។ សតវត្ស I (ត្រូវមើលថាទី ១) នៃពុទ្ធសកកាជ រាប់តាំងពីឆ្នាំ ១ ដល់ ១០០ រាប់បញ្ចូល ។ សតវត្ស II ពីឆ្នាំ ១០១ ដល់ ២០០ ។

– លើសពីសតវត្សទៅទៀត គេច្រើនរាប់ជា ១០ សតវត្ស ជា ២០ សតវត្ស ។ល។

ដើម្បីសំគាល់សម័យណាមួយ ដែលកន្លងទៅហើយ គេច្រើនប្រើពាក្យ ពុំសូវច្បាស់លាស់ ដូចជាកាល វេលា រដូវ ឬគ្រា ។

«ជំនាន់» គឺជាកាលមួយៗ ប្រកបទៅដោយរបៀបរបបរស់នៅមួយបែប ឬ ដោយគំរូសិល្បៈពិសេស ។

តាមអត្ថបដិរូប ពាក្យសតវត្ស សំដៅយកសម័យកាលណាមួយ ដែលប្រទេសប្រកបទៅដោយសេចក្ដីរុងរឿង ក្រោមអ្នកដឹកនាំម្នាក់ដ៏ប្រសើរ ។

ឧ:– "សតវត្សយសោវរ្ម័ន"

– "សតវត្សជ័យវរ្ម័ន VII (ទី៧)

# អំពីការចែកប្រវត្តិសាស្ត្រជាកាល

## ក.– ឯកសារប្រវត្តិសាស្ត្រ

ប្រវត្តិសាស្ត្រត្រូវការឯកសារ គឺរបស់អ្វីៗទាំងអស់ ដែលធ្វើឲ្យយើងដឹង ស្គាល់ យល់អំពីអតីតកាល ដូចជាប្រាសាទ ស្នាដៃសិល្បៈ ប្រដាប់ការងារ សំលៀកបំពាក់ ។ល។ ប៉ុន្តែពិសេសជាងនេះទៅទៀត អ្នកប្រវត្តិសាស្ត្រត្រូវការឯកសារលាយលក្ខអក្សរ ។ បើគ្មានឯកសារលាយលក្ខអក្សរ ប្រវត្តិសាស្ត្រក៏គ្មានដែរ ។

យើងពុំសូវដឹងអ្វីច្រើនទេអំពីអារ្យធម៌ណាដែលគ្មានឯកសារលាយលក្សអក្សរ ។ ឧទាហរណ៍ដូចជាអារ្យធម៌ឥណ្ឌូស ។

ប៉ុន្តែការមានឯកសារលាយលក្សអក្សរនេះ ពុំគ្រប់គ្រាន់ទេ សំខាន់បំផុតគេត្រូវចេះអាន ហើយយល់នូវឯកសារ ទាំងនោះ ។ គេស្គាល់ប្រវត្តិសាស្ត្រអេស៊ីបច្បាស់ ក្នុងពេលដែលអ្នកប្រាជ្ញចេះអានសិលាចារឹកទាំងឡាយ ក្នុងឆ្នាំ ១៨២២ ។

## ខ.– ប្រវត្តិសាស្ត្រនិងបុព្វប្រវត្តិ

មនុស្សចូលក្នុងប្រវត្តិសាស្ត្រ ក្នុងពេលដែលរកអក្សរឃើញ (មិនលើសពី ៤០០០ ឆ្នាំ មុនគ.ស. នេះ) ។ ដូច្នេះ បុព្វប្រវត្តិសាស្ត្រ លាតសន្ធឹងអស់ពេលតិចឬច្រើន តាមជនជាតិនិមួយ ១ ។ ជនជាតិដែលចូលប្រវត្តិសាស្ត្រមុនគេ គឺអេស៊ីប និងកាល់ដេនៅមេសូប៉ូតាមី ។ ក្នុងឆ្នាំ ១៥០០ មុន គ.ស. (អារ្យធម៌មេមត់) ប្រទេសយើងរស់នៅក្នុងបុព្វប្រវត្តិសាស្ត្រនៅឡើយ ។

អតីតកាលដ៏វែងឆ្ងាយនៃមនុស្ស ដែលយើងអាចស្គាល់បាន ដោយឯកសារគ្មានលាយលក្សអក្សរ ដូចជាអំបែងចាន- ឆ្នាំង ក្អម ដែលកប់ក្នុងដី ឬ ក្នុងគុហា ឆ្អឹង ប្រដាប់ប្រដារ អាវុធផ្សេង ១ មានឈ្មោះហៅថា បុព្វប្រវត្តិសាស្ត្រ ។

## គ.– កាលធំ ៗ នៃប្រវត្តិសាស្ត្រ

ដើម្បីឲ្យងាយក្នុងការសិក្សាប្រវត្តិសាស្ត្រ ឬ ដោយលៃទៅតាមឯកសារតិច ឬ ច្រើនតាមព្រឹត្តិការណ៍នៃប្រវត្តិសាស្ត្រ (ដូចជាចំបាំងធ្វើឲ្យឯកសារបាត់បង់) នៅបស្ចិមប្រទេស គេបានចែកប្រវត្តិសាស្ត្រជាកាលដូចតទៅនេះ ៖

- បុរាណកាល រាប់តាំងពីមនុស្សចូលប្រវត្តិសាស្ត្រ មកដល់ចុងសតវត្ស IV ដែលអធិរាជាណាចក្ររ៉ូមត្រូវរលាយ ក្រោមការពតត្បាតនៃអនារ្យករ ។

– មធ្យមកាល រាប់តាំងពីសតវត្ស V មកដល់សតវត្ស XV ដែលសង្ក្រាក់នាភពរ បានរីកចំរើន ហើយដែលពួកទួរក់ យកបានក្រុងគុស្តង់ប៊ូល (១៤៥៣) ។

– កាលថ្មី ចប់នៅឆ្នាំ ១៧៨៩ ឆ្នាំមហាបដិវត្តន៍នៅប្រទេសបារាំង ។

– កាលឥឡូវ ពី ១៧៨៩ មកដល់សព្វថ្ងៃ ។

ការចែកប្រវត្តិសាស្ត្របៀបនេះ គ្មានអត្ថប្រយោជន៍អ្វី ឬ គ្មានការទាក់ទងអ្វីដល់អាស៊ីអាគ្នេយ៍ ជាពិសេសចំពោះប្រទេសយើងទេ ។

បើគិតតាមប្រទេសយើងវិញ ។

— បុរាណកាល រាប់តាំងពីប្រទេសយើងចូលប្រវត្តិសាស្ត្រ មកដល់ការបែករាជាណាចក្រខ្មែរជាប្រទេសចិនឡា (ប្រហែល ៧១០ នៃគ.ស.);

— មជ្ឈិមកាល រាប់តាំងពីព្រះបាទជ័យវរ្ម័ន II បានធ្វើឯកភាពនៃប្រទេសខ្មែរឡើងវិញ (៨០២) ពោលគឺដើមអធិរាជាណាចក្រខ្មែរអង្គរ មកដល់ការបាក់បោលអង្គរ (១៤៣២);

— កាលថ្មី រាប់តាំងពីព្រះបាទពញាយ៉ាត ទ្រង់យករាជធានីមកដាក់នៅភ្នំពេញ (១៤៣២) មកដល់ទីវង្គតនៃព្រះករុណាព្រះអង្គឌួង (១៨៥៩);

— កាលឥឡូវ ដើមរជ្ជកាលព្រះបាទនរោត្តម មកដល់សព្វថ្ងៃ ។

សេចក្ដីសង្កេត.— សព្វថ្ងៃនេះ ចាប់តាំងពីមជ្ឈិមកាលមក គេច្រើនចែកប្រវត្តិសាស្ត្រជាសតវត្ស ។


—បណ្ណាគារ ប៊ុត នាង, លេខ ១៧៦ វិថីខេមរភូមិន្ទ, ភ្នំពេញ

—បណ្ណាគារ ហ៊ុង យូ, លេខ ៤ វិថីចន្ទរាជា, ភ្នំពេញ

—បណ្ណាគារ ដួង ដួណារី លេខ ២២២ វិថីខេមរភូមិន្ទ, ភ្នំពេញ

—បណ្ណាគារខ្មែរ លេខ ១២៣ E មហាវិថីព្រះសីហនុ ភ្នំពេញ នឹងមានសេចក្ដីរីករាយទឹងចុះថ្លៃ ១០% ដល់បណ្ដាមិត្ត

**ដំណឹងអនុគ្រោះ**

សាស្ត្រាចារ្យយើង ដែលទៅទិញសៀវភៅសិក្សានៅបណ្ណាគារទាំងនេះ ហើយដែលបានបង្ហាញប័ណ្ណសមាជិកសមាគមយើងផង ។

ម្យ៉ាងទៀត បើមិត្តត្រូវការបញ្ញើទិញសៀវភៅអ្វី តិចឬច្រើននៅបារាំង មិត្តក៏អាចនឹងទិញតាមរយៈបណ្ណាគារ ហ៊ុង យូ បានដែរ ។

# ការពិសោធន៍ ខាងមុខវិជ្ជាខ្លះ សរសេរតាមសូត្រ (អនុវាក្យ) ខ្មែរ

ខេង-ធុង
និស្សិត-សាស្ត្រាចារ្យឆ្នាំទី ២

•

ខ្ញុំតែងឮមិត្តខ្លះត្អូញត្អែរថា មុខវិជ្ជាសរសេរតាមសូត្រខ្មែរជា វិជ្ជាមួយដែលពិបាកអនុវត្តចំពោះសិស្សឲ្យបានលទ្ធផលជាទីគាប់ចិត្តណាស់ ។ ចំពោះមតិផ្ទាល់ខ្លួន ក៏យល់ឃើញយ៉ាងដូច្នេះដែរ ព្រោះខ្ញុំតែងសង្កេតឃើញមានឧបសគ្គច្រើនបែបច្រើនយ៉ាងណាស់នៅក្នុងការបង្រៀនសរសេរតាមសូត្រម្ដងៗ ។ ឧបសគ្គទាំងនោះមាន ៖

ក) ពាក្យខ្មែរខ្លះពិបាកចំណាំណាស់: ចំពោះអក្ខរាវិរុទ្ធជាពិសេស គឺពាក្យដែលប្រកប ឬ គ្មានប្រកបនឹង "រ" ។

ខ) វេយ្យាករណ៍ខ្មែរយើងមិនសូវសម្បូរក្បួនខ្នាតខាងការសរសេរពាក្យត្រឹមត្រូវច្បាស់លាស់ដែរ ។

គ) នៅក្នុងផ្លាក ឬ យ៉េហោ តាមមន្ទីរផ្សេងៗ និងគ្រឹះស្ថានពាណិជ្ជកម្ម ដែលច្រើនសរសេរជាអក្សរមូលបេទាយ៉ាងស្អាតហើយធំៗផងនោះ យើងតែងប្រទះឃើញមានពាក្យខុសខ្លះនឹងអក្ខរាវិរុទ្ធ ។ ម្ល៉ោះហើយតែកាលណាសិស្សចេញពីសាលាទៅតែងប្រទះនូវពាក្យខុសនោះៗ គ្នាក៏ចងចាំទុកក្នុងខួរក្បាលនូវពាក្យខុសនោះជាប់ (តែឥឡូវ ឃើញបានត្រឹមត្រូវជាងមុនច្រើនហើយ) ។

ឃ) សិស្សភាគច្រើន ពុំសូវយកចិត្តទុកដាក់ខាងអក្ខរាវិរុទ្ធទេ ម្ល៉ោះហើយនាំឲ្យស្ទាក់ស្ទើរក្នុងការសរសេរពាក្យនីមួយៗ ។ គ្នាមានធុញទ្រាន់ក្នុងការសរសេរតាមសូត្រនេះម្ដងៗ ។

អាស្រ័យហេតុនេះ ដើម្បីឲ្យការបង្រៀនសរសេរតាមសូត្រប្រព្រឹត្តទៅបានស្រួល ហើយ

•

សិស្សក៏បានទទួលលទ្ធផលបង្គួរផងនោះ ខ្ញុំបានប្រើនូវមធ្យោបាយដូចខាងក្រោមនេះ ៖

១- ជាការធម្មតា ដើម្បីឲ្យសិស្សចេះសរសេរពាក្យនិមួយ ៗ បានត្រឹមត្រូវ គប្បីរំលឹកឲ្យហាត់ចំណាំអក្ខរាវិរុទ្ធរបស់ពាក្យនោះ ដោយសរសេរជាច្រើនផង ។

២- តែការចំណាំនេះ ជួនកាលក៏មិនសម្រេចដែរ ដោយពាក្យច្រើនពេក នាំឲ្យមានការភ្លេចភាំងខ្លះទៅ ។ ហេតុដូច្នេះ ត្រូវបង្គាប់សិស្សឲ្យចេះធ្វើការសំគាល់ផ្ទាល់ខ្លួនផង (remarques personnelles, ។

ឧ.- ពាក្យស្មើរ និងពាក្យស្មើ យើងគួរចំណាំរបៀបនេះ ៖

ចំពោះពាក្យ ស្មើរ គឺជាបើស្មើរ គឺខ្លះត្រូវតែទំរកមកបន្ថែមទៀត ហេតុដូច្នេះត្រូវតែដាក់ „រ"

ឯពាក្យ ស្មើ វិញ គឺជាបើរាល្មមសមរម្យ ហើយ មិនបាច់យកអ្វីមកបន្ថែមទៀតទេ ហេតុនេះគ្មាន "រ„ ទេ ។

- ពាក្យសុចរិត និងពាក្យទុច្ចរិត

មនុស្ស សុចរិត ជាមនុស្សត្រឹមត្រូវ មិនប្រព្រឹត្តអំពើពាលកម្ម ហេតុដូច្នេះ មិនបាច់ដាក់ជើង "ច„ ទៀតឡើយ ។

ឯពាក្យ ទុច្ចរិត ត្រូវតែមានជើង "ច„ ថែមទៀត ព្រោះមនុស្សទុច្ចរិត ជាពាលសាមាន្យ ។

- ពាក្យ រង៉ា គ្មាន "រ„ នៅខាងមុខទេ ព្រោះយើង រង៉ា ក៏ដោយសារយើងនៅខ្លួនទទេ គ្មានអ្វីដណ្ដប់ គ្មានអ្វីនៅជិត ឲ្យកក់ក្ដៅ ។

៣- ត្រូវពន្យល់ក្បួនវេយ្យាករណ៍ណាដែលទាក់ទងខាងអក្ខរាវិរុទ្ធ ឲ្យបានយល់ច្បាស់ដល់សិស្ស ដូចជាវិធីប្រើវណ្ណយុត្តផ្សេងៗ ជាពិសេស "រស្សសញ្ញា ( ់ ), មូសិកទន្ត ( " ), ត្រីស័ព្ទ ( ៊ ) ។ល។

៤- ទំលាប់សិស្សឲ្យចេះបំបែកពាក្យសមាសនាមទាំងឡាយ ដើម្បីឲ្យស្គាល់ឫសគល់នៃពាក្យច្បាស់លាស់ ។

ឧ. សុន្ទរកថា = សុន្ទរ (ពីរោះ)+ កថា (ពាក្យ, សំដី) ៖ ពាក្យពីរោះ

- បេសកកម្ម = បេសក (ការផ្ញើ)+ កម្ម (អំពើ)

- ឧបទ្ទវន្តរាយ = ឧបទ្រព+(ចង្រៃ)+អន្តរាយ (វិនាស)

- រហស្សុបាយ = រហស្ស (សំងាត់)+ ឧបាយ (កលល្បិច)

- អយស្ម័យយាន = អយស្ម័យ (ដែលធ្វើដោយដែក, + យាន (ជំនិះ) ។ល។

ការទំលាប់បំបែកដូច្នេះ មានប្រយោជន៍ល្អណាស់ ។ លុះសិស្សត្រូវសរសេរពាក្យដដែលនោះឡើងវិញ ទើបមិនសរសេរពាក្យបេសកកម្ម ដោយភ្ជាប់ "ក" (កណ្ដាល), ឧបទ្ទវន្តរាយ ដោយដាក់ជើង ្រ ឬ ភ្ជាប់ជើង "ន", សុន្ទរកថាជា សន្ទរកថា ឡើយ ។

៥- ទំលាប់សិស្សឲ្យចំណាំពាក្យណាជាពាក្យបាលី ពាក្យណាជាពាក្យសំស្ក្រឹតផង ដូចះ៖ ផលកុសល លាមក បណ្ដាជន ។ល។ ដែលមិនត្រូវទទួល រស្សសញ្ញា(់) ឡើយ ហើយឲ្យស្គាល់លិង្គក្នុងភាសាបាលីផង ដូចពាក្យឧបាសិកា សមាជិកា យាចិកា ទារកា ។ល។ ជានាមឥត្ថីលិង្គ គូគ្នានឹងនាមបុំលិង្គ ឧបាសក សមាជិក យាចក ទារក ហេតុដូច្នេះមិនត្រូវប្រកបនឹង "រ" ទៀតទេ ។

៦- មានពាក្យខ្លះ យើងអាចទំលាប់សិស្សឲ្យហាត់ចំណាំដោយសេចក្ដីខ្លីៗ នៃរឿងព្រេងបាន ដូចជាពាក្យ ៖

ពោធិ៍សាត់ (ខែត្រ) ។ រឿងព្រេងបុរាណដំណាលថា មានដើមពោធិ៍តូចមួយរសាត់ច្រាស់ទឹកមក ជាអស្ចារ្យប្លែក, គេបានស្រង់យកទៅដាំនៅទីមួយ ។ ដោយហេតុនេះ ទើបឲ្យឈ្មោះភូមិប្រទេសនោះថា ពោធិ៍សាត់; លុះចំណេរកាលយូរមកក៏ក្លាយជា ពោធិ៍សាត់ ។

បាត់ដំបង ។ តាដំបងក្រញូង គាត់បោលដំបងមួយ បាត់រកមិនឃើញ ។ ត្រង់តំបន់នោះទើបគេឲ្យឈ្មោះភូមិប្រទេសនោះថា បាត់ដំបង ។

៧- ឲ្យសិស្សទន្ទេញកម្រងពាក្យខ្លះ ដែលមានរបៀបសរសេរប្រហែលគ្នា ។

១.- ចិត្ដ ចិត្ដ ចិត្រ ចេត្ដា (មិនសរសេរនឹង "ឋ" ទេ)

-សន្តាន សន្តោស ចិន្តា ចេតនា និរន្តរ អន្តរធាន វេស្សន្តរ (មិនសរសេរនឹង "ណ" ទេថ្វីដ្បិតតែ "ន្ត" នៅក្នុងវគ្គជាមួយនឹង "ណ" ក៏ដោយ ។

៨- ឲ្យសិស្សទំលាប់ចំណាំព្យញ្ជនៈណា តែងផ្ញើជើងនឹងព្យញ្ជនៈណាផង ។

១.- ជើង "ង" ត្រូវផ្ញើជាមួយព្យញ្ជនៈ

“ភ„ ជាដកប ដូចពាក្យ ភ្លាប់ ភ្លិត ភ្លើញ ភ្លូរ ភ្លាំ ភ្លុំ ។

— ជើង ល “្ល„ ផ្ញើនឹងអក្សរ “ផ„ ដូចពាក្យ បំផ្លិចបំផ្លាញ ផ្លេកបន្ទោរ ផ្លែឈើ ណេកតផ្លោះ, ផ្លែសរ ។ ល ។ លើកលែងតែពាក្យខ្លះ ដូច ពោរប្លន់ តុកកំប្លែង ប្លែក ។ល។

— ជើង ប “្ប„ ផ្ញើជាមួយព្យញ្ជនៈ “ត„ មិនដែលផ្ញើជាមួយព្យញ្ជនៈ “ថ„ ទេ ដូចពាក្យ ខាងត្បូង ត្បូងខ្នើយ ត្បាញសំពត់ ត្បាល់កិន ត្បូងចិញ្ចៀន ត្បិតត្បៀត ។ល។ នៅមានការចំណាំរបៀបនេះច្រើនទៀត ។

សូមមិត្តមេត្តាជួយស្រាវជ្រាវផងចុះ ។

ម្យ៉ាងទៀត នៅពេលសរសេរតាមសូត្របើមិត្តមិនចង់យកអត្ថបទទាំងមូលមកហៅឲ្យសិស្សសរសេរតាមទេ មិត្តគ្រាន់តែដកស្រង់យកពាក្យពិបាកៗខ្លះ មកឲ្យសិស្សសរសេរលើក្ដារខៀនម្ដងម្នាក់ ៗ មួយម៉ាត់ ឬ ពីរម៉ាត់ ឬ សរសេររួចឲ្យសិស្សដដែលនោះពន្យល់ន័យរបស់ពាក្យនោះផង ។ លុះសិស្សនោះសរសេរនិងពន្យល់ពាក្យលើក្ដារខៀនរួចហើយ សូមមិត្តសួរឲ្យសិស្សឯទៀត កែឡើងវិញ ប្រសិនជាមានខុសអក្ខរាវិរុទ្ធ ឬ ពន្យល់ន័យមិនបានសមរម្យ ។ រួចហៅម្នាក់ទៀតមកក្ដារខៀន ធ្វើរបៀបនេះ ទាល់តែគ្រប់ពេលមួយម៉ោង ដែលត្រូវសរសេរតាមសូត្រនោះ ។

យើងធ្វើដូច្នេះម្ដង ៗ កុំឲ្យសិស្សធុញទ្រាន់នៅពេលសរសេរតាមសូត្រ ។ ហើយលទ្ធផលក៏ឃើញថាចំរើនដែរ ព្រោះសិស្សចំណេញពេលដោយបានស្គាល់ពាក្យពិបាកច្រើន ក្នុងពេលមួយម៉ោងនោះ ។ មិនស្គាល់តែពាក្យ គឺអាចស្គាល់ន័យរបស់ពាក្យទាំងនោះច្បាស់លាស់ផង ។ ហើយម្យ៉ាងទៀត ថ្នាក់យើងមានសកម្មភាពល្អ ព្រោះសិស្សម្នាក់ៗ ត្រូវតែប្រុងប្រយ័ត្ន ក្រែងដល់វេនខ្លួន សរសេរមិនបានត្រឹមត្រូវល្អ នាំឲ្យខ្មាសគេ ។

ជាអវសាន ខ្ញុំសូមមិត្តជួយកែតម្រូវផង កាលបើឃើញថាការពិសោធន៍ ត្រង់ណាមិនសូវបានផលល្អ ឬក៏មានសេចក្ដីទាស់គន្លងយ៉ាងណាខ្លះ ។

## ប្រធាន

## ដែលបានឱ្យក្នុងការប្រឡងចូល
## វិទ្យាស្ថានជាតិគរុកោសល្យ កាលពីថ្ងៃទី ២៥ មិថុនា ១៩៦២

### ផ្នែកវប្បធម៌ទូទៅ (៣ ម៉ោង)

(សរសេរជាបារាំង បើបេក្ខជនយកមុខវិជ្ជាខ្មែរ ជាវិជ្ជាឯកទេស = Spécialité; ហើយសរសេរជាខ្មែរ បើបេក្ខជននោះយកមុខវិជ្ជាឯកទេសក្រៅពីខ្មែរ ដូចជាប្រវត្តិសាស្ត្រ ភូមិសាស្ត្រ . . .)

ប្រធាន : *ភារៈកិច្ចរបស់សាស្ត្រាចារ្យក្នុងការកសាងសិក្សាធិការជាតិ ។*

(ដោយប្រធាននេះ មានអត្ថប្រយោជន៍ យ៉ាងសំខាន់ចំពោះនិស្សិតសាស្ត្រាចារ្យយើងសូមស្នើរ ធ្វើអត្ថាធិប្បាយដូចតទៅ) :

### អត្ថាធិប្បាយ

តាំងពីប្រទេសយើងបានឯករាជ្យពីថ្ងៃណាមក ការលូតលាស់គ្រប់វិស័យ បានមានសន្ទុះកាន់តែលឿន ឯការទាមទារឲ្យពលរដ្ឋប្រឹងប្រែងធ្វើពលិកម្មក៏កាន់តែរីកធំថែមទៀត ។ ក្នុងវិស័យសិក្សាធិការជាតិ ដែលបានលូតលាស់គួរជាទីពេញចិត្ត ការទាមទារនេះ កាន់តែសន្ធឹកណាស់ទៅទៀត ចំពោះរាជរដ្ឋាភិបាល ក៏ដូចជាចំពោះពលរដ្ឋទូទៅ ដែលជាឪពុកម្តាយសិស្ស ប៉ុន្តែពិសេសណាស់ទៅទៀត ចំពោះសាស្ត្រាចារ្យដែលជាអ្នកអប់រំផ្ទាល់ និងជាអ្នកទទួលខុសត្រូវចំពោះអនាគតយុវជនយើង ។ ពិតមែនតែសាស្ត្រាចារ្យម្នាក់ៗ ប្រតិបត្តិការ នៅក្នុងសិស្សមួយចំនួនតូចក៏ដោយ ប៉ុន្តែបើម្នាក់ៗ យល់ភារៈកិច្ចខ្លួនច្បាស់ និងបំពេញភារៈកិច្ចនេះបានត្រឹមត្រូវ ក៏រាប់ថាបានជួយកសាងសិក្សាធិការជាតិសន្ធឹកដែរ ។

១– មុនដំបូង ក្នុងឋានៈខ្លួនជាភ្នាក់ងាររាជការមួយរូប សាស្ត្រាចារ្យមានករណីយកិច្ចដូចភ្នាក់ងារក្រសួងឯទៀតៗដែរ ដូចយ៉ាងទំលាប់មកដល់ថ្នាក់បង្រៀនទាន់ពេលវេលា មិនឲ្យសិស្សពីបាករង់ចាំយូរៗ ដូចយ៉ាងរៀបចំការបង្រៀនតាំងពីផ្ទះមកស្រេច យ៉ាងហ្មត់ចត់ ដើម្បីកុំឲ្យមានការរអាក់រអួលក្នុងពេលពន្យល់ នាំឲ្យសិស្សនៅសង្ស័យៗ ត្រូវពិនិត្យកិច្ចការសិស្ស

ព្រមទាំងតែឲ្យល្អិតល្អន់ និងប្រគល់ឲ្យសិស្សវិញរាល់ពេលវេលា ។ រក្សាយុត្តិធម៌ក្នុងការឲ្យពិន្ទុ ក្នុងការសរសើរ ឬ ដាក់ទោស ។ ដូចយ៉ាងអនុវត្តកម្មវិធីត្រឹមត្រូវតាមកាលកំណត់ មិនឲ្យខ្វះ មិនឲ្យលឿនពេក ឬ យឺតពេក ។ ទៀតពេលសំគីសិស្សឲ្យផ្តិនយកលទ្ធផលល្អចុងឆ្នាំ ក្នុងការប្រឡងចេញ ឬ ប្រឡងឡើងថ្នាក់ ។ ដូចយ៉ាងទទួលគោរពនូវការត្រួតពិនិត្យ ឬ ការណែនាំអំពីនាយកសាលាឬ អគ្គាធិការ ។ ភារៈកិច្ចទាំងនេះជាភារៈកិច្ចធម្មតា ដែលសាស្ត្រាចារ្យអាចបំពេញដោយងាយឲ្យតែមានមនសិការក្នុងការងារបន្តិចបន្តួចក្នុងចិត្ត ។ បើបំពេញការងារប៉ុណ្ណោះបាន ចាត់ទុកថាជាភ្នាក់ងារម្នាក់ល្អ សន្មតថាបានរួចខ្លួន ។

២– ប៉ុន្តែការកសាងសិក្សាធិការជាតិតាមការ ឲ្យសាស្ត្រាចារ្យឈានមួយជំហានទៅមុខទៀត ក្នុងឋានៈខ្លួនជាអ្នកបច្ចេកទេសខាងការអប់រំ។ មុនដំបូងត្រូវតែជ្រួតជ្រាបនូវវិធីសាស្ត្រខាងគរុកោសល្យឲ្យសព្វគ្រប់ ជ្រួតជ្រាបហើយតោងចេះយកទៅអនុវត្ត និងដកស្រង់ពិសោធន៍កែប្រែខ្លួនឯង ដ្បិតការចេះទ្រឹស្តីនិងការយកទៅប្រតិបត្តិ ជាបញ្ហាពីរផ្សេងគ្នាស្រឡះ ។ យើងអាចចែកសកម្មភាពអប់រំ របស់សាស្ត្រាចារ្យជាពីរផ្នែក មួយផ្នែកអប់រំផ្តល់ចំណេះឲ្យសិស្ស មួយផ្នែកទៀតអប់រំចរិយាសម្បត្តិសិស្ស ។ អ្នកខ្លះយល់ខុសថា " សាស្ត្រាចារ្យ ជាអ្នកឯកទេសខាងមុខវិជ្ជាណាមួយ ចាំផ្តល់ចំណេះតែខាងមុខវិជ្ជានោះ មិនត្រូវស្និទ្ធស្នាលស្គាល់សិស្សទេ ភារៈអប់រំចរិយាសម្បត្តិសិស្ស ស្រេចនៅលើសាស្ត្រាចារ្យខាងចរិយាសាស្ត្រ លើអគ្គានុរក្ស លើសិក្សាធិរក្សចុះ" ។ ឯការពិត សាស្ត្រាចារ្យមានភារៈកសាង "មនុស្ស" មិនមែនកសាងឲ្យមានតែចំណេះប៉ុណ្ណោះទេ ។

ក្នុងផ្នែកផ្តល់ចំណេះឲ្យសិស្ស សាស្ត្រាចារ្យត្រូវពិសោធន៍រកវិធីខ្លួនឯង ឲ្យសមនឹងសមត្ថភាពសិស្ស ។ ខ្លឹមសារបង្រៀនសោតក៏ពុំអាចនៅប្រំដែល ៗ រាល់តែឆ្នាំឡើយ ត្រូវបន្ថែមចំណេះថ្មី ការរកឃើញថ្មី ឲ្យទាន់បច្ចុប្បន្នភាព ទាន់សម័យ ។ ហេតុដូច្នេះហើយ បានជាសាស្ត្រាចារ្យត្រូវតែខំសំគីឲ្យកាន់តែស្ទាត់ជំនាញក្នុងវិជ្ជាជីវៈរបស់ខ្លួន ។ ឧទាហរណ៍ ដូចជាធ្វើការស្រាវជ្រាវក្នុងវិជ្ជាដែលខ្លួនបង្រៀន ចងក្រងសរសេរសៀវភៅសំរាប់បង្រៀន ឧស្សាហ៍អានសៀវភៅ និងទស្សនាវដ្តី

គរុកោសល្យមកកាន់ កសាងបណ្ណាល័យមួយនៅផ្ទះសំណាក់ខ្លួន ដោយប្រមូលសន្សំឯកសារផ្សេង ៗ ដើម្បីជាការចេះដឹងទូទៅ ។ ត្រូវរួបរួមប្រជុំសន្និសិទជាមួយនឹងសាស្ត្រាចារ្យឯទៀត ៗ ស្តីអំពីវិធីបង្រៀន អំពីកម្មវិធីសិក្សា ។ល។

ក្នុងផ្នែកអប់រំចរិយា នឹងស្មារតីសិស្ស សាស្ត្រាចារ្យមានភារៈនឹងទាក់ទងស្និទ្ធស្នាលនឹងសិស្សធ្វើឲ្យសិស្សទុកចិត្ត យកខ្លួនជារៀមច្បងល្មមគ្នាផ្ចិតផ្ចើមថ្នមបានផង ។ សាស្ត្រាចារ្យដែលមកបង្រៀនកោក ៗ ដល់ម៉ោងទៅបាត់ មិនស្គាល់សិស្សក្នុងថ្នាក់ខ្លួន ថាអ្នកណាយ៉ាងណា ៗ សាស្ត្រាចារ្យនោះ ប្រៀបបាននឹងមនុស្សរើរវាយ ដើរជើងមិនជាប់ដី ។ គប្បីសាស្ត្រាចារ្យស្គាល់ចិត្តថ្លើមយុវជនឲ្យច្បាស់ ដែលធ្លាប់តែសប្បាយក៏ធាប់ ក្រេកក្រអាលក៏ធាប់ កៀរគ្នាក៏ធាប់ ឈឺចាប់អាក់អន់ចិត្តក៏ធាប់ ។ ក្នុងពេលបង្រៀនក្តី ក្នុងពេលចេញលេងក្តី ការអប់រំចរិយាមិនបាច់ធ្វើដោយបង្ខំឲ្យសិស្សដឹងខ្លួនឡើយ គ្រាន់តែប្រើអាកប្បកិរិយា នឹងសំដីបន្តិចបន្តួច សមតាមកាលៈទេសៈ សាមីខ្លួនច្រើនតែដឹងខ្លួន ហើយនឹងអរគុណសាស្ត្រាចារ្យមិនភ្លេច ដែលបានចេះជៀសវាង មិនធ្វើឲ្យខ្លួនបាក់មុខ ។ គប្បីសាស្ត្រាចារ្យស្គាល់លក្ខណៈសិស្សខ្លួននិមួយ ៗ ហើយមានវិធានការយឹតយោងសិស្សណា ដែលខ្វះខាតចរិយាសម្បត្តិជាងគេ ។ ពិសេសទៅទៀត ការទាក់ទងនឹងឪពុកម្តាយសិស្ស ជួយបំភ្លឺគេអំពីការរៀនសូត្ររបស់កូនគេនៅសាលា នឹងអំពីវិធានការដើម្បីអប់រំចរិយាគ្នានៅផ្ទះ ជាការប្រពៃណាស់ដែលអ្នកអប់រំត្រូវតែឆ្លៀតធ្វើ ។

### ៣– ភារៈកិច្ចសាស្ត្រាចារ្យ ចំពោះសង្គមមនុស្ស និង ចំពោះជាតិ

រឹតតែមានសារៈសំខាន់ណាស់ទៅទៀត ។ ត្រង់ចំណុចនេះ គប្បីសាស្ត្រាចារ្យមើលឲ្យវែងឆ្ងាយមែនទែន ឲ្យដឹងថាសកម្មភាពខ្លួនក្នុងយុវជន ដំរង់ទៅទិសណាទៅដល់ណា ។ ការនេះនាំឲ្យពិនិត្យពិចារណាច្រើន គឺថាសាស្ត្រាចារ្យត្រូវដឹងស្ថានការណ៍ប្រទេសជាតិខ្លះ ដឹងបញ្ហារបស់យុវជនយើង ដឹងសេចក្តីត្រូវការជាចាំបាច់របស់សិក្សាធិការជាតិ នឹងទិន្នាការនៃការវិវត្តន៍ទៅអនាគត ក្នុងវិស័យសិក្សាធិការនេះ ។ មុខងារសាស្ត្រាចារ្យក្នុងការរីកចំរើនវប្បធម៌ជាតិ មិនមែនតូចជាងអ្នកកវីនិពន្ធ ឬសិល្បករឡើយ ។

និយាយដោយខ្លី ចំណុចដែលសាស្ត្រាចារ្យត្រូវចាប់អារម្មណ៍ជាងគេ គឺថាមនុស្សក្នុងប្រទេសយើងជាងពាក់កណ្ដាលសុទ្ធតែជាយុវជន (និយាយតាមស្ថិតិអ្នកជំនាញម្នាក់) ដែលមិនទាន់ជាអ្នកបង្កើតផលនៅឡើយទេ គឺសុទ្ធតែជាអ្នករៀនឬជាអ្នកត្រៀមខ្លួនចាំតែមករៀន ។ បញ្ហាដែលចោទចំពោះជាតិ គឺអប់រំយុវជនជាងពីរលាននាក់ឲ្យចេះដឹង, លុះចេះហើយត្រូវមានការឲ្យធ្វើទៀត ។ តើធ្វើការសរសេរលើក្រដាសនៅការិយាល័យ ឬធ្វើការជាផលិតករ បង្កើនសេដ្ឋកិច្ចជាតិ ?

មកដល់សព្វថ្ងៃនេះ តាមព្រះរាជនយោបាយសម្ដេចព្រះបិតាជាតិ យើងបានយកការអប់រំយុវ-ជនជាទន់ធំទៅអនាគត ។ ហេតុដូច្នេះហើយបានជាប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ ស្ថាបនាសាលារៀនពុំចេះចប់ពុំចេះហើយ ។ ភារៈកិច្ចសាស្ត្រា-ចារ្យក្នុងផ្នែកនេះ គឺរួបរួមយ៉ាងសកម្មក្នុងគណៈកម្មការពង្រីកសិក្សាក្នុងដំបន់ខ្លួន ដើម្បីស្ថាបនាសំណង់ ទិញផ្គត់ផ្គង់សម្ភារៈ ឲ្យសាលាឲ្យកាន់តែច្រើនទៀត ។ ប៉ុន្តែសេចក្ដីត្រូវការរបស់សិក្សាធិការជាតិយើង មិនមែនតែចំនួនសាលា តុកៅអីប៉ុណ្ណោះទេ នៅត្រូវការខាងគុណសម្បត្តិទៀត ។ ដ្បិតសាស្ត្រាចារ្យគ្រប់គ្នា សុទ្ធតែបានធ្លាប់ឮគេថា "សិស្សឥឡូវខ្សោយជាងពីដើមឆ្ងាយណាស់" ។ ដូច្នេះសាស្ត្រាចារ្យតោងតែជួយពិនិត្យរកបុព្វហេតុផង ។ ម្ល៉ោះហើយ អ្នកត្រូវតែគិតគូរដល់បញ្ហាចំនួននឹងសមត្ថភាពគ្រូ បញ្ហាកម្មវិធី បញ្ហាប្រើភាសាជាតិ ក្នុងការបង្រៀន បញ្ហាសរសេរសៀវភៅជាភាសាជាតិ បញ្ហាសម្ភារៈសំរាប់ពិសោធន៍វិទ្យាសាស្ត្រ នឹងការអនុវត្ត ។ បញ្ហាទាំងនេះ ឪពុកម្ដាយសិស្សមិនបានជាគិតទេ លោកគិតតែពីសង់សាលា ដើម្បីបញ្ចូលកូនចៅលោកឲ្យបានកន្លែងរៀនតែម៉្យាង ។ សាស្ត្រាចារ្យតោងតែមានមតិច្បាស់លាស់ជួយចំភ្លឺលោក អំពីបញ្ហាទាំងនេះ មានបញ្ហាភាសាជាតិជាដើម ពីព្រោះខ្លួនជាអ្នកប្រតិបត្តិការរាល់ថ្ងៃ អាចដឹងសព្វគ្រប់ជាងគេ ។

ដើម្បីកសាងយុវជនឲ្យទៅជាពលរដ្ឋល្អ ក្នុងសង្គមជាតិ សាស្ត្រាចារ្យមានភារៈអប់រំសិស្សឲ្យចេះស្រឡាញ់ការព្យាយាម កុំឲ្យម្នាក់ៗ គិតតែយកស្រណុកខ្លួនឯងចំណេញលើខ្នងគេ ឲ្យចេះស្រឡាញ់មុខរបរផលិតកម្មពិតៗ ឲ្យចេះសប្បាយក្នុងការស្អាតស្អំ ឲ្យចេះគោរពមតិគេ ស្រឡាញ់

ប្រជាធិបតេយ្យ ឲ្យរក្សាសមគ្គីភាព ឲ្យខ្ជាប់ក្នុងយុវជន ឲ្យស្រឡាញ់តែវប្បធម៌ ថ្លៃថ្នូរ ៗ ខាងផ្លូវស្មារតីត្រូវឲ្យយុវជនជ្រួតជ្រាបឧត្តមគតិជាតិ តាមដំបូន្មានព្រះអគ្គមគ្គុទ្ទេសក៍ជាតិ គឺស្នេហាជាតិ និងប្តូរផ្តាច់ការពារឯករាជ្យ បូរណភាព និងអព្យាក្រឹតភាព នៃប្រទេសជាតិ ៗ ជាពិសេស សាស្ត្រាចារ្យមានភារៈកិច្ច នាំសិស្សប្រួមប្រួមក្នុងគ្រប់សកម្មភាពដែលជាសន្ទុះដល់ការលូតលាស់ ក្នុងផ្ទៃជាតិ ដូចជាការធ្វើកីឡា ការហាត់កម្ម ជាដើម ៗ

សរុបទៅឃើញថាភារៈកិច្ចរបស់សាស្ត្រាចារ្យក្នុងការកសាងសិក្សាធិការជាតិធំទូលាយណាស់ ៗ ភារៈនេះតាមទារឲ្យសាស្ត្រាចារ្យ បំណាយកម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញា ធ្វើពលិកម្មពុំខ្លាចហត់នឿយគ្រប់ពេលវេលា ហើយថែមទាំងមិនបានជាចេញមុខមាត់និងគេច្រើនដងទេ ៗ ដែលមានអ្នកសុខចិត្តមកប្រកបវិជ្ជាជីវៈជាសាស្ត្រាចារ្យដោយដឹងថាលំបាកយ៉ាងនេះ ក៏មកតែពីអ្នកនោះស្រឡាញ់យុវជនអស់ពីចិត្តពីថ្លើម ចង់កសាងអប់រំគេ ប្រៀបដូចជាអ្នកដាំផ្កាដែលខំសិតសំអាងផ្កាឲ្យរីកល្អ ដើម្បីលើកជូនទៅប្រទេសជាតិសំរាប់អនាគតដែរៗ ទោះជាគេដឹងក្តីពុំដឹងក្តី សាស្ត្រាចារ្យនៅតែពេញចិត្តនិងស្នាដៃខ្លួនឯង នេះជារង្វាន់លើកទឹកចិត្តម្យ៉ាងដែរ ៗ នរណាដែលពុំយល់ភារៈកិច្ចទាំងនេះ ពុំស្រឡាញ់យុវជនសោះ ហើយចូលមកប្រកបរបរសាស្ត្រាចារ្យ ដើម្បីដោះគុនឲ្យតែរួចមួយគ្រា ៗ នោះ អ្នកនោះនាំឲ្យខូចប្រយោជន៍សិក្សាធិការជាតិ និងប្រយោជន៍សិស្សច្រើនណាស់ ៗ គួរណាស់តែអ្នកនោះទៅចាប់របរដទៃ តាំងតែពីដើមទីឲ្យហើយទៅ ៗ

★

## វិញ្ញាសាឯកទេស (៣ ម៉ោង)

### ផ្នែកភាសាខ្មែរ :

ពិតមែនហើយ ការសាងសន្សំបារមី ជាភារៈកិច្ចនៃព្រះពោធិសត្វ ៗ ប៉ុន្តែគេហាថា ការសាងទានបារមីរបស់ព្រះវេស្សន្តរ មិនសមហេតុសមផលសោះ ព្រោះសកម្មភាពរបស់ព្រះអង្គផ្តល់លទ្ធផលដ៏ឃោរឃៅដល់ព្រះអង្គឯង ដល់ព្រះរាជវង្សព្រះអង្គឯង ៗ

តើអ្នកគប្បីពិភាក្សាដោះស្រាយដូចម្តេច ?

### ផ្នែកភូមិសាស្ត្រ

Caractéristiques de la vie économique dans le Sud - Est asiatique (Birmanie, Thailande, Malaisie, Viet-Nam, Laos).

### ផ្នែកប្រវត្តិសាស្ត្រ

L’émancipation des peuples coloniaux après la 2è guerre mondiale .

## ផ្នែកវិទ្យាសាស្ត្រធម្មជាតិ

L'appareil respiratoire ; la respiratoion.

## ផ្នែកភាសាបារាំង

Une correspondante de Rousseau lui écrivait à propos de l'« Emile» : «J'ai lu votre roman de l'éducation , je l'appelle ainsi parce qu'il apparaît impossible de réaliser votre méthode , mais il y a beaucoup à apprende , à méditer et à profiter ». Vous illustrez les divers aspects de ce jugement nuancé .

## ផ្នែកភាសាអង់គ្លេស

### Aviation

«Flinyg (1) like any kind of new mechanical development is a double-edged instrument : it can be a benefit as well as a curse (2) or mankind. »

Discuss the above judgment through a conversation between two people holding two opposite opinions about aviation.

(1) Flying: aviation.

(2) curse: evil ; cause of ruin (fr:mal, fléau).

## ផ្នែកវិទ្យាសាស្ត្ររូបនិយម

### I— Question de cours :

L'œil réduit. Accommodation, défauts d'accommodation et leur correction.

### II— Problème :

1°— Un solénoïde S long et droit comprend 504 spires pour une longueur de 60 centimètres; sa résistance est 4,4 ohm. Il est constitué par un fil ayant une section de 1 millimètre carré dont la résistivité est $1,6 \times 10^{-6}$ ohm-centimètre. Calculer la longueur de ce fil.

2°— Trois résistances, $r_1 = 65$ ohms, $r_2 = 26$ ohms, $r_3 = x$, sont montées en dérivation pour former une résistance R=6, 3 ohms. Calculer x.

3°— Le solénoïde S et la résistance R montés en série aux bornes sont d'une batterie d'accumulateurs de f.é.m. E= 55 volts et de résistance interiéure r =0,1 ohm. On demande de calculer :

a) la résistance totale du circuit ;

b) l'intensité du courant dans $S, r_1, r_2, r_3$;

c) la valeur du champ magnétique au centre de la bobine longue;

d) la quantité d'électricité débitée en deux heures par la batterie.

4°— En admettant que cette quantité d'électricité traverse deux voltamètres disposés en série dont les électrolites sont pour le premier du sulfate ferreux et pour le second du sulfate ferrique, calculer les masses de fer déposées sur chacune des cathodes, sachant que 96.500 coulombs libèrent une valence—gramme et que la masse atomique du fer est 56.





# វិទ្យាសាស្ត្រ និង កំណាព្យ

## បណ្តាំទំនើប

ធុប រិន

កូនខ្មែរពិត   គួរឈឺចិត្ត   គិតរឿងជាតិ
គួរខ្មីឃ្មាត   ជ្រោមជ្រែងជាតិ   ឲ្យថ្លៃថ្លា
ទំគ្រប់គ្នា   ធ្វើបុកពា   ឲ្យសង្ហារ
កុំសារ៉ា   ដោះអាត្មា   ជាខ្ជិលច្រើន ៗ
គួរគន់គិត   គិតរាសនា   កម្ពុជា
ទំគ្រប់គ្នា   កុំរុញរា   គប្បីរើង
ខំខន្តា   ក្តាប់ហត្ថា   ពេញទំហឹង
គ្បៀតគ្រវតឹង   ប្រឹងឲ្យណាស់   ទាំងចាស់ក្មេង ៗ
ចាប់ត្រង់ណា   ត្រាត់ខ្លាច   កុំម៉េះម៉ោះ
វែកឲ្យខ្សោះ   គាប់ឲ្យអស់   កុំធ្វើលេង
កាន់ត្រង់ណា   កាន់ត្រង់នោះ   កុំបីលែង

ប្រាណត្រចៀង វែងត្រចៀង ប្រឹងប្រិតឡើង ៗ
ត្រូវសន្តោស ប្រោសគាណិត គិតជាតិខ្មែរ
ជួយប្រុងកែ ខ្មែរដូចគ្នា ឲ្យបានចើន
កុំស្រដី ពាក្យអប្រីយ វាយបុកច្រើន
គួរជំរើន ឲ្យខ្ពស់ឡើង ទើបប្រសើរ ៗ
កុំឃើញគ្នា ទាទន់ទាប រាបទឹកដី
តាំងខ្ពុកខ្វី កាច់ជើងដៃ មិនឲ្យដើរ
ឃើញគ្នាប៉ិច ក្ដិបគ្នាប៉ាត់ ដូច្នេះតេ
វាប្រសើរ ប្ដុយ៉ាងម៉េច ចូរគិតមើល !
ប្រុសក្លាខ្លាំង ត្រូវស្លូតសាំង ចំពោះស្រី
ឯស្ត្រី គួរគប្បី កុំធ្វើព្រើល
គោរពគ្នា ជាបងប្អូន កុំងាយមើល
កុំងងើល នាំជ្រួលផ្អើល ទឹងកាមា ៗ
ត្រូវនិយម ចំប្រើប្រាស់ ភាសាជាតិ
គួរខ្មីឃ្មាត ឈ្មបច្នាស់ធ្វៀត ចំសិក្សា
ភាសាជាតិ អក្ខរៈ ខេមរា
មុនភាសា ទឹងអក្ខរា ជាតិនានា ៗ
កុំថាខ្មែរ តែបែរជា បុកមិនផែះ
ជាតិគេតេះ ដៀលខេមរា មិនវឌ្ឍនា
ព្រោះខេមរៈ មានអ្នកខ្វះ មិនចំពា
ទឹងសិក្សា ភាសាជាតិ ផងខ្លួនសោះ ៗ

| | | |
|---|---|---|
| អ្នកនោះឯង | ច្រើនស្រដី | ក្មេងខេមក |
| ពោលបរបា | ប្រហ្វង់ភាសា | មិនសូវស្រស់ |
| ក្មេងឥឡូវ | និយាយមិន | ត្រូវជ្រុងសោះ |
| រាគ្គងចាស់ | ចុះយ៉ាប់អស់ | សម្បើមក្រៃ ៗ |
| ខ្ញុំសូមសួរ | ដោយសមគួរ | ព្រោះឆ្ងល់ខ្លាំង |
| ជាបារាំង | កុំជាក្មេង | ជាបាស់ថ្មី |
| តើមានបេះ | ខ្មែរមួយម៉ាត់ | ដែរឬអ្វី ? |
| គួរគប្បី | លៃតាមនេះ | ផងទៅអើយ ! |



— បើមិត្តបានទទួល “ទស្សនាវដ្ដីសាស្ត្រាចារ្យ” មិនទៀតទាត់ទេ សូមមិត្តជំរាប តំណាងរបស់មិត្ត ឲ្យទាមទារជូន ។

★

— ម្យ៉ាងទៀត គណៈកម្មាធិការនាយក ទើបតែបានបោះពុម្ពលក្ខន្តិកៈ នឹងប័ណ្ណសមាជិកថែមទៀត ។ សូមមិត្តតំណាងផ្ញើចំនួនសមាជិក ដែលត្រូវការលក្ខន្តិកៈ នឹងប័ណ្ណនេះ មកគណៈកម្មាធិការនាយក ។



# លូ ស៊ិន

## អ្នកមួយដ៏ឆើតឆាយក្នុង អក្សរសាស្ត្រចិន

លូ ស៊ិន ជាអ្នកនិពន្ធម្នាក់ ប្រកបទៅដោយទេពកោសល្យកម្ររកបាន ហើយដែលប្រជាពលរដ្ឋចិន បានចាត់ទុកជាអ្នកបង្កបង្កើតអក្សរសាស្ត្រចិនសម័យថ្មី និងជាអ្នកបើកផ្លូវ ហើយដឹកនាំការបដិវត្តន៍ ខាងវប្បធម៌ចិនទៀតផង ។ ប៉ុន្តែ កិត្យានុភាពរបស់ លូ-ស៊ិន មិនមានព្រំដែនតែត្រឹមប្រទេសចិនប៉ុណ្ណោះទេ កិត្យានុភាពដ៏ធំទូលាយនេះ ថែមទាំងបានខ្ចរខ្ចាយចេញហួសពីព្រំដែនចិនទៅទៀត ។ ហើយនៅបរទេស លោក លូ ស៊ិន បានគេស្គាល់លោក ដូចជាគេស្គាល់ ហ្សង់ហ្សាក់ រូស្សូ (J.J.Rousseau) បារាំង ឬ ម៉ាក ត្វេន (Marc Twain) អាមេរិក ឬ ម៉ាក់ស៊ីម ហ្គរគី (Maxime-Gorki) រុស្ស៊ីដូច្នោះដែរ ។

ហេតុនេះ យើងមានសេចក្ដីរីករាយនឹងជំរាបមិត្តអ្នកអានរបស់យើង ក្នុងលេខនេះ ពីលោក លូ ស៊ិន ដូចតទៅ (ទៅអនាគត យើងនឹងបង្ហាញជូន នូវអ្នកនិពន្ធបារាំង អាមេរិក . . . ជាលំដាប់) ។

★

លូ ស៊ិន កើតក្នុងឆ្នាំ ១៨៨១ នៅស្រុកចាវស៊ិញ ក្នុងខេត្តចេគាំង ។ គ្រួសាររបស់លោក ដោយរវល់នឹងព្យាបាលជម្ងឺឪពុកលោក ក៏បានធ្លាក់ក្រ ហើយទោះបីឥវ៉ាន់មានតម្លៃទាំងប៉ុន្មានបានត្រូវលក់អស់រលីងហើយ ឪពុកលោកក៏នៅតែបាត់បង់ជីវិតដដែល ។

ក្រោយមកយុវជន លូ-ស៊ិន បានសំរេចចិត្តទៅសិក្សានៅ សាលានាវា "គាំងណាង"

ឯណាន់កាំង ៗ ដើម្បីឲ្យលោកធ្វើសាហ៊ុយ ម្ដាយលោកគេប្រាក់ឲ្យបានត្រឹមតែ ៨ ដុល្លា ប៉ុណ្ណោះ ៗ ម្ដាយលោកយំជាខ្លាំង យំអាណិតកូន ដែលមុខជានឹងត្រូវគេមើលងាយ បន្ទាបបន្ថោក ហើយ ព្រោះនៅសម័យនោះ បើចង់ទៅជា បណ្ឌិតខាងអក្សរសាស្ត្រមួយរូប ៗ គេត្រូវតែសិក្សា អក្សរចិនបូរាណ ឯអ្នកដែលទៅសិក្សាវិជ្ជាបរទេស នឹងត្រូវគេចាត់ទុកជាអ្នកអស់សង្ឃឹម ដែលរកផ្លូវអ្វីគ្មាន ក៏ដាច់ចិត្តទៅលក់ខ្លួនឲ្យបរទេស ៗ លូ-ស៊ុឆ គ្មានរវល់ពីការអស់ទាំងនេះទេ ៗ លុះទៅដល់សាលានោះ ទើបលោកបានដឹងថា នៅក្នុងលោកនេះ មានវិទ្យាសាស្ត្រ ដែលហៅថាប្រវត្តិសាស្ត្រធម្មជាតិ នព្វន្តសាស្ត្រ ភូមិសាស្ត្រ ប្រវត្តិសាស្ត្រ គំនូរនឹងកាយសាស្ត្រ ៗ លើសពីនេះទៅទៀត លូ-ស៊ុឆ បានដឹងតាមសៀវភៅប្រវត្តិសាស្ត្រ ដែលប្រែភាសាពីបរទេសមកថា នៅប្រទេសជប៉ុន ការកែទម្រង់មួយយ៉ាងធំ កំពុងតែបានចាប់ផ្ដើមអនុវត្តហើយ ដោយគេបញ្ជូលនូវវេជ្ជវិជ្ជាខាងអឺរ៉ុបមកសិក្សា ៗ

ចំណេះវិជ្ជាសើ ១ ខាងលើនេះ បានដឹកនាំចិត្តលោកឲ្យទៅសិក្សាក្នុង មហាវិទ្យាល័យពេទ្យមួយក្នុងអាណាខេត្តនៃប្រទេសជប៉ុន ៗ លោកគិតថា លុះរៀនចប់កាលណា លោកនឹងត្រឡប់មកមាតុភូមិវិញ ជួយសំរាលទុក្ខ នៃអ្នកជម្ងឺទាំងឡាយ ហើយធ្វើឲ្យជនជាតិរបស់លោក កាន់តែមានជំនឿជាក់ក្នុងការកែទម្រង់ថែមទៀត ៗ នៅឯសាលា កាលណាមេរៀនចប់មុនម៉ោងម្ដង ១ គេតែងបញ្ចាំងកុនឲ្យសិស្សមើល ៗ មានម្ដងនោះ នៅលើផ្ទាំងសំពត់ស លោកលូស៊ុឆ ឃើញមានជនជាតិចិនជាច្រើន ឈរពេទជុំវិញចិនម្នាក់ទៀត ដែលមានដៃជាប់ចំណង ៗ គេទាំងឡាយមានមាឌមាំ ៗ ប៉ុន្តែទឹកមុខបែបជាសោះអង្គើយខ្លាំងណាស់ ៗ បើតាមសេចក្ដីពន្យល់នៃចំណងជើងរឿង « ចិនដែលជាប់ចំណងនោះ គឺជាអ្នកយកការឲ្យពួករុស្ស៊ី (ក្នុងសង្គ្រាមរុស្ស៊ី-ជប៉ុន) ជប៉ុនត្រូវតែកាត់កកុំឲ្យចិនឯទៀត ១ យកដំរាប់តាម » ៗ

ឆ្នាំសិក្សានៅមិនទាន់ចប់នៅឡើយទេ តែលោកក៏ដាច់ចិត្តចេញមកនៅឯតូក្យូហើយ ៗ ដល់ពេលនេះ លោកឃើញថាវិជ្ជាពេទ្យ ហាក់ដូចជាមានសារៈសំខាន់បន្ទាប់បន្សំទៅវិញហើយ ៗ ព្រោះថាពលរដ្ឋនៃប្រជាជាតិគូនថយនិមួយ ១ បើសំរាប់តែឲ្យគេសម្លាប់ធ្វើជាឧទាហរណ៍ ឬក៏សំរាប់

តែឈរមើលគេសម្លាប់ជនជាតិឯង ដោយគ្មានភ្ញាក់រលឹកដូច្នេះទេ នោះប្រសិនជាបណ្ដោយឲ្យគេឈឺរួចស្លាប់ទាំងជម្ងឺទៅ ក៏គ្មានជាការសំខាន់អ្វីប៉ុន្មានដែរ ។ លោក លូ ស៊ុន យល់ថា ដំបូងបង្អស់ត្រូវតែកែប្រែគំនិតមនុស្ស ហើយមធ្យោបាយប្រសើរបំផុតដើម្បីកែប្រែនោះ គឺអក្សរសាស្ត្រ ។ ហើយលោកក៏សម្រេចចិត្តបបួលគេឯង ឲ្យគិតគូរពីអក្សរសាស្ត្រឡើង ។ ប៉ុន្តែបណ្ដានិស្សិតចិននៅតូក្យូពេលនោះ គ្មាននរណាម្នាក់រៀនខាងអក្សរសាស្ត្រ ឬ វិចិត្រសិល្បៈសោះ មានតែខាងច្បាប់ ខាងវិទ្យាសាស្ត្រ នយោបាយ រូបសាស្ត្រ គីមី ឬក៏ខាងប៉ូលិស ឬខាងឧស្សាហកម្មទៅវិញ ។ គឺគំនិតឈឺចាប់ គំនិតស្នេហាជាតិនេះហើយ ដែលនាំឲ្យលោកលះបង់វិជ្ជាពេទ្យហើយ បែរមកគិតគូរពីអក្សរសាស្ត្រវិញ ហើយធ្វើឲ្យលោកមានទេពកោសល្យខាងបញ្ហានេះឡើង ។

ស្នាដៃទាំងប៉ុន្មានរបស់លោក លូ ស៊ុន សុទ្ធតែមានគោលដៅមួយច្បាស់លាស់ គឺសំដៅទៅអប់រំប្រជាពលរដ្ឋឲ្យបេះឈឺផ្ដាល ឲ្យបេះភ្ញាក់រលឹក ឲ្យមានគំនិតស្នេហាជាតិ ឲ្យបេះស្អប់សត្រូវរបស់ជាតិនិងរបស់ប្រជាពលរដ្ឋចិន ។ ស្នាដៃរបស់លោកបង្ហាញនូវប្រាកដនិយម យ៉ាងច្បាស់លាស់ បង្ហាញសេចក្ដីស្នេហាលទ្ធិប្រជាធិបតេយ្យ របស់លោក និងការជាប់ជិតស្និទ្ធជាសាច់មួយរវាងលោកនឹងប្រជាពលករ រវាងលោកនឹងមនុស្សទេះគឺអត្តន័យ ។ ចំណែកឯរបៀបនិពន្ធវិញនោះគឺពេញទៅដោយជីវិតរស់រវើក ហើយពេញទៅដោយសំរស់ស្រស់ប៉ប្រិម នៃលក្ខណៈពិសេសរបស់សង្គមជាតិចិន ។

លោក លូ ស៊ុន ចាប់ផ្ដើមការនិពន្ធរបស់លោក ដោយសរសេររឿងខ្លី ៗ (Nouvelles) (ស្ដីពីជីវភាពនៃប្រជាពលករ នៃបញ្ញវ័នចិន . . . . . . . ) ដែលគេបានបង្ក្រងបោះផ្សាយជាលើកដំបូងក្រោមចំណងជើង "សំរែកអំពាវនាវ,, (Cri d'appel) ។ ក្នុងក្រមង់នេះ មានរឿង "កំណត់ប្រចាំថ្ងៃនៃមនុស្សឆ្កួតម្នាក់, គុងយី-គី, ឧបត្ដិហេតុតូចមួយ, ព្យុះសង្ឃរានៅក្នុងទឹកតែ មួយពែង, ភូមិនៃជីដូន ជីតាខ្ញុំ, ល្ខោននៃពួកទេវតា,, (១៩១៨-១៩២២) ។ ក្នុងក្រមង់ទី ២ ឈ្មោះ " ទម្លាប់នៃការប្រព្រឹត្ត" (Errements) មានរឿង " ពលិកម្មដើម្បីបុណ្យចូលឆ្នាំ, នៅក្នុងតៀមមួយ, អ្នកស្អប់មនុស្ស, គ្រួសារសប្បាយចិត្តមួយ, ការសោក

ស្តាយអតីតកាល» (១៩២៤-១៩២៥) ។ កម្រងទី ៣ ឈ្មោះ «រឿងព្រេងចាស់ យកមកនិទានជាថ្មី» ដែលមានរឿង ៨ ។

សារុបទៅ គឺជាវប្បធម៌ជាតិចិន ហើយជាពិសេសគឺអក្សរសាស្ត្រចិន ដែលបានប្រែភេទចាស់របស់ខ្លួន (បំរើម្ចាស់ដី បំរើសៅកែ) មកជាអក្សរសាស្ត្ររបស់ប្រជាពលរដ្ឋ ដែលបំរើប្រជាពលករពិត ៗ ដូចសព្វថ្ងៃនេះវិញ គឺចាប់ពីពេលដែល «សំរែកអំពាវនាវ» ដែលជាសេរីត្រលើកដំបូងរបស់លោក លូ ស៊ុន បានបន្លឺឡើងដើម្បីទឹងដាស់ប្រជាករនេះឯង ។

ហើយបើមិត្តចង់ស្គាល់លោក លូ ស៊ុន ឲ្យកាន់តែបានច្បាស់បន្តិចទៀត សូមមិត្តអានអត្ថបទនេះដែលជាសេចក្តីដកស្រង់ពីរឿង «ឧបត្តិហេតុតូចមួយ» របស់លោក (កក្កដា ១៩២០) ចុះ ។

★

អ្នករត់ដៃកៃរដែលលោក លូ ស៊ុន ជិះ កំពុងតែរត់ដោយល្បឿនយ៉ាងលឿន ជិតដល់ដំណាក់ចុះទៅហើយ ស្រាប់តែមានមនុស្សម្នាក់ រត់មកបុកនឹងទូកដៃកៃរនោះ ហើយដួលទៅលើដីដោយស្រួលទៅ ។

«មនុស្សនោះ គឺជាស្ត្រីម្នាក់ សក់ឡើងប្រផេះ ហើយដែលមានសំលៀកបំពាក់ ដាច់ដាចរហែករយ៉ី ៗ ស្ត្រីនេះស្រាប់តែចុះពីលើចិញ្ចើមថ្នល់មកយ៉ាងលឿន ហើយតម្រង់មករកដៃកៃរ ។ កម្មករអ្នករត់ដៃកៃរបានទប់ប្រឹងគេច ដើម្បីនឹងជៀសគាត់ ប៉ុន្តែដោយអាវប្រេកសំឡូររបស់គាត់របេះឡេវ ខ្យល់បក់មកក៏បប៉ើងឲ្យទៅជាប់ជាប់នឹងទូកដៃកៃរ ។ ជាសំណាងល្អ អ្នករត់ដៃកៃរនោះបានបន្ថយល្បឿនទុកបំរុងស្រេច បើពុំនោះទេ ដៃកៃរនោះនឹងបុកស្ត្រីតាំងទទឹងខ្លួនហើយ ហើយគាត់នឹងត្រូវរបួសជាទម្ងន់មិនខាន ។

«ដោយឃើញថា ស្ត្រីនោះមិនទាន់ក្រោករួចនៅឡើយទេ កម្មករក៏ឈប់ ៗ ដោយខ្ញុំដឹងច្បាស់ថា គាត់នេះគ្មានត្រូវរបួសត្រង់ណាសោះ ហើយគាប់ជួនពេលនោះ គ្មាននរណាម្នាក់គេបានឃើញផង ខ្ញុំមានចិត្តមិនចង់ឲ្យអ្នកដៃកៃរខ្ញុំជាប់ដៃកង្វល់រឿងនេះសោះ ដែលជាហេតុនាំឲ្យតែមានរឿងដល់គ្នាផង ហើយនាំឲ្យតែយឺតដំណើរដល់ខ្ញុំផង ។

«ខ្ញុំក៏ប្រាប់ថា :

– គ្មានអីជាទម្ងន់ទេ ទៅ ទៅទៀត !

កម្មករមិនបានយកចិត្តទុកដាក់នឹងសំដីរបស់

ខ្ញុំទេ — ឬប្រហែលជាគេមិនបានឮក៏មិនដឹង ។ កម្មករដាក់ទូកផៃកៅចុះ រួចជួយលើកស្រ្តីនោះឲ្យឈរឡើងដោយថ្នមៗ ជួយគ្រាហ៍ហើយសួរស្រ្តីនោះថា :

— ម៉េចទៅ មានត្រូវត្រង់ណាទេ មីង ?

— ខ្ញុំឈឺខ្លាំងណាស់ ។

“ ខ្ញុំគិតថា : អញបានឃើញគាត់ឯងដួលស្រួលៗសោះ ចុះម៉េចក៏គាត់ឯងអាចនឹងថាឈឺដល់ទៅម្ល៉េះកើត? ឯងច្បាស់ជាធ្វើពុតហើយ ស្អប់ណាស់... មនុស្សរបៀបហ្នឹង ! ហើយចំណែកឯងខាងនេះវិញ នែអ្នករត់ ! ឯងត្រូវការអ្វីទៀតយកដំរៅញ្ចោះនេះមកតៀតក្បៀក ? បន្តិចថាដល់មានរឿងទៅ ពិបាកបន្ទោសខ្លួនឯង ។ តែល្ហើយស្រេចតែឯងទៅចុះ !

“ លុះបានឮសំដីស្រ្តីថាដូច្នោះហើយ កម្មករក៏លែងរញ៉ករទៀតហើយ ; គេគ្រាហ៍ស្រ្តីនោះដើរសន្សឹមៗចេញទៅ ។ ដោយធ្លល់ខ្លាំងពេក ខ្ញុំក៏សម្លឹងមើលតាមគេទៅ ឃើញប៉ុស្តិ៍ប៉ូលីសមួយ ។

. . , . , . . . . . .

“ នៅក្នុងខណៈនោះ ខ្ញុំមានការចាប់អារម្មណ៍យ៉ាងប្លែកអស្ចារ្យ ; រូបារម្មណ៍នៃខ្លួនដ៏មានធូលីរបស់កម្មករនោះស្រាប់តែមានទំហំរីកធំឡើងៗ ។ គេកាន់តែដើរចេញឆ្ងាយទៅកាលណា រូបរបស់គេក៏កាន់តែធំឡើងៗ កាលនោះធំក្រៃណាធំ ធំមែនទែន ពាល់តែខ្ញុំទ្រាំអត់តទៅទៀតមិនបាន ខ្ញុំក៏ងើតក្បាលមើល ។ លើសពីនេះទៅទៀត រូបនេះបានផះមកលើខ្ញុំនូវឥទ្ធិពលសង្កត់មួយ មានលក្ខណ: ជាគំរាមកំហែង (une pression menaçante) ដែលកិនកំទេចបន្តិចម្តងៗ នូវ “ អញ: Moi ” ដ៏តូចល្អិតដែលនៅលាក់ខ្លួនក្នុងអាត្មាពីក្នុងអាវធ្វើពីរោមសត្វ ។

“ ជីវិតរបស់ខ្ញុំក៏ហាក់ដូចជារលត់បាត់ដែរ ។ ខ្ញុំនៅអង្គុយធ្មឹងដូចទឹងមោង គ្មានកម្រើកដៃជើងអ្វីបន្តិចសោះៗ គឺពាល់តែឃើញភ្នាក់ងារប៉ូលីសម្នាក់ចេញពីប៉ុស្តមក ទើបខ្ញុំចុះពីផៃកៅ ។

“ ភ្នាក់ងារដើរមកជិតខ្ញុំ :

— សូមលោកអញ្ជើញទៅរកផៃកៅមួយផ្សេងទៀតចុះ ផៃកៅនេះលែងដឹកលោកបានទៀតហើយ ។

“ ដោយគ្មានពិចារណាអ្វីបន្តិចសោះ ខ្ញុំក៏បាវលុយមួយក្តាប់ធំពីហោប៉ៅអាវធំមក ហើយហុចទៅប៉ូលីសដោយប្រាប់ថា :

— សូមលោកយកលុយនេះ ទៅឲ្យគ្នាផង ចុះ ៗ

“ដើរបណ្ដើរ ខ្ញុំពិចារណាបណ្ដើរ ប៉ុន្តែខ្ញុំ សឹងតែខ្លាចមិនហ៊ានគិតប្រមូលមើលមកខ្លួនឯង ផង ៗ ខ្ញុំក៏ខុកព្រឹត្តិការណ៍ដែលមានពីមុន ៗ មក ទាំងប៉ុន្មានដោយខ្សែកសិន ហើយខ្ញុំសួរខ្លួនឯងថា “តើអាគ្នាអញ ចង់ឲ្យន័យទៅលុយមួយកាប់នោះ យ៉ាងណាអញ្ចេះ? ជាស្ពានឬ? តើអាគ្នាអញបាន វិនិច្ឆ័យអ្នករត់ដៃកែរនោះត្រឹមត្រូវទេ ?” ខ្ញុំមិន អាចនឹងរកចម្លើយមួយឲ្យពេញចិត្ត ចំពោះសំនួរ ទាំងនេះបានសោះ ៗ

“ខ្ញុំរមែងតែគិតទៅឧប្បត្តិហេតុនោះជា រឿយ ៗ ៗ ឧប្បត្តិហេតុនោះធ្វើឲ្យខ្ញុំមានសេចក្ដី ក្លាហាននឹងពិនិត្យមើលមកខ្លួនខ្ញុំជាញឹកញាប់ ទោះបីការពិនិត្យនេះ នាំឲ្យតែខ្ញុំលំបាកចិត្តយ៉ាង ណាក៏ដោយ ៗ កិច្ចការខាងនយោបាយនិងខាង យោធាក្នុងប៉ុន្មានឆ្នាំក្រោយៗនេះ ខ្ញុំនៅនឹកឃើញ មិនលើសពីខ្ញុំនឹកឃើញសៀវភៅដែលខ្ញុំបាន សិក្សាកាលនៅពីក្មេងទេ ប៉ុន្តែ បុព្វហេតុដ៏តូចនេះ វិញ វាចេះតែហើរពីមុខខ្ញុំជានិរន្តរ៍ ៗ សព្វថ្ងៃនេះ ខ្ញុំមើលឃើញឧប្បត្តិហេតុនោះ ច្បាស់ជាងនៅ ពេលដែលឧប្បត្តិហេតុនោះ កំពុងតែប្រព្រឹត្ត ទៅទៀត ហើយឧប្បត្តិហេតុនោះបង្រៀនខ្ញុំឲ្យ ចេះខ្មាសខ្លួនឯង ជម្រិតខ្ញុំឲ្យខំកែខ្លួន ហើយ ធ្វើឲ្យខ្ញុំមានសេចក្ដីក្លាហាន និងសេចក្ដីសង្ឃឹម ខ្លាំងឡើង ៗ ៗ

★

លោក លូ ស៊ុន បន្ទាប់ពីបានយកទេព កោសល្យនិងជីវិតលោក បូជាវប្បធម៌ជាតិលោក បូជាមាតុភូមិនិងប្រជាពលករចិន អស់ប្រមាណ ២០ ឆ្នាំមក ក៏បានទទួលអនិច្ចកម្មនៅខែត្រ ស៊ាំងហៃ ក្នុងឆ្នាំ ១៩៣៦ ក្នុងជន្មាយុ ៥៥ ឆ្នាំ ៗ

រូបលោកបាត់ទៅ ប៉ុន្តែស្នាដៃលោកនិង គំនិតរបស់លោក ព្រមទាំងទស្សនៈរបស់លោក ហើយនិងកិត្តិស័ព្ទរបស់លោកស្ថិតនៅជានិច្ច ៗ លក្ខណៈដែលលោកបានតស៊ូឲ្យអក្សរសាស្ត្រចិន មាននោះ ផ្លូវដែលលោកបានតស៊ូត្រួសត្រាយឲ្យ វប្បធម៌ចិនដើរនោះ សង្គមជាតិចិនដែលលោក បានតស៊ូកែប្រែឲ្យទៅតាមឧត្តមគតិលោក - ឧត្តម គតិប្រជាពលករនោះ សព្វថ្ងៃនេះ ប្រជាពលករនៃ ប្រទេសចិនប្រជាមានិត បានសំរេចអស់ហើយ ហើយកំពង់តែចំណានឡើងខ្ពស់ទៅទៀត ៗ

នៅប្រទេសចិន មានឧទ្យានមួយយ៉ាងធំ ដែលមានរូបសំណាកមួយនៅចំកណ្ដាល បាន ត្រូវរដ្ឋាភិបាលប្រជាមានិតចិន រៀបចំសាងឡើង ដើម្បីរំលឹកដល់គុណូបការៈនៃអ្នកនិពន្ធរបស់ប្រជាពលករនេះឈ្មោះ "ឧទ្យាន លូស៊ុន ។"

## បុរាណសុភាសិតដែលត្រូវគិត

១– កុំទុកចិត្តបរទេស កុំទុកចិត្តអក៏នៃស្រក៍ កុំទុកចិត្តអកិប្រាយ ។

២– កុំពន្យល់មនុស្សព្រហើនក្មេងពាលា ឬមនុស្សខុសលទ្ធិគ្នាជាដាច់ខាត គេមិនស្ដាប់ត្រាប់ត្រង់យកមកជាការ៏ គេឆ្លើយបាទបាទតែមាត់ចិត្តដោយខ្លួន ។

៣– កុំពោលពាក្យមុសា – រាក់ចាឲ្យមានហ្មង • បំពួកសត្រូវធំ តែងយកទោសនៃអាត្មា ។

៤– កុំតាមគេដោយឥតគ្នេរពិចារណា ឲ្យច្បាស់ការដើរជ្រៅរាក់ជាក់ជាមុន បេះតែរុលជ្រុល ខ្លួនចូលពាល់តែស៊ុន ទឹងខាតខ្ទួនព្រោះតែព្រើលមិនមើលការ ។

៥– កុំគិតធ្វើអំពើអ្វីតាមកំហឹង ត្រូវតែប្រឹងធ្វើតាមច្បាប់ទៅវិញជា គិតតែយកកំហឹងមក ធ្វើជាគ្នា កិច្ចការផងនោះនឹងកើតទៅជាទោស ។

៦– កុំកាត់ប្រឡោះបុះតែខ្លួន កុំពួនប្រឡូករកកិច្ចកល កុំគិតវង្វៀសគេដោយឆ្ងល់ ចង់ឆ្ងាញ់ ត្រូវស្គាល់រសជាតិល្អ ។



# La situation

# de notre Faculté des Sciences

Im Saroeun

En ce début de l'année scolaire où le problème de l'enseignement et celui des professeurs ont été fréquemment évoqués, et en cette période où la Science et la Technique viennent de faire à l'homme des prouesses extraordinaires, il ne serait pas mal venu de parler d'un domaine peu connu de notre enseignement la Facultés des Sciences et de la Technique de Phnom-Penh.

Notre faculté vient d'entrer dans sa 4e année d'existence. Comme son nom l'indique, c'est un établissement d'enseignement supérieur des Sciences et de la Technique. Mais en vérité, le programme est calqué sur celui des Facultés de France où le côté technique est exclu. A son entrée dans la faculté, l'étudiant aura à choisir entre trois options (MGP, MPC, SPCN)[1]. correspondant aux trois ordres des sciences: Mathématiques, Physique, Chimie, et Sciences naturelles. Il faut signaler qu'il existe une autre option, la PCB (Phisique, Chimie et Biologie), destinée à donner une base de sciences générales aux futurs étudiants en Médecine. Le premier objectif des étudiants en sciences est la Licence. Au-delà de la licence, il y a le Doctorat.

Pour la licence, la durée moyenne des études est de 4 ans.

Que feront les licenciés ?—En général, ils exerceront dans les établissements d'enseigne-

1.— MGP: Mathématiques Générales et Physique.
MPC: Mathématiques, Physique et Chimie.
SPCN: Sciences Physique, Chimique et Naturelle.

ment secondaire. Certains iront dans la Recherche, préparant en même temps le Doctorat. D'autres choisiront l'industrie. Ceci ne manque pas de surprendre quelques-uns de nos lecteurs. En effet, nous sommes à l'époque où la Science et la Technique doivent collaborer pour progresser ensemble. Avec les machines à calculer, les mathématiciens sont recherchés pour la programmation. L'avènement de la pétrochimie ouvre la voie de l'industrie aux chimistes. Les semi-conducteurs, les produits ferromagnétiques .... créent des emplois pour les physiciens. La course au pétrole absorbe bon nombre de géologues. Et dans les laboratoires privés de physique nucléaire, les licenciés de toutes branches de sciences sont demandés.

Il est évident toutefois que dans notre pays, l'Industrie et la Recherche sont encore à un degré assez bas, et nos futurs licenciés n'auront pour le moment que la possibilité d'être professeurs.

★

Où en est notre faculté, à l'heure actuelle? — Jeune, elle a à affronter des maux de croissance. N'ayant pas de locaux, ni de laboratoires propres, elle emprunte ceux des autres établissements: la Faculté de Médecine, l'Ecole des aides-chimistes, et surtout l'Institut National Pédagogique où d'ailleurs elle installe son secrétariat. Toutefois, un plan de construction a été approuvé et attend d'être réalisé.

L'effectif du personnel enseignant croît constamment et est passé de trois (Français) lors de sa création à douze (dont 5 Français et 7 Cambodgiens) cette année.

En ce qui concerne les étudiants, le tableau suivant nous donne un aperçu sur l'évolution de leur effectif et de leurs résultats :

| Options | Année | Inscription aux cours | Inscrits aux examens | Accès aux examens |
|---|---|---|---|---|
| P C B | 1959-60 | 13 | 11 | 6 |
| | 1960-61 | 34 | 31 | 24 |
| | 1961-62 | 46 | 37 | 32 |
| | 1962-63 | 48 | | |
| S P C N | 1959-60 | 0 | | |
| | 1960-61 | 0 | | |
| | 1961-62 | 16 | 4 | 2 |
| | 1962-63 | 18 | | |
| M P C | 1959-60 | 0 | | |
| | 1960-61 | 17 | 6 | 3 |
| | 1961-62 | 55 | 6 | 2 |
| | 1962-63 | 9 | | |
| M G P | 1959-60 | 0 | | |
| | 1960-61 | 0 | | |
| | 1961-62 | 0 | | |
| | 1962-63 | 34 | | |

En PCB, l'effectif est assez important et croît constamment. La proportion des inscrits aux examens et des succés est nettement élevée. Cela tient en partie au programme, mais surtout à la régularité et la stabilité du travail des étudiants qui se sont bien fixés dans le choix de leur futur métier.

En S P C N, l'effectif est un peu maigre. La proportion des reçus aussi. Il semble que cette branche n'intéresse encore pas beaucoup de nosjeunes.

En M P C, ce n'est guère mieux. L'an dernier, on a assisté à une désertion en masse, due à l'ouverture de l'Ecole Nationale d'Ingénieurs des Travaux Publics. L'année 1962—63 marque un recul, dû cette fois - ci à la création d'une 3ème option : le M G P.

En bref, le nombre de nos étudiants se destinant à la licence des sciences reste faible et insuffisant. Il y a plusieurs raisons à cela, dont les principales sont :

1o— Nos bâcheliers ne sont pas très attirés par le professorat. S'ils veulent être professeurs, ils entrent directement à l'Institut National Pédagogique ( pour des raisons pécuniaires immédiates ).

2o— Le métier d'ingénieur ou de médecin plait davantage à nos jeunes ( Sur une classe de Math. Elem de 40 élèves, plus de la moitié veut être ingénieurs ).

3o— Les bourses à l'étranger sont nombreuses et alléchantes.

4o— La peur que les cours de licence ne s'étendent pas rapidement jusqu'à la fin de leur cycle. Cette incertitude constitue un obstacle majeur au développement de la Faculté du fait qu'un cercle vicieux en résulte: il n'y a pas de cycle complet parce qu'on ne dispose pas d'assez étudiants, et il n'y a pas d'étudiants parce qu'il n'y a pas de cycle complet.

Pour remédier à la pénurie des étudiants en Sciences, le gouvernement cherche à les encourager par tous les moyens. D'abord en créant des bourses ( bourses mensuelles de 1.700$00), ensuite en faisant un projet qui autoriserait les meilleurs élèves sortant de l'I N P de suivre ensuite les cours de Faculté. Dernièrement, sur la demande de l'Association des Professeurs Khmers, des Professeurs sortant de l'IN P et titulaires des Certificats de Propédeutique ( MPC, SPCN, Propédeutiques lettres ) se sont vu accorder la faveur d'enseigner dans la capitale afin qu'ils puissent continuer de suivre les cours des facultés. Cette année, la création du certificat de M G P complète la gamme des choix pour les étudiants. Et pour résoudre le 4e point ci-dessus énuméré, la création des certificats de licence ( Electricité, Chimie Minérale, Technique mathématique de la Physique ) a été décidée.

★

Est - ce que ces remèdes porteront leur fruit? — Nous en sommes certains. Néanmoins, il est encore trop tôt pour conclure à leur efficacité totale. L'expérience a montré des abandons déconcertants en cours d'année. Il semble qu'en plus des causes précitées, ces abandons aient des racines plus profondes que nous

n'analyserons pas en détail ici. En gros, disons que nos jeunes préfèrent la Technique aux Sciences pures: soit par ce que la Technique est passionnante en elle-même, soit parce qu'elle rapporte davantage à leurs yeux, soit parce que les sciences pures n'ont pas de perspectives d'avenir pour eux (il n'y a pas encore chez-nous de la vraie recherche) ni dans les établissements officiels, ni dans le privé). D'autre part, il semble que beaucoup d'esprits se refusent à cette abstraction totale des sciences pures et préfèrent le concret de la Technique. Et la pédagogie moderne, se plaçant dans ce contexte que le monde actuel est technique, s'inspire beaucoup de cette réalité. Comme la technique n'avance pas sans la science, on essaie au maximum d'associer les deux ensembles. Deux hommes volent dans l'espace. Cet évènement scientifique remarquable ne paraît ni passionner, ni même émouvoir nos jeunes. Il n'y a pas cet émerveillement devant le progès de la Science et de la Technique, cet intérêt, cette curiosité qu'on trouve chez les jeunes de certains autres pays. Ceci est propre à beaucoup de pays qui, comme le nôtre, sont en voie de développement. Et le problème à résoudre pour nous est justement là, de créer et développer une atmosphère technique et scientifique. Tout comme le twist, la Science et la Technique ont besoin d'une ambiance. Où créer cette ambiance, si ce n'est sur les bancs de notre faculté. Dans les pays techniquement évolués, cette nécessité paraît moins évidente, car les moyens d'information sont assez puissants pour exciter la curiosité et l'enthousiasme des jeunes : radiodiffusion, télévision, cinéma documentaire, presse, revues (spécialisées et de vulgarisation), expositions, visite ...., et même les usines et les objets qui entourent les jeunes.

L'on en vient alors à se demander si chez nous il faut enseigner comme dans les pays ayant un degré technique et scientifique élevé, si nous ne devons pas essayer de repenser notre programme pour l'adapter à notre pays, à esprit même qu'implique cette dénomination: «Faculté des SCIENCES et de la TECHNIQUE».

# ★ អាកប្បកិរិយារឹងរុះរបស់សាស្ត្រាចារ្យបរទេសខ្លះ

ដំណឹងមួយតាមកាសែតឡាដេប៉ែស (La Dépêche) លេខ ១៤៩២ ចុះថ្ងៃអង្គារ ទី ១៨ កញ្ញា ១៩៦២ បានធ្វើឲ្យមជ្ឈដ្ឋានសាស្ត្រាចារ្យយើង ចាប់អារម្មណ៍ជាខ្លាំង ចំពោះការរឹងរុះប្រកែករបស់សាស្ត្រាចារ្យបារាំង នៅអនុវិទ្យាល័យព្រះនរោត្តម មិនព្រមឲ្យគណៈប្រតិភូសាធារណៈសិក្សាធិការសូវៀតចូលមើលថ្នាក់ខ្លួន ៗ តាមពាក្យដែលគេនិយាយក្រៅផ្លូវការ ដោយការសាកសួររបស់យើង ជាសាស្ត្រាចារ្យបារាំងបួននាក់បានបញ្ចេញអាកប្បកិរិយាយ៉ាងឃ្លើនខ្លាំងជាងគេ នៅពេលដែលអ្នកស្រីចាងហ្វាងសាលា ប្រាប់ថាមានគណៈប្រតិភូសូវៀតមកមើលថ្នាក់ ៗ សាស្ត្រាចារ្យស្រីបារាំងម្នាក់បានសួរយ៉ាងគំរោះគំរើយថា "មានសូមសេចក្ដីអនុញ្ញាតពីស្ថានទូតបារាំងហើយឬនៅ ដែលនាំគេឲ្យមក "ត្រួតពិនិត្យ" ថ្នាក់ខ្ញុំនេះ ?" ម្នាក់ទៀតមានពាក្យពោលសំដីថា "មិនត្រូវឲ្យជនក្រហមមកជាន់ទឹកដីខ្ញុំនេះទេ . . . ។ល។"

ពាក្យសំដីបែបនេះប្រហែលជាពិតអញ្ចឹងមែន បានជាអធិករណ៍នេះមានលក្ខណៈតឹងតែងនៅដល់សព្វថ្ងៃ ។ គណៈប្រតិភូគ្រូបង្រៀនសូវៀតបានមកទស្សនាប្រទេសយើង គឺក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងខាងវប្បធម៌ រវាងប្រទេសកម្ពុជា និងសហភាពសូវៀត ។ គេពុំបានសូមទៅមើលថ្នាក់គ្រូបារាំងបង្រៀន នៅអនុវិទ្យាល័យព្រះនរោត្តមទេ តែគឺក្រសួងអប់រំជាតិយើងទេតើ ដែលរៀបចំកម្មវិធីជូនឲ្យគេទៅទស្សនាយ៉ាងនេះ ប្រហែលជាក្នុងគោលបំណងផ្លាស់ប្ដូរការពិសោធន៍ខាងគរុកោសល្យទេ ពុំមែនទៅ "ត្រួត" ដាក់ពិន្ទុសិក្សា ទៀងហានន្ទរៈស័ក្ដិឯណា !

តាំងតែពីដើមមក មានគណៈប្រតិភូអ្នកបច្ចេកទេសខាងអប់រំពីសហរដ្ឋអាមេរិក ពីប្រទេសជប៉ុន ពីប្រទេសបារាំង មកទស្សនាសាលាមធ្យមសិក្សានានា ក្នុងព្រះរាជាណាចក្រយើងជាហូរហែមកដែរ ប៉ុន្តែពុំដែលមានអធិករណ៍យ៉ាងនេះ ជាមួយនឹងសាស្ត្រាចារ្យបារាំងសោះឡើយ ។ លុះអ្នកបច្ចេកទេសគរុកោសល្យសូវៀតមកទស្សនាម្ដង ម្ដេចក៏មានរឿង ? តើសាស្ត្រាចារ្យបារាំងទាំងនេះ បានរៀបចំដោយចេតនា ឲ្យមានឧប្បត្តិហេតុនេះឡើង គ្រាន់ជាអាម៉ាស់មុខដល់ខ្មែរឬអ្វី ? ម្ដេចក៏ចាំឲ្យ

រាជរដ្ឋាភិបាលខ្មែរ សូមច្បាប់ស្ថានទូតបារាំងសិន ទើបចូលមើលថ្នាក់ខ្លួនបាន ? តើសាស្ត្រាចារ្យបារាំងនេះ ចង់ស្មានតែខ្មែរនៅក្នុងសម័យអាណានិគមនៅឡើយឬអ្វី ? សព្វថ្ងៃខ្លួនបើកបៀវត្សពីខ្មែរ តើខ្លួនស្គាល់បង្គាប់ខ្មែរឬទេ ? បើខ្លួនស្អប់ "ក្រហម" ក៏ស្អប់តែក្នុងពោះទៅចុះ ដ្បិតនេះជាសេរីភាពខាងជំនឿរបស់ខ្លួន ដូចតែអ្នកខ្លះគេស្អប់ "ខៀវ" អញ្ចឹងដែរ ប៉ុន្តែប្រទេសកម្ពុជាឯករាជអព្យាក្រឹតមានប្រពៃណីដ៏ថ្លៃថ្នូរក្នុងការទទួលភ្ញៀវជាតិដោយរាក់ទាក់ ពុំមានរើសអើងថាជាជាតិណា ពណ៌ណាឡើយ គួរណាស់តែសាស្ត្រាចារ្យបារាំងទាំងនេះគោរពកិត្តិយសជាតិយើង តែប៉ុណ្ណោះផងទៅចុះ !

យើងបានដំណឹងតមកទៀតថា សាស្ត្រាចារ្យបារាំងមួយក្រុម នៅអនុវិទ្យាល័យជ័យវរ្ម័នទី ៧ នៅដីអង្គក៏មិនជាស្រួលដែរ ធ្លាប់តែធ្វើតាមទំនើងចិត្ត ពុំសូវគោរពការដឹកនាំរបស់ចាងហ្វាងសាលានោះ ។ ក្នុងឱកាសដែលគណៈប្រតិភូសូវៀតដដែលនេះ ទៅទស្សនាសាលា សាស្ត្រាចារ្យបារាំងក្រុមនេះ ចង់រករឿង "បញ្ចេញចង្កូម" ទៀត (សូមអានកាសែតមាតុភូមិចុះថ្ងៃ ១៩ កញ្ញា ១៩៦២) ដែលបានអធិប្បាយរឿងនេះយ៉ាងក្បោះក្បាយ ។

សាស្ត្រាចារ្យខ្មែរជាច្រើន ឲ្យយោបល់ថា សាស្ត្រាចារ្យបារាំងទាំងប៉ុន្មាននាក់នោះ ដែលបានប្រព្រឹត្តកំហុសយ៉ាងធំដូចនេះ សមតែផ្លាស់ចេញពីទឹកដីខ្មែរ ឬមួយបញ្ជូនទៅស្រុកគេវិញទៅ ។ ប៉ុន្តែចំពោះការដោះស្រាយ យើងសូមទុកចិត្តទាំងស្រុង លើព្រះរាជរដ្ឋាភិបាលដើម្បីរក្សាសេចក្តីថ្លៃថ្នូររបស់ជាតិយើង ។ ចំណែកគណៈប្រតិភូបច្ចេកទេសគរុកោសល្យសូវៀត ដែលបានទស្សនាវិទ្យាល័យព្រះស៊ីសុវត្ថិ វិទ្យាស្ថានជាតិគរុកោសល្យ វិទ្យាល័យ និងអនុវិទ្យាល័យ នៅខេត្តកំពង់ឆ្នាំង កំពង់ចាម កំពង់ធំ និង សៀមរាប គេបានទទួលស្វាគមន៍យ៉ាងរាក់ទាក់និងយ៉ាងសមរម្យ អំពីសំណាក់សិក្សាធិការយើង ហើយយើងជឿជាក់ថា គេនឹងរក្សាអនុស្សាវរីយ៍មួយដ៏ល្អប្រសើរអំពីប្រទេសកម្ពុជាយើងពុំខាន ។

★

ពុំថានៅវិទ្យាល័យព្រះយុគន្ធរ មានសាស្ត្រាចារ្យអាមេរិកាំងម្នាក់ ដែលរដ្ឋអាមេរិកបានផ្តល់ជាជំនួយដល់សិក្សាធិការជាតិយើង ក៏ពុំសូវស្គាល់ការដឹកនាំរបស់នាយកសាលាប៉ុន្មានដែរ ។

នៅពេលដែលរដ្ឋទូតខ្លួន ប្រើឲ្យជូនអ្នកជំនាញអាមេរិកាំងទៅទស្សនាខែត្រក្រៅ ខ្លួនក៏ទៅបាត់ទៅ ដោយគ្មានប្រាប់ គ្មានសូមច្បាប់នាយកដ្ឋានមួយម៉ាត់សោះ ។ លុះនាយកហៅមកសួរ គេឆ្លើយថា "រដ្ឋទូតគេប្រើឲ្យចេញទៅខែត្រក្រៅ ម្ដេចក៏ដំរូវឲ្យគេធ្វើពាក្យសូមច្បាប់ទៀត ? នាំតែខាតក្រដាស" ។ មើលទៅ ប្រហែលជាគេយល់ថា គេបើកបៀវត្សពីរដ្ឋការជាតិគេ គេស្ដាប់បញ្ជារតែពីទូតគេតែម្យ៉ាងប៉ុណ្ណោះ ។ ចុះដែលរដ្ឋការគេផ្ដាច់ឲ្យមកធ្វើការក្រោមបង្គាប់ខ្មែរនោះ តើគេទទួលគោរពបង្គាប់ខ្មែរដល់កំរិតណា ?

រឿងនេះតូចតាចទេ ប៉ុន្តែយើងលើកមកនិយាយគ្រាន់តែជាមេរៀនដល់មិត្តយើង ដែលដឹកនាំវិទ្យាល័យ-អនុវិទ្យាល័យថា ៖ បុគ្គលិកបរទេសដែលធ្វើការក្រោមបង្គាប់យើង ត្រូវតែស្ដាប់យើង ទោះជាអ្នកនោះទទួលបៀវត្សពីរាជការយើងក្ដី ពីរដ្ឋការគេក្ដី ពុំនោះសោត មុខតែប្រទូកប្រទាំក្នុងការដឹកនាំជាពុំខាន ។ បើរដ្ឋការ ឬ រដ្ឋទូតអ្នកនោះត្រូវការប្រើខ្លួន គេគង់តែសូមច្បាប់ដល់ក្រសួងអប់រំជាតិយើងសិន ទើបយើងអនុញ្ញាតឲ្យបាន ។ បើអ្នកនោះធ្វើអ្វី ៗ តាមតែទំនង "ក្បាលចិត្ត" ខ្លួននោះ គប្បីស្នើសូមឲ្យដកចេញពីសាលា ឬ ក៏បញ្ជូនគេឲ្យទៅស្រុកដើមវិញចុះ ។



## មិត្តអ្នកអាន!

មិត្តនឹងច្បាស់ជាបានជួយគណៈកម្មាធិការ ជាប្រាកដ បើមិត្តបញ្ចេញមតិប្រាប់យើង ពីការពេញចិត្ត និង មិនពេញចិត្តរបស់មិត្ត ចំពោះអត្ថបទណា ហើយនឹងសូមសំណូមពររបស់មិត្ត ចំពោះអត្ថបទបែបណាទៀត ។

# ដំណើរទស្សនកិច្ច



## សន្និសិទស្តីអំពី

## វប្បធម៌និងអក្សរសាស្ត្រ

## នៅសហភាព សាធារណរដ្ឋ សង្គមនិយម សូវៀត

ដោយលោក លាង ហាប់ អាន

(សង្ខេប សន្និសិទដែលលោក លាង ហាប់ អាន លេខាធិការ នៃក្រុមអភិបាលសមាគមអ្នកនិពន្ធខ្មែរនិងសមាជិកនៃគណៈកម្មាធិការនាយក របស់សមាគមសាស្ត្រាចារ្យខ្មែរ បានធ្វើជាទីសណ្តាប់ដល់សាស្ត្រាចារ្យនិងនិស្សិតសាស្ត្រាចារ្យ ៣៣៤ រូប ពីថ្ងៃ ១១ កក្កដា ១៩៦២ បន្ទាប់ពីទស្សនកិច្ច ដែលលោកបានធ្វើជាមួយនឹងគណៈប្រតិភូអ្នកនិពន្ធខ្មែរ នៅសហភាពសូវៀត ចំនួន ៣ សប្តាហ៍ គឺពីថ្ងៃ ១ ដល់២១-៥-៦២)

★

អស់លោក-អ្នក,

មិត្តជាទីគោរព,

មុននឹងចូលទៅដល់កម្មវត្ថុ នៃសន្និទរបស់ខ្ញុំ ខ្ញុំសូមជំរាបបន្តិច ពីទិដ្ឋភាពនៃមហាប្រទេសនេះ ។

### I_ភូមិសាស្ត្របន្តិច

សហភាព សាធារណរដ្ឋ សង្គមនិយម សូវៀត (ស.ស.ស.ស U.R.S.S) ឋិតនៅក្នុងទ្វីបអាស៊ីផង អឺរ៉ុបផង ហើយកើតឡើងដោយសាធារណរដ្ឋសហព័ន្ធ (Républiques fédérées) ចំនួន ១៥ និងសហភាពស្វយ័ត ១៨ (Républiques autonomes) ។

ផ្ទៃដីមាន ២២,៤ លានគីឡូម៉ែត្រក្រឡា គឺ ១/៦ នៃផ្ទៃពិភពលោក (ប៉ុនសហរដ្ឋអាមេរិក ៣ ដង,

ប្រទេសឥណ្ឌៀ ៧ ដង, ជប៉ុន ៦០ ដង, ហុល្លង់ ៧០០ ដង, កម្ពុជាយើង ១២៣ ដង) ។

អាកាសធាតុប្រែប្រួលទៅតាមតែតំបន់ ៗ មានដល់ទៅ ៧០ អង្សាក្រោមសូន្យ នៅកលស៊ីបេរី (Sibérie) ហើយដល់ទៅ ៥០ អង្សាលើសូន្យ នៅតំបន់ធែរម៉េស (Thermez) ។

ប្រជាជនមាន ២០៨,៨២៦ លាន នាក់ (តាមការជំរឿន ឆ្នាំ ១៩៥៩) ហើយក្នុងមួយឆ្នាំ ៗ កើនបាន ៣,៥ លាននាក់ ។ មានសាសន៍ជាង ១០០ (ក្នុងចំណោមនេះ សាសន៍រុស្ស៊ី អ៊ុយក្រេន បេឡូរុស្ស៊ី អ៊ូសបែក និងតាតារ មានមនុស្សច្រើនជាងគេ) ។

## II - អំពីវប្បធម៌និងអក្សរសាស្ត្រ

នៅសហភាពសូវៀត សាធារណរដ្ឋសហព័ន្ធនិងស្វយ័តទាំងឡាយ សុទ្ធតែមានវប្បធម៌ពិសេសរៀង ៗ ខ្លួន ដូចជាប្រទេសនិមួយ ៗ ដែរ ។ សាធារណរដ្ឋ Ouzbékistan, Russie និង Géorgie ដែលខ្ញុំបានទៅទស្សនា និងស្នាក់នៅ គេមានវប្បធម៌ (ភាសា អក្សរសាស្ត្រ សិល្ប ទំនៀមទំលាប់ ជំនឿផ្សេង ៗ ពីគ្នា) ។

### ១– អំពីភាសានិងអក្សរសាស្ត្រ



ភាសានិងអក្សរ មានចំនួនស្មើគ្នានឹង ជាតិសាសន៍ (ជាង ១០០) គឺមានរហូតដល់ទៅជាតិសាសន៍ភាគតិច ដែលរស់នៅដោយក្នុងក្រុមបន្ទៀតផង ។ ដើម្បីងាយក្នុងការទាក់ទងគ្នា គេបានយកភាសា Russe ធ្វើជាយានភ្ជាប់ ប៉ុន្តែភាសាជាតិនិមួយ ៗ ត្រូវជាតិគេនិយមជាបឋម ហើយរៀនតាំងពីបឋមសិក្សាទៅ ។ ឯឈ្មោះនៃសាលារៀន គ្រឹស្ថានជំនួញ ឬគ្រឹស្ថានពាណិជ្ជការ ... សុទ្ធតែសរសេរជាអក្សរជាតិគេផង ៗ ពីលើហើយនិងអក្សរ Russe តូច ៗ ពីក្រោម ។ សៀវភៅរៀន ក្បួនខ្នាតផ្សេង ៗ និងកាសែត ក៏សរសេរជាភាសានៃសាធារណរដ្ឋមួយ ៗ ដោយឡែកដែរ លើកលែងតែសំរាប់ផ្សាយក្នុងសហភាពទូទៅ ។ ក្នុងករណីនេះ

គេប្រែជាភាសាផ្សេង ៗ ទៅតាមសារៈសំខាន់នៃស្នាដៃនោះ ៗ ។

សហភាពអ្នកនិពន្ធគេ (Union des Ecrivains) បានប្រាប់ខ្ញុំថាអក្សរសាស្ត្រគេបានរីកចំរើនជាអតិបរមា នៅក្នុងសៈធារណរដ្ឋនិមួយ ៗ ។

ក)- សៀវភៅដែលសហភាពសូវៀតបានបោះផ្សាយ មានបរិមាណ ១/៤ នៃពិភពលោក.

— ក្នុងឆ្នាំ ១៩៦១ បានផ្សាយសៀវភៅគ្រប់យ៉ាង ៧៤.០០០ មុខ សរុបទៅមាន ១.១២០.០០០.០០០ ក្បាល,

— ពី១៩៤៦ មកទល់នឹង ១៩៦១ មានផ្សាយជា ៧៣ ភាសាក្នុងស្រុក, ហើយប្រែទៅជាភាសាបរទេស ៤៧ ភាសា,

ខ)- កាលពីដើមឆ្នាំ ១៩៦២ គ្រឹស្តានពាំងឡាយបានផ្សាយកាសែតចំនួន ៩.១១១ បែបផ្សេង ៗ គ្នា,

— ក្នុងឆ្នាំ ១៩៦១ មានកាសែតតំបន់ (Journal de district) ចំនួន ៣.២៣៩ យ៉ាង ។ ឯកាសែតកណ្តាល (Presse centrale) មានសំខាន់ៗគឺ: — Izvestia ផ្សាយមួយលេខ ៗ ជាង ៤ លានក្បាល, Sovietskaïa Rossia ២ លានក្បាល, Troud ១,៥ លាន ។ (ជា ៥៩ ភាសាក្នុងស្រុក នឹងជា ៧ ភាសាបរទេស)

—ទស្សនាវដ្តី មានខាងនយោបាយ សេដ្ឋកិច្ច អក្សរសាស្ត្រនឹងសិល្បៈ ។ ពីដើមឆ្នាំ ១៩៦២ នេះ ទស្សនាវដ្តីមានដល់ទៅ ៩៥០ មុខ, ចេញប្រចាំខែមាន ៤១២១ យ៉ាង ។

គ)- ទស្សនាវដ្តីយុវជន ក្រៅពីផ្នែកអប់រំ មានរឿងរ៉ាវ ៗ (Nouvelles) រឿងប្រឌិត ប្រលោមលោក សំរាប់យុវជននឹងកុមារ កំណាព្យ ។ល។ មាន ១៣០ យ៉ាង ។ ក្នុង១ លេខ ៗ ចេញផ្សាយម្តងជិត ៨ លានក្បាល ។

— Pionerskaïa Pravda ចេញ ១ លេខ ៗ ៤ លានក្បាល ។

— កាសែតអប់រំកូនយុវជន (Pionnier) ចេញជាទូទៅមួយលេខ ៗ លើសពី ៧,៥ លានក្បាល ។

ឃ)- ក្នុងមួយឆ្នាំ ទស្សនាវដ្តីស្ត្រី ផ្សាយ ៨០,៦ លានក្បាល ។

ង)- មានកាសែតខ្លះ ចេញផ្សាយតាមសហគ្រាសធំ ៗ ការដ្ឋានសំខាន់ ៗ វិទ្យាស្ថាន ឬ Kolkhoze ។ ក្នុងដើមឆ្នាំ ១៩៦២ នេះ មាន

៤.៧៩៧ យ៉ាន់ (ក្នុងនេះមាន ២៥០០ យ៉ាន់ ផ្សាយក្នុង Kolkhoze) ។ មួយលេខ ១ ៦ លានក្បាល ។

## ២– អំពីការសិក្សា

នៅសាកលវិទ្យាល័យ Lomonossov នៅម៉ូស្គូ (ស្ថាបនាពី ឆ្នាំ ១៧៥៥) នឹងវិទ្យាស្ថានអប់រំអ្នកនិពន្ធ Gorki ដែលខ្ញុំបានទស្សនា គេបានរៀបរាប់ពីវឌ្ឍនភាព ក្នុងសិក្សាធិការ ដូចតទៅ :



### ក) ការសិក្សាទូទៅ

តាំងពីឆ្នាំ ១៩២០ មកទល់នឹង ១៩៣៥ មានមនុស្ស ៥០ លាននាក់ចេះអាននឹងសរសេរ ។ មកដល់ឆ្នាំ ១៩៣៩ អ្នកចេះអាននឹងសរសេរឡើងដល ៩១ ភាគរយ ហើយតាំងពីពេលនោះមក បញ្ហាមិនចេះអក្សរ លែងចោទទៀតហើយ ។ សមាជទី ៨ កាលពីឆ្នាំ ១៩១៩ បានកំរិតឲ្យ " ការសិក្សា ត្រូវប្រព្រឹត្តទៅដោយឥតយកថ្លៃ ហើយជាការចាំបាច់ ។ ការសិក្សាត្រូវធ្វើជាភាសាជាតិ (សំរាប់សាធារណរដ្ឋនីមួយ ៗ) ហើយសំដៅទៅលើការអប់រំចរិយាមារយាទ នឹងកិច្ចការសំរាប់អនាគតរបស់ក្មេង ដែលនឹងបំពេញមុខងារក្នុងសង្គមសូវៀត" ។

កាលពីឆ្នាំ ១៩៣០ ដល់ ១៩៣៥ ការសិក្សាបានកំណត់ត្រឹម ៧ ឆ្នាំ ។ លុះមកដល់រយៈ ១៩៥០-១៩៥៥ ការសិក្សាត្រូវបន្ទាយដល់ ១០ ឆ្នាំ យ៉ាងតិច ។ កាលពីឆ្នាំ ១៩១៤ គ្រូនឹងសាស្ត្រាចារ្យមានចំនួនត្រឹមតែ ២៨០.០០០ នាក់ប៉ុណ្ណោះ ។ លុះមកដល់ឆ្នាំ ១៩៥៨ បានឡើងដល់ ២ លាននាក់ ។

### ខ) អំពីអន្តេវាសិកភាព

គេទុកអន្តេវាសិកភាពជាមជ្ឈដ្ឋានសំរាប់អប់រំយុវជន ឲ្យស្រឡាញ់ការងារ តាមពាក្យស្លោក "អ្វីៗ ត្រូវធ្វើដោយខ្លួនឯង„ ។ គេបង្កើតអន្តេវាសិកភាព នៅគ្រប់សាកលវិទ្យាល័យ ។ ក្នុងសាកលវិទ្យាល័យ Lomonossov ដែលមានមហា

វិទ្យាល័យ ១២ (វិទ្យាសាស្ត្រធម្មជាតិ យន្ត និង គណិតសាស្ត្រ រូបសាស្ត្រ គីមី ជីវសាស្ត្រនៃធរណី ភូមិសាស្ត្រ និងធរណីសាស្ត្រ ។ល។) មានបន្ទប់ចំនួន ៥.០០០ សំរាប់ឲ្យសិស្សគ្រប់សញ្ជាតិនៅ ហើយប្រកបទៅដោយផាសុខភាពគ្រប់សព្វ ។ សាកលវិទ្យាល័យនេះមាន ៣៣ ជាន់, កំពស់ ២៤០ម មានទីកំសាន្ត បន្ទប់ហាត់ប្រាណ សាលតន្ត្រី កាពយន្ត ល្ខោន សាលសន្និសីទ សាលតាំងពិពណ៌ស្នាដៃសិស្ស ភោជនីយដ្ឋានបែបសណ្ឋាគារ បណ្ណាគារជាតូច ៗ លក់សៀវភៅទស្សនាវដ្តី កាសែតគ្រប់មុខ និងបណ្ណាល័យធំមួយ សំរាប់សិស្សអាននិងខ្ចីសៀវភៅ ។ (មាន



បណ្ណាល័យធំមួយឈ្មោះលេនីន មានសៀវភៅ ២២ លានក្បាល ជា ១៦០ ភាសា ក្នុងនេះមាន ៨៩ ភាសា នៅ ស.ស.ស.ស ។ មួយថ្ងៃ ៗ អ្នកចូលអាននិងខ្ចីប្ដូសងមានពី ៧ ទៅ ៨ ពាន់នាក់) ។

## គ) សាលាសំរាប់មនុស្សចាស់

សព្វថ្ងៃមានកម្មករ-កម្មការិនី ចំនួន ២ លាននាក់ បានសិក្សានៅក្នុងសាលាបែបនេះ ។

## ឃ) មធ្យមសិក្សាបច្ចេកទេស និង ឧត្តមវិជ្ជា

នៅសហភាពសូវៀត កម្មករ អាចបន្តវិជ្ជារបស់ខ្លួនរហូតដល់ឧត្តមសិក្សាបាន ។

សាកលវិទ្យាល័យធំ ៗ ជាងគេនៅ ស.ស.ស.ស. មាន :

—l'Université Lomonossov នៅម៉ូស្គូមាននិស្សិត ១៥.០០០ នាក់, សាស្ត្រាចារ្យធំៗ ២៤៥០ នាក់ និងមានមហាវិទ្យាល័យ ១២ ។

— L'Université de Léningrad នៅ Léningrad

— L'Université de Kiev នៅ Ukraine

— L'Université de l'Amitié entre les peuples Patrice Lumumba នៅ Moscou

សិស្សនៅមធ្យមសិក្សានិងឧត្តមសិក្សា មានអាហារូបករណ៍ថែមទៀត ។ (និស្សិតខ្មែរ នៅ ស.ស.ស.ស. ជាពិសេសនៅសាកលវិទ្យាល័យ Lomonossov, Patrice Lumumba និង Kiev

ទទួលអាហាររូបករណ៍ក្នុង ១ ខែ ម្នាក់ ៗ ៩០ រូប្លិស (Roubles) (ប្រហែល ៣.៩០០ រៀលយើង) ។

### ៣– អំពីអ្នកនិពន្ធ

គឺមកពីប្រជាករ មានកំរិតវិជ្ជាខ្ពង់ខ្ពស់ដូចនេះ ហើយ បានជាអ្នកនិពន្ធច្រើនតែបានជោគជ័យក្នុងការសរសេរផ្សាយ នូវស្នាដៃរបស់ខ្លួន ព្រោះវាស្របទៅតាមការត្រូវការនៃប្រជាជនផង ទៅតាមប្រយោជន៍នៃប្រទេសជាតិផង ។

អ្នកនិពន្ធច្រើនយកមកធ្វើជានិក្ខេបបទរបស់ខ្លួន នូវបញ្ហាជាក់ស្ដែងនៃជីវភាពរបស់ប្រជាករ កម្មករ ហើយណែនាំអប់រំសំដៅទៅរកសុភមង្គល សេចក្ដីស្នេហា ការស្រឡាញ់ការងារ ការតស៊ូដើម្បីសន្តិភាព ទោះជាក្នុងប្រលោមលោកក្ដី រឿងប្រឌិតក្ដី ល្ខោនក្ដី កំណាព្យក្ដី ។ គឺមកពីអ្នកនិពន្ធបំពេញសេចក្ដីប្រាថ្នារបស់គេ សេចក្ដីត្រូវការរបស់គេដូចនេះហើយ បានជាមហាជនកម្មករស្រឡាញ់អ្នកនិពន្ធគេខ្លាំងម៉្លេះ ហើយទុកអ្នកនិពន្ធជាមាតាបិតាទីពីររបស់គេ ហើយជាអ្នកមានគុណូបការសំខាន់ចំពោះប្រទេសជាតិ ។

គេឃើញតែរូបសំណាកនៃអ្នកនិពន្ធ អ្នកប្រាជ្ញបណ្ឌិត ទស្សនវិទូដ៏ល្បីល្បាញធ្វើអំពីសិលា ឬថ្ម-




កែវយ៉ាងស្អាត ៗ ដូចជាលោក Maxime Gorki, V. Maïakovski, Démian Bedny ជាកវី ៗល ។ ហើយនឹងអ្នកកសាងវប្បធម៌សង្គមនិយមសំខាន់ ៗ ដូចជា Véressaïev នឹង Serguéev Tsenski, Chichkov Prichvine, Téléchov នឹង N. Ostrovski នៅក្នុងមន្ទីររាជការ ក្នុងសារមន្ទីរ បណ្ណាល័យ ឧទ្យានក្រុង មុខគ្រឹស្ថានសិក្សា ឬ នៅផ្លូវកែង ៗ ជុំវិញរូបតាំងនេះ មានបរិវេណស្អាត ១ ហើយមានបូជាផ្កាភ្ញីផង ។

សហភាពអ្នកនិពន្ធ មានសមាជិកទាំងអស់ជាង ៤០០០ នាក់ (គ្រប់សាធារណរដ្ឋ) ។

សហភាពនេះ មានការៈសិក្សាស្រាវជ្រាវរិះគន់អប់រំគ្នា ។ ដូចនេះហើយ បានជាចំណេះវិជ្ជា ការពិសោធន៍ផ្សេង ៗ បានកើនឡើងដោយប្ដូរយោបល់គ្នា ក្នុងវិធីនិងវិជ្ជានិពន្ធ ដែល

ធ្វើឲ្យសៀវភៅនិមួយ ៗ មានខ្លឹមសារជ្រៅជ្រះ ថែមទៀត ៗ ស្នាដៃអ្នកនិពន្ធខ្លះ បានគេយកទៅលេងជាល្ខោន ឬ កុន ៗ អ្នកនិពន្ធនៅសហភាពសូវៀត ជាអ្នកមានជីវភាពហ៊ឺហា មានប្រាក់កាសសំបូរណ៍ជាងគេ ៗ ព្រោះគង់ការផ្សាយស្នាដៃមួយលើក ៗ អ្នកនិពន្ធបានទទួលកំរៃសិទ្ធិជាច្រើនរ៉ូប៊ល (ច្រើនម៉ឺនរៀល) ។

ឧទាហរណ៍: ចាប់ពីឆ្នាំ ១៩១៧ មកដល់ ១៩៥៧ ស្នាដៃលោក M. Gorki បានផ្សាយ ៨៩,២ លានក្បាល; A- Tolstoï ៤១,៣ លាន ៗលៗ

## ៤- អំពីសិល្បៈ កុន ល្ខោន ភ្លេង និងរបាំ

ក) កុន- តាមខ្ញុំបានសួរ គេថានៅមណ្ឌលថត Mosfilms ខ្សែភាពយន្តមិនគ្រាន់តែជាសិល្បៈអប់រំយុវជន យុវនារីប៉ុណ្ណោះទេ តែថែមទាំងជាចំណីអាហារបង្កើនស្មារតី សតិ បញ្ញា ទៀតផង ៗ រឿងសំខាន់ៗ មាន «Le Cuirassé de Potiomkine» (១៩២៥) ដោយលោក S. Eisenstein; «La mère» (១៩២៦) និង «La fin de St. Pétersbourg» (១៩២៧) ដោយលោក V. Poudovkine; «Octobre» ១៩២៨ ដោយលោក S. Eisenstein; «Tempête sur l'Asie» ១៩២៩ ដោយ Poudovkine ៗលៗ

អ្នកលេងកុន ច្រើនតែជាអ្នកលេងល្ខោនយ៉ាងល្បី ៗ ។

គង់ឆ្នាំ ១៩៥៧ ខ្សែភាពយន្ត ១៩ បានទទួលរង្វាន់នៅពេលប្រឡងប្រជែង ៗ គង់ឆ្នាំ ១៩៥៨ រឿង «Quand passent les cigognes» របស់លោក L. Kalatogov បានទទួល Palme d'Or នៅ Festival International de Film à Cannes រឿង «Le destin d'un Homme» របស់លោក Bondartchouk បានទទួល le Grand prix d'Or du Festival.



ខ) អំពីល្ខោន

ល្ខោនបិតនៅក្រោមការត្រួតត្រារបស់គណៈកម្មការរដ្ឋនៃក្រសួងសាធារណសិក្សាធិការ (Commission d'Etat de l'Instruction Publique) ចាប់តាំងពីថ្ងៃ ៩ វិច្ឆិកា ១៩១៧ មក ៗ គ្រាន់តែ

ក្នុងឆ្នាំ ១៩១៧ «កងទ័ពក្រហម» មានល្ខោនជាង ១ ពាន់វង់ តន្ត្រីនិងចម្រៀងរួម ១.៥០០វង់ ល្ខោនតាម kolkhoze និង sovkhoze ៣០០ វង់ ។

នៅសហភាពសូវៀត មានល្ខោន ៥ បែបគឺ

– ផ្នែកកំសត់ (Théâtre dramatique)

– មហោស្រពធំៗ និងរបាំ (Théâtre d'opéra et ballet)

– ផ្នែកកំប្លែង (Théâtre de la comédie lyrique)

– ផ្នែកយុវជន (Tléâre de jeune spectateur)

– ផ្នែកតុក្កតា (Théâtre de marionnettes)

នៅ Moscou មានវង់ល្ខោនសំខាន់ៗ ៣៤ នៅ Léningrad ១៨ ។

សាច់រឿង ច្រើនជាស្នាដៃរបស់អ្នកនិពន្ធល្បីៗ ដូចជា « Le Mystère-Bouffe » របស់ Maïakovski ដែលរៀបរាប់ពីជោគជ័យនៃការបដិវត្តន៍ និងប្រវត្តិនៃការរំដោះជាតិ ; រឿង « Olivier Cromwell » រឿង La Révolte de Pougatchev, Rythmes, Mon ami, Après le Bal, Honneur et Amour, Les Ennemis, les Villégiateurs, les Barbares ។ល។

ក្រៅពីនេះ នៅមានរឿងបរទេស (អាល្លឺម៉ង់ បារាំង អង់គ្លេស អាមេរិក) ដែលមានសារៈសំខាន់បំរើប្រជាជន និងមនុស្សជាតិ ក៏យកមកលេងដែរ: Sheakespeare, Schiller, Molière, Goldoni, Gogol ។ល។ ឬរឿងថ្មីៗ ដូចជា «Filumena Maturano» «Ma Famille» របស់ Eduardo de Filippo (អ៊ីតាលី) «Une Berceuse vendue» របស់ H. Laxness (អ៊ីស្លង់), «Le nid de pierre» របស់ H. Vulijoki (ហ្វាំងឡង់)

គ) អំពីរបាំ

របាំតាមប្រពៃណី បានសាធារណរដ្ឋនិមួយៗ រក្សាទុកខ្ជាប់ណាស់ ។ ជាសិល្បៈជាតិរបស់គេ (art folkhlorique) ។ របៀបអំពីភ្លេងកាយវិការ លោត រាំ លុតជង្គង់ ពត់ពេនខ្លួន ញ៉ុម្រាមតាមសង្វាក់ស្គរសំលៀកបំពាក់តាមប្រពៃណី ។ ឯរបាំសម័យ (dancing) ក៏មានដែរ ។ តែល្បាបៗ ឡើង អ្នកមានប្តីប្រពន្ធ អ្នកមានសង្សារគូចាស់ ក្រុមកម្លោះ បណ្តើរគ្នាទៅបន្តកន្ទុយចាំចូលភោជនាគារ ទទួលទាននិងកំសាន្តតាមបែបអឺរ៉ុបនេះ ។

ឃ) អំពីភ្លេង និងចំរៀង

ភ្លេងមានពីរបែប ហើយត្រូវបានគេនិយមដូចៗគ្នា :

– ភ្លេងបូរាណ ទ្រ ឈើប៉ី ខ្លុយ ឃឹម និងស្គរ

– ភ្លេងសម័យ ភ្លេងខ្មែរ ត្រែ ស្គរ ។

អ្នកភ្លេងល្បីឈ្មោះជាងគេ គឺ R. Glier,



D.Kabalievski, N.Miaskovki, Rokofiev, T.Khrennikov ។ល។ ចម្រៀងល្បីគឺៈ "ចំរៀងជួយយើងច្បាស់នៅទីធ្វើការ" ; ចំរៀងបដិវត្តន៍ដែលគេចូលចិត្តគឺ : Hardi, Camarades, La Varsovienne, Vous les victimes, Nous les forgerons.

អ្នកតែងចំរៀងល្បីឈ្មោះ A. Alexandrov, V. Zakharov, I. Dounaïevski, les fères Pokrass.

សាលាអប់រំភ្លេង ត្រូវរៀន ១០ ឆ្នាំ មាន ១៩ កន្លែង; ត្រូវរៀនតែ ៧ ឆ្នាំ មាន ៩០០ សាលា ។ សាលាសំខាន់ជាងគេគឺ le Conservatoire de Moscou Tchaïkovski ។ នៅសមាគមនិងរោងចក្រធំៗ មានក្រុមភ្លេងដល់ទៅ ១៦.៧០០ ក្រុម ។ វង់ធំបំផុតគឺ L'orchestre symphonique d'Etat de l'URSS; le Grand Orchestre symphonique de la Radio-Télévision de l'URSS (មណ្ឌលផ្សាយរូបទស្សន៍ជាង ១០០, ស្ថានីយផ្សាយបន្ត ១៨០) ។

## ៥–អំពីគំនូរ និងបម្លាក់

គណៈប្រតិភូបានទស្សនាសារមន្ទីរ Musée de l'ermitage និងការិយាល័យនៃអ្នកគំនូរដ៏ល្បីជាតិ géorgien (Lado Gondiachvili).

អ្នកគំនូរក៏បានរួបរួមគ្នាជាសហភាពដែរ ។ សារមន្ទីរសិល្បៈមាន ១១៥ ហើយអ្នកទស្សនាមួយឆ្នាំៗ មាន ១០ លាននាក់ ។ ខ្ញុំបានឃើញគំនូរ របនាពីជីវភាពប្រជាជនតាមសម័យកាលនិមួយៗ ការបដិវត្តន៍ ព្រឹត្តិការណ៍ក្នុងចំបាំងបង្ហូរឈាមក្នុងស្រុក រូបអ្នកដឹកនាំសំខាន់ៗ ។

## ៦– លទ្ធិនិងជំនឿ

### ក) លទ្ធិ

ភោគផលនិងទ្រព្យសម្បត្តិធំៗ ទាំងអស់ជារបស់ប្រជាជនដែលពង្កកការកាន់កាប់ តែពលរដ្ឋម្នាក់ៗ អាចនឹងមានកម្មសិទ្ធិផ្ទាល់ខ្លួន ។ កម្មសិទ្ធិនេះជាកំរៃដែលបានមកពីការសន្សំ (សម្ភារៈប្រើប្រាស់ក្នុងផ្ទះ រថយន្ត គេហដ្ឋានខ្លះ) ។ តែពលរដ្ឋគ្មានសិទ្ធិ នឹងយកកម្មសិទ្ធិផ្ទាល់នោះទៅធ្វើ

ជំនួញទេ (ជាវិស័យរបស់រដ្ឋ) ។

១) ជំនឿ

បរិស័ទចាស់ ៗ ច្រើននិយមសាសនាគ្រិស្តវិបប Orthodoxe (មិននៅក្រោម Pape នៅ Vatican ទេ) ។ ទ. នៅ Ouzbékistan និង Géorgie ដែលខ្ញុំបានទស្សនា មានវិហារ Islam និង Protesant ជាច្រើន ។ អ្នកស្រុកជាតិ Islam មិនទទួលទានសាច់ជ្រូកទេ យកទឹកដោះពពែ ចៀម គោជំនួសវិញ; ប្រុសពាក់កាតិប ស្រីស្លៀកដូចបាម ។

ពួកយុវជនមិនសូវជឿទេ ច្រើនតែជឿលើកម្លាំងខ្លួន លើវិទ្យាសាស្ត្រ លើកម្លាំងការងារជាធំៗ

## III – យោបល់

តាមការរៀបរាប់ ដោយសង្ខេបមកខាងលើ ឃើញថាវប្បធម៌របស់ ស.ស.ស.ស. មានការចម្រើនល្អគួរណាស់មែន (បើធៀបទៅនឹងប្រទេសដែលខ្ញុំចូលទស្សនាដែរ គឺប្រទេសសាធារណរដ្ឋសង្គមនិយមឆេកូស្លូវ៉ាគី និងប្រទេសបារាំង) ។ ការល្អគួរណាស់ដ៏មានសន្ទុះបែបនេះ គឺជាលទ្ធផលដែលកើតមកអំពីការ ប្រជាជនគេ បានរួបរួមកម្លាំងគ្នា កសាងប្រទេសក្នុងវិស័យនេះ មកចំនួន ៤៥ ឆ្នាំហើយ (គិតតាំងពីឆ្នាំបដិវត្តន៍ ខែតុលា ១៩១៧ មកសព្វថ្ងៃនេះ) ។



# សកម្មភាពសមាគម

ក្នុងខែកក្កដា និងខែសីហា កន្លងទៅនេះ សមាគមយើងបានបំពេញកិច្ចការ និងសកម្មភាពពិសេស ៗ ដូចតទៅ ៖

១– បានអញ្ជើញលោកលាង-ហាប់-អាន ដែលបានរួមក្នុងដំណើរទស្សនកិច្ច នៃអ្នកនិពន្ធខ្មែរ នៅសហភាពសូវៀត ឲ្យធ្វើសន្និសីទមួយស្ដីអំពី "វប្បធម៌និងអក្សរសាស្ត្រ" នៅប្រទេសនេះ ៗ មានសមាជិក-សមាជិកាជាង ៣០០ នាក់ បានទៅស្ដាប់ដោយយកចិត្តទុកដាក់ជាទីបំផុត ៗ ក្នុងឱកាសនោះ មានទាំងតាំងរូបថតខ្លះផង ដើម្បីបង្ហាញរូបគណៈប្រតិភូខ្មែរនៅកន្លែងផ្សេង ៗ ដែលបានទស្សនា ៗ

២– បានចូលជាភាគទាន ៥០០ រៀលក្នុងរឿងក្ដី ព្រះវិហារ ៗ ទឹកប្រាក់នេះ ឃើញហាក់ដូចជាតិច មកពីមិនបានអំពាវនាវសមាជិកឲ្យចូលថែមទៀត ព្រោះដឹងថាសាស្ត្រាចារ្យម្នាក់ៗ សុទ្ធតែបានចូលតាមសាលារៀនខ្លួនរួចទៅហើយ ៗ ម្យ៉ាងទៀត ហិបប្រាក់គណៈកម្មាធិការនាយក កាលនោះកំពុងតែខ្វះ ៗ ទោះបីជាយ៉ាងណាក៏ដោយ បច្ច័យនេះក៏ទុកជានិមិត្តរូប នៃសេចក្ដីសោមនស្សសាទរឥតឧបមា នៃសមាគមចំពោះជ័យជំនះខ្មែរយើង ក្នុងរឿងក្ដីព្រះវិហារនេះដែរ ៗ

៣– បានចូលបុណ្យជាប្រាក់ ៥០០ រៀល ក្នុងពិធីឈាបនកិច្ច នៃនិស្សិតសាស្ត្រាចារ្យម្នាក់ ដែលទើបនឹងចូលរៀនថ្នាក់ឆ្នាំទីមួយ ហើយទទួលអនិច្ចកម្មទៅ គួរជាទីសោកស្ដាយ ៗ

សមាជិកគណៈកម្មាធិការនាយក ២ រូបបានដំណាងសមាគមទៅចូលហែក្បួននេះ ៗ

៤– បានធ្វើអន្តគមន៍ សុំឲ្យសាស្ត្រាចារ្យ ៤ រូប ដែលទើបនឹងប្រឡងជាប់សញ្ញាប័ត្រ ឆ្នាំជំបូងនៅមហាវិទ្យាល័យ ឲ្យធ្វើការនៅភ្នំពេញ ដើម្បីនឹងបានបន្តវិជ្ជាទៅទៀត សំរាប់រៀបចំបរិញ្ញាប័ត្រ ៗ

៥– បានធ្វើសេចក្ដីថ្លែងការណ៍មួយ ប្រឆាំងនឹងពាក្យមួលបង្កាច់របស់កាសែត "អ្នកនាំសារ" ហើយបានបញ្ជាក់ អាកប្បកិរិយាត្រឹមត្រូវរបស់

សាស្ត្រាចារ្យយើងចំពោះបញ្ហាជាតិ និងសំដែងស្វាមីភក្តិចំពោះសម្តេចព្រះបិតាជាតិ (សូមអានអត្ថបទនៅក្នុងកថាមុខទស្សនាវដ្តីលេខនេះ) ។

៦- បានធ្វើញត្តិ ឧបត្ថម្ភ វិធានការដែលសម្តេចព្រះប្រមុខរដ្ឋទ្រង់បានចាត់ចែង ដើម្បីទប់ទល់នឹងការឈ្លានពានរបស់ថៃនិងវៀតណាមខាងត្បូង ដែលវាប្រមាថទឹកដី បូរណភាព ឯករាជ្យ និងអព្យាក្រឹតភាពប្រទេសយើង (សូមអានអត្ថបទនៅក្នុងកថាមុខទស្សនាវដ្តីលេខនេះ) ។

៧- បានចាត់ចែងបោះពុម្ពបណ្ណថែមទៀត សំរាប់ជូនសមាជិកកាន់ ហើយដែលអាចឲ្យទិញសៀវភៅថោកបាន ១០% នៅបណ្ណាគារខ្លះនៅភ្នំពេញ ។ បានចាត់ចែងបោះពុម្ពទស្សនាវដ្តីលេខ ៨ នេះ ។

៨- បានទទួលប្រាក់ភាគទានពីសមាជិកនៅខេត្តនិងស្រុកខ្លះ ដែលបានចាត់ដំណាងយកទៅប្រគល់ឲ្យសមាជិកគណៈកម្មាធិការនាយក ព្រមទាំងឆ្លើយឆ្លងសំបុត្រជាច្រើន ជាមួយនឹងសមាជិកនៅជិតឆ្ងាយ ។ សូមអរគុណយ៉ាងជ្រាលជ្រៅ ចំពោះសមាជិកទាំងនោះ ។

៩- បានធ្វើសំបុត្រគំរូមួយ អំពីការផ្លាស់លោក ស៊ុង ស៊ៀង និង ប៉ាប់ រ៉ិតស្លួង ដោយមានសមាជិកជាង ១៥០ នាក់ចុះហត្ថលេខាឧបត្ថម្ភផង ។ សូមបញ្ជាក់ថាបានជាមិនបានឲ្យសមាជិកឯទៀតចុះហត្ថលេខាផង មកពីប្រញាប់បញ្ជូនសំបុត្រនោះឲ្យទាន់ពេលវេលា ។

មិត្តសាស្ត្រាចារ្យទាំងអស់ ប្រហែលជាបានស្តាប់តាមវិទ្យុនូវព្រះរាជសន្និសីទនៅខេត្តកំពង់ស្ពឺរួចហើយ ដែលសម្តេចព្រះប្រមុខរដ្ឋទ្រង់បានដោះស្រាយបញ្ហានេះ ដោយព្រះទ័យសន្តោសជាទីកក់ក្តៅក្រៃលែង ។ សមាគមបានសរសេរសំបុត្រមួយច្បាប់ថ្វាយព្រះអង្គ ដើម្បីសំដែងសេចក្តីអំណរចំពោះព្រះមហាករុណាធិគុណនេះ ។ សំបុត្រនោះមានសេចក្តីដូចតទៅ ៖

សមាគមសាស្ត្រាចារ្យខ្មែរ
លេខ ១៣ ស.ស.។

សូមព្រះតេជៈដ៏គល់លើត្បូង

សូមក្រាបបង្គំទូលថ្វាយសម្តេចព្រះប្រមុខរដ្ឋ

សូមទ្រង់ជ្រាបក្រោមល្អងធូលីព្រះបាទ

ក្នុងនាមនៃសាស្ត្រាចារ្យទាំងអស់ជាសមាជិក គណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យ,

សូមក្រាបបង្គំ ថ្វាយនូវសេចក្តីសោមនស្សរីករាយរកទីបំផុតគ្មាន ក្រោយដែលសម្តេចឪទ្រង់បានដោះស្រាយ រឿងថ្នាស់សាស្ត្រាចារ្យ ជីវ មុល ថាច់ ហ៊ង់ល្អួង និង សុឆ សេឆ ដោយព្រះមហាករុណាធិគុណ និងដោយព្រះបញ្ញាញាណឈ្លាសវៃ គួរជាទីគក់ក្តៅដល់កូនចៅព្រះអង្គទាំងអស់ ហើយដោយសម្តេចឪទ្រង់បានព្រះរាជានុញ្ញាតឲ្យលោកថាច់ ហ៊ង់ល្អួង និងលោក សុឆ សេឆ នៅកាន់ដំណែងដដែលក្នុងវិទ្យាស្ថានជាតិគរុកោសល្យ ។

សមាគមសាស្ត្រាចារ្យ ដែលបានសូមលោករដ្ឋមន្ត្រីក្រសួងអប់រំពិនិត្យរឿងនេះ ដោយអនុគ្រោះ ក៏ដោយសារតែសាស្ត្រាចារ្យទាំងឡាយធ្លាប់ស្គាល់ និងស្រឡាញ់ចរិយាសម្បត្តិរបស់អ្នកទាំងបីនេះតែប៉ុណ្ណោះ តែពុំបានគិតថា រឿងនេះអាចទៅដល់សម្តេចឪម្ចាស់ នាំរំខានដល់ព្រះអង្គឡើយ ។

ទូលព្រះបង្គំទាំងឡាយ សូមឱនកាយសម្តែងនូវកតញ្ញូតាទីងស្វាមីភក្តិ យ៉ាងជ្រាលជ្រៅចំពោះព្រះអង្គ សូមទ្រង់ប្រកបតែនឹងបរមសុខ ដើម្បីទ្រង់គង់នៅជាមគ្គុទ្ទេសក៍ដឹកនាំកម្ពុជាឯករាជ អព្យាក្រឹត បំរុងចំរើន លុះអវសានកាល ។

សូមក្រាបបង្គំទូលថ្វាយ នៅថ្ងៃ ៣ សីហា ១៩៦៦

គណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យ

រួចយើងបានដំណឹងតមកទៀតថា បន្ទាប់ពីព្រះរាជសន្និសីទនេះមក លោកសាស្ត្រាចារ្យ ឌឹវ អុល បានសរសេរសំបុត្រមួយផ្ទាល់ខ្លួន ចុះថ្ងៃទី ៣ សីហា ឆ្នាំ ១៩៦២ ថ្វាយសម្ដេចឪ ដើម្បីនឹងបញ្ជាក់ដោះស្រាយនូវលេសដែលចោទលើខ្លួនលោក ព្រមទាំងដើម្បីនឹងសំដែងជាថ្មីម្ដងទៀតនូវសេចក្ដីស្វាមីភក្ដីនឹងសុទ្ធចិត្តគ្មានរង្គើររង្គើរបស់លោក ចំពោះព្រះរាជបល្ល័ង្ក ចំពោះព្រះអង្គសម្ដេចឪដែលជាស៊ីម៉ង់ផ្សារភ្ជាប់នូវឯកភាពនៃផ្ទៃក្នុងជាតិ នឹងចំពោះព្រះមាតានយោបាយអព្យាក្រឹតនិងបង្រួបបង្រួមជាតិ ដែលជាការធានាអះអាងដល់សន្តិសុខនិងបូរណភាពដែនដីនៃជាតិ ។

ហើយតាមលិខិតលេខ ១៨៧ SPU/II ចុះថ្ងៃ ១៤ សីហា ១៩៦២ នៃលេខាធិការដ្ឋានផ្ទាល់ព្រះអង្គសម្ដេចព្រះប្រមុខរដ្ឋទ្រង់សព្វព្រះរាជហឫទ័យត្រាស់ឲ្យជំរាបលោកសាស្ត្រាចារ្យ ឌឹវ អុល វិញថា ទ្រង់ជឿនូវពាក្យសំដីទាំងអស់របស់លោក បើមិនមានហេតុអ្វីទៅថ្ងៃក្រោយទៀត ។

**NOuvelle revue pédagogique** (bimensuel)
Fernand Nathan et Cie,
18, rue Monsieur le Prince Paris 6e
**L'Ecole des parents** (mensuel)
47, rue de Miromesnil, Paris 8e
**L'Ecole libératrice** (bihebdomadaire)
94, rue de l'Université, Paris 7e




## I— តបនឹងសំណួមពររបស់លោក អ៊ុក សាម៉ន

## សាស្ត្រាចារ្យនៅសាលាជាតិខាងសិល្ប និង មុខរបរនៅភ្នំពេញ

*— គណៈកម្មាធិការនាយក បានពិនិត្យហ្មត់ចត់នូវការស្នើរបស់លោក ដែលសរសេរជាអត្ថបទយ៉ាងវែងសំរាប់ចុះក្នុងទស្សនាវដ្ដីយើង ។ សូមអរគុណជាពន្លឹក ដែលលោកបានយកចិត្តទុកដាក់នឹងកិច្ចការ សមាគមយើង ប៉ុន្តែដោយទស្សនាវដ្ដីយើងបន្ថែមទំព័រច្រើនពេកពុំបាន ព្រោះគ្មានសោហ៊ុយ សូមលោកអនុញ្ញាតឲ្យយើងសារុបចំណុចស្នើទាំងឡាយរបស់លោក នឹងជូនយោបល់យើងចំពោះចំណុចទាំងនោះដូចតទៅ ៖*

១– អំពីទស្សនាវដ្ដី

ស្នើៈ— *ខាងរូបភាព លោកបានស្នើឲ្យបង្កើនចំនួនទំព័រ ព្រោះ "អានមិនទាន់ទាំងផ្អែតស្រួលបួលផង ក៏ស្រាប់តែអស់ទំព័រទៅហើយ !„ ម្យ៉ាងទៀតលោកស្នើឲ្យលែលកចេញបាន ២ ខែម្ដង ។*

ឆ្លើយៈ— *យើងយល់ស្របនឹងយោបល់នេះ ប៉ុន្តែខុបសគ្គបញ្ហាថ្លៃនៅត្រង់សមាគមខ្វះប្រាក់នឹងធ្វើ ។ ទស្សនាវដ្ដីចេញមួយលេខ ៗ ដំរូវឲ្យចាយប្រាក់៨០០០៛ (កំពស់ជាង ៩០ ទំព័រ បោះ ១០០០ ក្បាល) ។ បើចេញ ២ ខែម្ដង គឺមួយឆ្នាំ ៦ ដង ត្រូវចាយប្រាក់ ៤៨.០០០៛ គិតទៅក្បែរនឹង ៥ ម៉ឺនរៀល ។ បើសិនជាសមាជិកទាំង ៧៩០ នាក់បង់និងផ្ញើភាគទានឲ្យបានទៀងទាត់ ការស្នើរបស់លោកនឹងអាចអនុមតិ ហើយយកមកអនុវត្តបាន ។*

ស្នើ៖– ខាងខ្លឹមសារ លោកបានស្នើឲ្យប្រគល់ភារៈសរសេរ ទៅគណៈកម្មការនិពន្ធមួយ ទើបមានឯកភាពក្នុងគំនិតនិងខ្លឹមសារ "រីឯអត្ថបទរបស់មិត្តយើងនានានោះ ត្រូវតែជាអត្ថបទស្វ័យរិន, សេរី" ដាក់ដោយឡែក ក្រោមចំណងជើងថា "ទំព័រសំរាប់មិត្តយើង" វិញ ។ ចំពោះប្រធានអត្ថបទ លោកបានស្នើថា "ត្រូវតែអត្ថបទបំភ្លឺណែនាំផ្សេងៗ ខាងវិជ្ជាគរុកោសល្យ" សូម "ឲ្យមានចុះតាមលទ្ធភាពរបស់គណៈកម្មការ សំរាប់ជាការចេះដឹងទូទៅ (connaissance générale) នូវពតិមានខ្លះដូចជា – ការធៀបប្រៀបបៀវត្សរបស់បុគ្គលិកសិក្សា គ្រប់ជាន់ថ្នាក់ទៅនឹងបៀវត្សនៃបុគ្គលិកក្រសួងដទៃទៀត – អំពីលក្ខន្តិកៈរួមនៃអ្នករាជការ – អំពីមុខងារនៃក្រសួងធនាគារជាតិ-របៀបប្តូរប្រាក់ – « អំពីលក្ខណៈដែលត្រូវបំពេញមុននឹងចេញដំណើរទៅបរទេស – ដម្លៃនិងរយៈ « ពេលពីប្រទេសមួយទៅប្រទេសមួយ ។ល។ និង ។ល។ – អំពីរបៀបសិក្សាធិការនៅសហរដ្ឋអាមេរិក, នៅសហភាពសូវៀត, នៅចិន, នៅចេកូស្លូវ៉ាគី ។ល។ – អំពីកំរិតភូមសិក្សា (cycle d'enseignement) – ការធៀបប្រៀបកំរិតវិជ្ជា (degré d'instruction) ។ល។ និង ។ល។» និងចុះវិញ្ញាសារប្រឡង « ប្រជែងគ្រប់បែបយ៉ាងដែលមានធ្វើកន្លងរាប់ប៉ុន្មានឆ្នាំមុន មកទល់សព្វថ្ងៃ » ។

ឆ្លើយ៖– គណៈកម្មការទស្សនាវដ្តីបានចាត់តាំងរួចហើយ ។ សមាជិកគណៈកម្មការនេះមានភារៈសរសេរអត្ថបទសំរាប់គ្រប់លេខ មិនចាំតែមានអត្ថបទសមាជិកពីខាងក្រៅសរសេរមកប៉ុណ្ណោះទេ ។ ប្រធានអត្ថបទ ដូចលោកបានស្នើ គួរឲ្យយើងកត់សំគាល់ដែរ ហើយក្នុងទស្សនាវដ្តីលេខ ៨ នេះ យើងបានចុះជូននូវសន្និសីទស្តីអំពី វប្បធម៌និងអក្សរសាស្ត្រនៅសហភាពសូវៀត ចុះអត្ថបទជាភាសាបារាំងស្តីអំពីស្ថានការណ៍សិក្សានៅមហាវិទ្យាល័យវិទ្យាសាស្ត្រយើង ចុះវិញ្ញាសារផ្សេងៗ ដែលបានឲ្យក្នុងការប្រឡងប្រជែងចូលវិទ្យាស្ថានជាតិគរុកោសល្យ ។

លើកក្រោយ យើងនឹងចុះជូននូវសារាចរ និងឯកសារជាផ្លូវការផ្សេងៗ ព្រមទាំងធ្វើអត្ថាធិប្បាយពន្យល់សមាជិកយើងផង ។

ស្នើ៖– ខាងមធ្យោបាយ លោកបានស្នើឲ្យជួលស្មៀនមួយឲ្យបានឆាប់ៗ តាមសេចក្តីសំរេចរបស់

មហាសន្និបាតពីខែមិថុនា ហើយឲ្យកំរៃខ្លះជារង្វាន់លើកទឹកចិត្តដល់ សមាជិកនៃគណៈកម្មការនិពន្ធទស្សនាវដ្ដី ។

ឆ្លើយៈ– អំពីស្មៀន សព្វថ្ងៃនេះជួលបានម្នាក់ហើយ ។ គណៈកម្មាធិការនាយកកំពុងតែដើររកជួលផ្ទះធ្វើជាទីស្នាក់ការ តែរកពុំទាន់បាន ។ រីឯកំរៃជាប្រាក់ជូនសមាជិកគណៈកម្មការនិពន្ធវិញ អ្នកទាំងនោះពុំទាន់ចង់បានទេសព្វថ្ងៃនេះ ពីព្រោះដឹងថាហិបប្រាក់សមាគមយើងនៅខ្សត់ខ្សោយនៅឡើយ ហើយសូមឲ្យតែសមាជិកទាំងអស់គាំទ្រទស្សនាវដ្ដីឲ្យចប់ចុងចប់ដើម ហើយនឹងជួយផ្ដល់គំនិតខាងការរិះគន់តែប៉ុណ្ណោះ ចំទុកជាការលើកទឹកចិត្តសន្ធឹកណាស់ទៅហើយ ។

## ២ អំពីការចារវិភាគទាន

ស្នើៈ– លោកស្នើឲ្យដំរូវដំណាងសមាគមប្រចាំវិទ្យាល័យ ឬ អនុវិទ្យាល័យនិមួយ ៗ ផ្ញើប្រាក់វិភាគទានជាពីរលើកក្នុងមួយឆ្នាំសិក្សា គឺផ្ញើនៅក្នុងខែវិច្ឆិកាសំរាប់ឆមាសទីមួយ និងក្នុងខែមេសាសំរាប់ឆមាសទីពីរ ។ ឯរបៀបប្រមូលវិភាគទាន លោកបានស្នើឲ្យដំណាងសមាគមអនុវត្តតាមតារាងដូចមានខាងក្រោមនេះ ៖

### សំរាប់ឆមាសទី ១ នៃឆ្នាំសិក្សា ១៩៦២-១៩៦៣

| ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|
| កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ↓ | ↓ | ↓ | ↓ | ↓ | ↓ |
| ប្រមូលប្រាក់ខែហ្នឹងក៏បាន | ប្រមូលប្រាក់ខែហ្នឹងក៏បាន | ប្រមូលប្រាក់ខែហ្នឹងក៏បាន | យ៉ាងយូរត្រូវប្រមូលនៅខែនេះ | ប្រាក់ត្រូវផ្ញើដំណើរទៅភ្នំពេញ | ប្រាក់ត្រូវនៅក្នុងហិបទាំងអស់ |

# សំរាប់ឆមាសទី ២ នៃឆ្នាំសិក្សា ១៩៦២-៦៣

| ១ | ២ | ៣ | ៤ | ៥ | ៦ |
|---|---|---|---|---|---|
| មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា |
| V | V | V | V | V | V |
| -ជ- | -ជ- | -ជ- | -ជ- | -ជ- | -ជ- |

ឆ្លើយៈ- សេចក្តីស្នើនេះត្រឹមត្រូវណាស់ ព្រោះជាកម្មវិធីច្បាស់លាស់សំរាប់ការវិភាគទាន ដែលងាយយល់នឹងងាយអនុវត្ត ព្រមទាំងជួយសំរាលការងារគណៈកម្មាធិការនាយកបានសន្ទឹកផង ។ យើងគ្រាន់តែថែមសេចក្តីបញ្ជាក់ថា កុំឲ្យដំណាងការសារុបទាំង ៦ ខែតែម្តង ព្រោះបង់ ១២០៛ តែមួយលើកឃើញហាក់ដូចជាច្រើនពេក ហើយសមាជិកមុខជាមានការត្អូញត្អែរពុំខាន ។ ដូចមានក្នុងគំរោងខាងលើស្រាប់ គប្បីដំណាងលៃលកការម្តងបន្តិច គឺការឲ្យហើយក្នុងរយៈ ៤ ខែដំបូងក្នុងឆមាសទី ១ ប៉ុន្តែដល់ឆមាសទី ២ គប្បីការឲ្យហើយក្នុងរយៈ ៣ ខែដំបូង ព្រោះ ៣ ខែចុងក្រោយជាពេលវិស្សមកាល ដែលសាស្ត្រាចារ្យត្រូវបែកគ្នាម្នាក់ មួយកន្លែងផ្លាស់ទៅសាលាផ្សេងទៀត ។ ហេតុដូច្នេះ យើងសូមដាក់ការស្នើនេះឲ្យដំណាងយើងនៅគ្រប់សាលាពិនិត្យ ហើយជូនយោបល់ខ្លះទៅគណៈកម្មាធិការនាយក ដើម្បីនឹងសំរេចថា គួរឬពុំគួរអនុវត្តការស្នើនេះក្នុងឆមាសទី ១ នេះ ។

គណៈកម្មាធិការនាយក សូមអរគុណមិត្ត អ៊ុក សាម៉ឆ ជាអនេកប្បការម្តងទៀត ចំពោះការស្នើប្រកបដោយវិចារណញ្ញាណទាំងប៉ុន្មានរបស់មិត្តខាងលើនេះ ហើយសង្ឃឹមថា ក៏ដូចជាមិត្ត អ៊ុក សាម៉ឆ នេះដែរ មិត្តឯទៀត ៗ ក៏មុខតែមិនខកសេចក្តីអំពាវនាវរបស់យើង (ក្នុងការសូមយោបល់) ឲ្យនៅស្ងៀមស្ងាត់ឡើយ ។

## II— សំបុត្រពីខែត្រស្វាយរៀង

### ដំណឹងរីករាយ

ដោយបានដឹងថា សម្តេចព្រះប្រមុខរដ្ឋ ស្តេចបានរកយុត្តិធម៌ ឲ្យលោក ជាច់ ពាំង ល្ហួង លោក សុន សេន នឹង លោក ឌីវ អុល ។

ដោយបានដឹងថា សម្តេចព្រះបិតាឯករាជ្យជាតិ ស្តេចប្រោសព្រះរាជទានលោក សុន សេន នឹង លោក ជាច់ ពាំងល្ហួង ឲ្យនៅរៀបចំធ្វើការក្នុងវិទ្យាស្ថានជាតិគរុកោសល្យតទៅទៀត ។

ដោយដឹងថា សម្តេចឪទ្រង់យល់កាន់តែច្បាស់ដល់សន្តានចិត្តរបស់សាស្ត្រាចារ្យ ចំពោះការស្ថាបនាប្រទេសជាតិ ។

យើងខ្ញុំជាសាស្ត្រាចារ្យ វិទ្យាល័យ សូរិយោវង្ស (ស្វាយរៀង) សូមសំដែងចិត្តរីករាយឥតឧបមា ព្រោះយើងទាំងឡាយធ្លាប់បានដឹងច្បាស់អំពីការរគាក់រអួលដំណើរនៃវិទ្យាស្ថានជាតិយើងជាយូរណាស់មកហើយ គឺតាំងពីវិទ្យាស្ថានរៀបនឹងចាប់កំណើតម៉្លេះ ។

គណៈសាស្ត្រាចារ្យ
វិទ្យាល័យព្រះសូរិយោវង្ស

សូម មិត្ត អាន ឲ្យ ចប់ ហើយ ឲ្យ យោ បល់ !

## សេចក្ដីបញ្ជាក់

សូមមិត្តអ្នកអានជ្រាបថា អត្ថបទរបស់យើង ស្ដីពី "អាកប្បកិរិយារឹងរុះ......" ក្នុងផ្នែក "សួនផ្កាសាលា" បាននិពន្ធនឹងបោះពុម្ពរួច មុនព្រះរាជសន្និបាត ដែលសម្ដេចឪ ទ្រង់សព្វព្រះរាជហឫទ័យប្រោសប្រទាន ដល់បណ្ដាសមាជិកនៃរាជរដ្ឋាភិបាល នឹង រដ្ឋសភា កាលពីថ្ងៃ៩ តុលា ១៩៦២ នេះ ដែលមិត្តយើងបានជ្រាបអត្ថន័យរួចហើយ ពីបញ្ហានេះ ។

## កំប្លែងទេ ?

ខ្ញុំមានមិត្តម្នាក់ ជាសាស្ត្រាចារ្យ ទើបនឹងចេញពីវិទ្យាស្ថានជាតិដូចគ្នា ដែលមានទេពកោសល្យម្យ៉ាង ខាងមិន "ធ្វើអ៊ីធ្វើឲ្យហើយ កុំទុកឡើយ....." ។ សូម្បីតែក្នុងការពន្យល់ ក៏គេមិនបញ្ចប់ប្រយោគគេដែរ គេទុកឲ្យសិស្សណាមានចិត្ត "ជួយធ្វើសហប្រតិបត្តិការ" នឹងគេចុះ!

ខ្ញុំក៏មិនហ៊ានយល់ថា តើគេជាអ្នកខ្ជិល ឬក៏ជាអ្នកមានល្បិច មាន "ការសំងាត់" ក្នុងវិធីពន្យល់ដែរ..... ពីព្រោះមាន "អ្នកគរុកោសល្យ" ខ្លះអះអាងថា វិធីនេះធ្វើថ្នាក់ឲ្យមាន "ជីវិត", ខ្លះនិយមថា ធ្វើថ្នាក់ "មិនឲ្យស្ងាប់", ខ្លះទៀតថា ធ្វើថ្នាក់ "មិនឲ្យត្រជាក់", ថានាំឲ្យសិស្សប្រុងប្រយ័ត្នតាមគំនិតរបស់សាស្ត្រាចារ្យ ថាជួយសិស្សខ្សោយឲ្យទាន់គេ ថា.... ថា....បេះតែថាទៅ.... !

ប៉ុន្តែ ...... ប៉ុន្តែ មានថ្ងៃមួយនោះ ខ្ញុំមានកញ្ចប់សនាទីឯបានទៅបង្រៀនជាប់នឹងថ្នាក់របស់ "អ្នកគរុកោសល្យ ហើយស្រាប់តែភ្ញាក់ព្រើតនឹងសម្លេងគិល ៗ ព្រម ៗ គ្នានៃសិស្សថ្នាក់គេ ។ ខ្ញុំក៏ផ្ទៀងស្ដាប់ :

គ្រូ – ហើយគៀវទាំងឡាយ កំឡើងយន្តហោះប្រតិ ......

សិស្ស- (គិលព្រម ៗ គ្នា) – កិរិយា !

ខ្ញុំលបមើលទឹកមុខរបស់គ្រូ ឃើញស្មឿក !

អរិកាល